ឆ្នាំឌុប

# វិញ្ញាសាត្រៀម

## គណិតវិទ្យា(ថ្នាក់វិទ្យាសាស្ត្រ)

លំហាត់ និងដំណោះស្រាយ


រៀបរៀងដោយ៖ សិស្សរៀន Latex

កែសម្រួលដោយ៖ ហ៊ីង វុទ្ធី


២០២១

# មាតិកា


១ អ៊ូច ប៊ុនថន ........................................ ១

២ អ៊ី ចាន់ធា ........................................ ៩

៣ ម៉ី ចន្ទ័មករា ........................................ ២១

៤ ជិក ជី ........................................ ៣១

៥ ផល ផានុ ........................................ ៣៩

៦ ថា មករា ........................................ ៤៩

៧ រស់ មាន ........................................ ៥៧

៨ អឿន សំណាង ........................................ ៦៥

៩ Kim Hun ........................................ ៧៥

១០ សុខលាភ ........................................ ៨១

១១ សារ៉ែន សុទ្ធា ........................................ ៨៩

១២ ហ៊ីង វុទ្ធី ........................................ ៩៧

១៣ ហ៊ីង វុទ្ធី ........................................ ១០៥

១៤ ហ៊ីង វុទ្ធី ........................................ ១១៣

១៥ ហ៊ីង វុទ្ធី ........................................ ១១៩

ក្រសួងអប់រំ យុវជន និងកីឡា    លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**    លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________    អក្សរសម្ងាត់

ហត្ថលេខា៖________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

______ / 125    **១**    វិញ្ញាសា៖ **គណិតវិទ្យាត្រៀម**    រយៈពេល៖ 120 នាទី    អក្សរសម្ងាត់

រៀបរៀងដោយ៖ **អ៊ុច ប៊ុនថន**

**I** នៅក្នុងទូទឹកកកមួយមានភេសជ្ជៈពីរប្រភេទគឺ ខាប៉ាបាវ 12 កំប៉ុង និងបាកាស 8 កំប៉ុង ។ បុរសម្នាក់បានយកភេសជ្ជៈបីកំប៉ុងចេញពីទូទឹកកកដោយចៃដន្យ។

១. រកប្រូបាបដែលបានបាកាសទាំងបីកំប៉ុង។

២. រកប្រូបាបដែលបានខាប៉ាបាវយ៉ាងតិចមួយកំប៉ុង។

**II** ១. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យ $(1-2i)x+(1+2i)y=1+i$ ។

២. រកចំនួនកុំផ្លិច $Z$ ដែលផ្ទៀងផ្ទាត់ $|Z|+Z=3+4i$ ។

៣. ដោះស្រាយក្នុងសំណុំ $\mathbb{C}$ នូវសមីការ $Z^2+\sqrt{3}Z+1=0$ រួចសរសេរឬសនីមួយៗជាទម្រង់ត្រីកោណមាត្រ ។

**III** គេឲ្យអនុគមន៍ $f$ កំណត់គ្រប់ $x>0$ ដោយ $f(x)=\dfrac{3x^2+4x-25}{x^2+x-6}$ ។

១. កំណត់តម្លៃ $a,b$ និង $c$ ដើម្បីឲ្យ $f(x)=a+\dfrac{b}{x+3}+\dfrac{c}{x-2}$ ។

២. គណនាអាំងតេក្រាល $I=\displaystyle\int f(x)dx$

**IV** គេឲ្យសមីការប៉ារ៉ាបូល $P: y^2-2y+6x-6=0$ ។

១. រកសមីការស្តង់ដានៃប៉ារ៉ាបូល ។

២. រកកូអរដោនេនៃកំពូល កំណុំ និងបន្ទាត់ប្រាប់ទិស រួចសង់ក្រាបនៃប៉ារ៉ាបូល។

**V** $f$ ជាអនុគមន៍កំណត់គ្រប់ $x>0$ ដោយ $f(x)=x^2+\dfrac{1}{2}-3\ln x$ និងមានក្រាប $C$ នៅក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

១. ក. គណនាលីមីតនៃ $f$ ត្រង់ 0 ។

ខ. កំណត់អនុគមន៍ $g$ ចំពោះ $x>0$ ដែលផ្ទៀងផ្ទាត់ $f(x)=x^2g(x)$ ។ គណនាលីមីតនៃ $f$ ត្រង់ $+\infty$ ។

២. សិក្សាអថេរភាពនៃ $f$ រួចសង់តារាងអថេរភាព ។ គណនា $f\left(\dfrac{1}{2}\right)$ និង $f(2)$ ។ ( គេយក $\ln 2=0.7$ )

៣. ក. សង់ក្រាប $C$ នៅក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

ខ. តើសមីការ $f(x)=0$ មានចម្លើយ ឬទេ ? ចូរបកស្រាយ ។

**VI** នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ មួយ គេឲ្យចំណុច $A(1,2,-3),B(0,5,-1)$ និង $C(3,0,1)$។

១. ចូរសង់ចំណុច $A,B$ និង $C$ ។

២. គណនាប្រវែង $AB,AC$ និង $BC$ រួចទាញបញ្ជាក់ថាត្រីកោណ $ABC$ ជាត្រីកោណកែងត្រង់ $A$ ។

៣. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ ។ គណនាផ្ទៃក្រឡាត្រីកោណ $ABC$ ។ រកសមីការប្លង់ $(ABC)$ ។

៤. គណនាចម្ងាយពីចំណុច $O$ ទៅប្លង់ $(ABC)$ ។

## ដំណោះស្រាយ

**I**

១. រកប្រូបាបដែលបានបាកាសទាំងបីកំប៉ុង

ក្នុងទូទឹកកកមានបាកាស 8 កំប៉ុង និងខាក់បារ 12 កំប៉ុង

បុរសម្នាក់បានយកគេសជ្ជៈបីកំប៉ុងដោយចៃដន្យ

- ចំនួនករណីអាច $n(S) = C(20,3) = \dfrac{20!}{17!3!}$

$$= \frac{17! \times 18 \times 19 \times 20}{17! \times 6}$$

$$= 19 \times 20 \times 3$$

$= 1140$ ករណី

តាង $A$ : "បានបាកាសទាំងបីកំប៉ុង"

- ចំនួនករណីស្រប $n(A) = C(8,3) = \dfrac{8!}{5!3!}$

$$= \frac{5! \times 6 \times 7 \times 8}{5! \times 6}$$

$= 7 \times 8 = 56$ ករណី

គេបានប្រូបាប $P(A) = \dfrac{n(A)}{n(S)} = \dfrac{56}{1140} = \dfrac{14}{285}$

ដូចនេះ $\boxed{P(A) = \dfrac{14}{285}}$

២. រកប្រូបាបដែលបានខាក់បារយ៉ាងតិចមួយកំប៉ុង

តាង $B$ : "បានខាក់បារយ៉ាងតិចមួយកំប៉ុង"

ដោយ $B$ និង $A$ ជាព្រឹត្តិការណ៍ផ្ទុយគ្នា

គេបាន $P(B) = 1 - P(A)$ នោះ $P(B) = 1 - \dfrac{14}{285}$

$$= \frac{285 - 14}{285}$$

$$= \frac{271}{285}$$

ដូចនេះ $\boxed{P(B) = \dfrac{271}{285}}$

**II**

១. កំណត់ចំនួនពិត $x$ និង $y$

គេមាន $(1-2i)x + (1+2i)y = 1+i$

$$x - 2xi + y + 2yi = 1 + i$$

$$(x+y) + (-2x+2y)i = 1 + i$$

គេទាញបាន $\begin{cases} x+y=1 \\ -2x+2y=1 \end{cases} \Leftrightarrow \begin{cases} x+y=1 & (i) \\ -x+y=\dfrac{1}{2} & (ii) \end{cases}$

បូក $(i)$ និង $(ii)$ គេបាន $2y = 1 + \dfrac{1}{2} = \dfrac{3}{2} \Rightarrow y = \dfrac{3}{4}$

តាម $(i) : x = 1 - y = 1 - \dfrac{3}{4} = \dfrac{1}{4}$

ដូចនេះ $\boxed{x = \dfrac{1}{4}, \ y = \dfrac{3}{4}}$

២. រកចំនួនកុំផ្លិច $Z$ ដែលផ្ទៀងផ្ទាត់ $|Z|+Z=3+4i$

តាង $Z=a+bi$ នោះ $|Z|=\sqrt{a^2+b^2}$

គេបាន $|Z|+Z=3+4i$

$$\Leftrightarrow \sqrt{a^2+b^2}+a+bi=3+4i$$

$$\Leftrightarrow \begin{cases} \sqrt{a^2+b^2}+a=3 \\ b=4 \end{cases}$$

ចំពោះ $b=4$ នោះ $\sqrt{a^2+4^2}+a=3$

$$\Leftrightarrow \sqrt{a^2+16}+a=3$$

$$\Leftrightarrow \sqrt{a^2+16}=3-a$$

$$\Leftrightarrow (\sqrt{a^2+16})^2=(3-a)^2$$

$$\Leftrightarrow a^2+16=9-6a+a^2$$

$$\Leftrightarrow 16=9-6a$$

$$\Leftrightarrow 6a=-7$$

$$\Leftrightarrow a=-\frac{7}{6}$$

ដូចនេះ $\boxed{Z=-\frac{7}{6}+4i}$

៣. ដោះស្រាយសមីការ $Z^2+\sqrt{3}Z+1=0$

តាម $\Delta=(\sqrt{3})^2-4(1)(1)=3-4=-1=(i)^2$

$$Z_1=\frac{-b-\sqrt{\Delta}}{2a}=\frac{-\sqrt{3}-i}{2}=-\frac{\sqrt{3}}{2}-\frac{1}{2}i$$

$$Z_2=\frac{-b+\sqrt{\Delta}}{2a}=\frac{-\sqrt{3}+i}{2}=-\frac{\sqrt{3}}{2}+\frac{1}{2}i$$

ដូចនេះ $\boxed{Z_1=-\frac{\sqrt{3}}{2}-\frac{1}{2}i\,,\ Z_2=-\frac{\sqrt{3}}{2}+\frac{1}{2}i}$

- សរសេរឫសនីមួយៗជាទម្រង់ត្រីកោណមាត្រ

$$\begin{aligned} Z_1 &= -\frac{\sqrt{3}}{2}-\frac{1}{2}i \\ &= \cos\left(\pi+\frac{\pi}{6}\right)+i\sin\left(\pi+\frac{\pi}{6}\right) \\ &= \cos\frac{7\pi}{6}+i\sin\frac{7\pi}{6} \end{aligned}$$

ដូចនេះ $\boxed{Z_1=\cos\frac{7\pi}{6}+i\sin\frac{7\pi}{6}}$

$$\begin{aligned} Z_2 &= -\frac{\sqrt{3}}{2}+\frac{1}{2}i \\ &= \cos\left(\pi-\frac{\pi}{6}\right)+i\sin\left(\pi-\frac{\pi}{6}\right) \\ &= \cos\frac{5\pi}{6}+i\sin\frac{5\pi}{6} \end{aligned}$$

ដូចនេះ $\boxed{Z_2=\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}}$

**III**

១. កំណត់តម្លៃ $a, b$ និង $c$

គេមាន $f(x) = a + \dfrac{b}{x+3} + \dfrac{c}{x-2}$

$= \dfrac{a(x+3)(x-2) + b(x-2) + c(x+3)}{(x+3)(x-2)}$

$= \dfrac{a(x^2+x-6) + b(x-2) + x(x+3)}{x^2+x-6}$

$= \dfrac{ax^2 + (a+b+c)x + (-6a-2b+3c)}{x^2+x-6}$

តែ $f(x) = \dfrac{3x^2+4x-25}{x^2+x-6}$

គេទាញបាន $\begin{cases} a = 3 \\ a+b+c = 4 \\ -6a-2b+3c = -25 \end{cases} \Leftrightarrow \begin{cases} a = 3 \\ b+c = 1 \\ -2b+3c = -7 \end{cases} \Leftrightarrow \begin{cases} a = 3 \\ b = 2 \\ c = -1 \end{cases}$

ដូចនេះ $\boxed{a = 3\,, b = 2\,, c = -1}$

២. គណនាអាំងតេក្រាល $I = \int f(x)dx$

គេបាន $I = \int f(x)dx = \int \left(a + \dfrac{b}{x+3} + \dfrac{c}{x-2}\right)dx$

$= \int \left(3 + \dfrac{2}{x+3} + \dfrac{-1}{x-2}\right)dx$

$= 3x + 2\ln|x+3| - \ln|x-2| + k\,, (x > 2)$

$= 3x + 2\ln(x+3) - \ln(x-2) + k\,, (k \in \mathbb{R})$

ដូចនេះ $\boxed{I = 3x + 2\ln(x+3) - \ln(x-2) + k}\,, (k \in \mathbb{R})$

**IV**

១. រកសមីការស្តង់ដានៃប៉ារ៉ាបូល

គេមាន $P : y^2 - 2y + 6x - 5 = 0$

គេបាន $y^2 - 2y = -6x + 5$

$\Leftrightarrow y^2 - 2y + 1 = -6x + 6$

$\Leftrightarrow (y-1)^2 = -6(x-1)$ ជាសមីការស្តង់ដានៃប៉ារ៉ាបូលដែលមានបន្ទាត់ប្រាប់ទិសស្របនឹងអ័ក្ស $\overrightarrow{oy}$

ដូចនេះ សមីការស្តង់ដាគឺ $\boxed{P : (y-1)^2 = -6(x-1)}$

២. រកកូអរដោនេនៃកំពូល កំណុំ និងបន្ទាត់ប្រាប់ទិស

ដោយសមីការ $(y-1)^2 = -6(x-1)$ មានទម្រង់ $(y-k)^2 = 4p(x-h)$

គេទាញបាន $h = 1\,, k = 1\,, 4p = -6 \Rightarrow p = -\dfrac{3}{2}$

កំពូល $V(h,k) = V(1,1)$

កំណុំ $F(h+p,k) = F(1-\dfrac{3}{2},1) = F(-\dfrac{1}{2},1)$

បន្ទាត់ប្រាប់ទិស $x = h - p = 1 + \dfrac{3}{2} = \dfrac{5}{2}$

ដូចនេះ $\boxed{V(1,1)\ ,\ F(-\frac{1}{2},1)\ ,\ x=\frac{5}{2}}$

- សង់ក្រាបនៃប៉ារ៉ាបូល

  បើ $x=-1.5$ នោះ $y=4.8$ និង $y=-2.8$

  បើ $x=0$ នោះ $y=1\pm\sqrt{6}$




**V** គេមាន $f(x)=x^2+\frac{1}{2}-3\ln x$ ដែល $x>0$

១. ក. គណនាលីមីតនៃ $f$ ត្រង់ 0

$$\lim_{x\to0^+} f(x) = \lim_{x\to0^+}(x^2+\frac{1}{2}-3\ln x)=0+\frac{1}{2}+\infty=+\infty$$

ដូចនេះ $\boxed{\lim_{x\to0^+} f(x)=+\infty}$

ដោយ $\lim_{x\to0^+} f(x)=+\infty$

ដូចនេះ បន្ទាត់ $x=0$ ជាអាស៊ីមតូតឈរនៃក្រាប $C$ ។

ខ. កំណត់អនុគមន៍ $g$ ចំពោះ $x>0$

គេមាន $f(x)=x^2g(x)$ គេបាន $x^2+\frac{1}{2}-3\ln x=x^2g(x)$

នាំឲ្យ $g(x)=\dfrac{x^2+\frac{1}{2}-3\ln x}{x^2}=1+\dfrac{1}{2x^2}-\dfrac{3\ln x}{x^2}$

ដូចនេះ $\boxed{g(x)=1+\dfrac{1}{2x^2}-\dfrac{3\ln x}{x^2}}$ , $(x>0)$

- គណនាលីមីតនៃ $f$ ត្រង់ $+\infty$

គេបាន $\lim_{x\to+\infty} f(x) = \lim_{x\to+\infty} x^2 g(x)$

$$= \lim_{x\to+\infty} x^2\left(1+\frac{1}{2x^2}-\frac{3\ln x}{x^2}\right)$$

$$= (+\infty)(1+0-0) = +\infty$$

ដូចនេះ $\boxed{\lim_{x\to+\infty} f(x) = +\infty}$

២. សិក្សាអថេរភាពនៃ $f$

$f(x) = x^2+\frac{1}{2}-3\ln x$ ដែល $x>0$

ដេរីវេ $f'(x) = 2x-\frac{3}{x} = \frac{2x^2-3}{x}$

ដោយ $x>0$ នោះ $f'(x)$ មានសញ្ញាដូច $2x^2-3 \Rightarrow x=\sqrt{\frac{3}{2}}$

សញ្ញានៃ $f'(x)$

| $x$ | $0$ | | $\sqrt{\frac{3}{2}}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |

តម្លៃអប្បបរមាត្រង់ $x=\sqrt{\frac{3}{2}}$ គឺ $f\left(\sqrt{\frac{3}{2}}\right) = 1.39$

• គូសតារាងអថេរភាព

| $x$ | $0$ | | $\sqrt{\frac{3}{2}}$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | ↘ | $1.39$ | ↗ | $+\infty$ |

• គណនា $f\left(\frac{1}{2}\right)$ និង $f(2)$

$f\left(\frac{1}{2}\right) = \frac{1}{4}+\frac{1}{2}-3\ln\frac{1}{2} = 0.75+2.1 = 2.85$

$f(2) = 4+\frac{1}{2}-3\ln 2 = 4.5-2.1 = 2.4$

៣. ក. សង់ក្រាប $C$




ខ. តើសមីការ $f(x)=0$ មានចម្លើយ ឬទេ?

តាមក្រាប $C$ ខាងលើ សមីការ $f(x)=0$ គ្មានចម្លើយទេ

( ព្រោះ $f(x)\geq 1.39$ គ្រប់ $x\in D$ ) ។

**VI** គេមានចំណុច $A(1,2,-3),B(0,5,-1)$ និង $C(3,0,1)$

១. សង់ចំណុច $A,B$ និង $C$




២. គណនាប្រវែង $AB,AC$ និង $BC$

គេមាន $\overrightarrow{AB}=(0-1,5-2,-1+3)=(-1,3,2)$

$\overrightarrow{AC}=(3-1,0-2,1+3)=(2,-2,4)$

$\overrightarrow{BC}=(3-0,0-5,1+1)=(3,-5,2)$

គេបាន $AB=|\overrightarrow{AB}|=\sqrt{(-1)^2+(3)^2+(2)^2}=\sqrt{1+9+4}=\sqrt{14}$ ឯកតាប្រវែង

$AC=|\overrightarrow{AC}|=\sqrt{(2)^2+(-2)^2+(4)^2}=\sqrt{4+4+16}=\sqrt{24}$ ឯកតាប្រវែង

$BC=|\overrightarrow{BC}|=\sqrt{(3)^2+(-5)^2+(2)^2}=\sqrt{9+25+4}=\sqrt{38}$ ឯកតាប្រវែង

ដូចនេះ $\boxed{AB=\sqrt{14}\,,AC=\sqrt{24}\,,BC=\sqrt{38}}$

• ទាញបញ្ជាក់ថាត្រីកោណ $ABC$ ជាត្រីកោណកែងត្រង់ $A$

គេបាន $AB^2 = (\sqrt{14})^2 = 14$

$AC^2 = (\sqrt{24})^2 = 24$

$BC^2 = (\sqrt{38})^2 = 38$

ដោយ $BC^2 = AB^2 + AC^2$ (ច្បាប់ពីតាំ)

ដូចនេះ បញ្ជាក់ថា $ABC$ ជាត្រីកោណកែងត្រង់ $A$ ។

៣. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB} \times \overrightarrow{AC}$

$$\overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ -1 & 3 & 2 \\ 2 & -2 & 4 \end{vmatrix} = \begin{vmatrix} 3 & 2 \\ -2 & 4 \end{vmatrix}\vec{i} - \begin{vmatrix} -1 & 2 \\ 2 & 4 \end{vmatrix}\vec{j} + \begin{vmatrix} -1 & 3 \\ 2 & -2 \end{vmatrix}\vec{k}$$

$$= (12+4)\vec{i} - (-4-4)\vec{j} + (2-6)\vec{k}$$

$$= 16\vec{i} + 8\vec{j} - 4\vec{k}$$

ដូចនេះ: $\boxed{\overrightarrow{AB} \times \overrightarrow{AC} = 16\vec{i} + 8\vec{j} - 4\vec{k}}$

• គណនាផ្ទៃក្រឡាត្រីកោណ $ABC$

តាមរូបមន្ត $S_{\Delta ABC} = \frac{1}{2}|\overrightarrow{AB} \times \overrightarrow{AC}|$

ដោយ $\overrightarrow{AB} \times \overrightarrow{AC} = (16, 8, -4) = 4(4, 2, -1)$

គេបាន $S_{\Delta ABC} = \frac{1}{2} \cdot 4\sqrt{(4)^2 + (2)^2 + (-1)^2} = 2\sqrt{16+4+1} = 2\sqrt{21}$

ដូចនេះ: $\boxed{S_{\Delta ABC} = 2\sqrt{21} \text{ (ឯកតាផ្ទៃ)}}$

• រកសមីការប្លង់ $(ABC)$

ប្លង់ $(ABC)$ កាត់តាមចំណុច $C(3, 0, 1)$ និងមានវ៉ិចទ័រណរម៉ាល់

$\vec{n} = \overrightarrow{AB} \times \overrightarrow{AC} = (16, 8, -4)$ គេបាន:

$(ABC) : a(x - x_o) + b(y - y_o) + c(z - z_o) = 0$

$16(x-3) + 8(y-0) - 4(z-1) = 0$

$16x - 48 + 8y - 4z + 4 = 0$

$16x + 8y - 4z - 44 = 0$

$4x + 2y - z - 11 = 0$

ដូចនេះ: $\boxed{(ABC):\ 4x + 2y - z - 11 = 0}$

៤. គណនាចម្ងាយពីចំណុច $O$ ទៅប្លង់ $(ABC)$

គេមាន $(ABC):\ 4x + 2y - z - 11 = 0$ និងចំណុច $O(0, 0, 0)$

ចម្ងាយពីចំណុច $O$ ទៅប្លង់ $(ABC)$ កំណត់ដោយ

$$D = \frac{|4(0) + 2(0) - (0) - 11|}{\sqrt{(4)^2 + (2)^2 + (-1)^2}} = \frac{|-11|}{\sqrt{16+4+1}}$$

$$= \frac{11}{\sqrt{21}} = \frac{11\sqrt{21}}{21} \text{ (ឯកតាប្រវែង)}$$

ដូចនេះ: $\boxed{D = \frac{11\sqrt{21}}{21} \text{ (ឯកតាប្រវែង)}}$

**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________________

ថ្ងៃខែឆ្នាំកំណើត៖________________

ហត្ថលេខា៖________________

| អក្សរសម្ងាត់ |
|---|

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

____ / 125

# ២

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី

រៀបរៀងដោយ៖ **អ៊ុំ ចាន់ធា**

| អក្សរសម្ងាត់ |
|---|

**I** គណនាលីមីត

ក. $\lim\limits_{x\to -1}\dfrac{\sqrt{2+x}-1}{\sqrt{5+x}-2}$ ខ. $\lim\limits_{x\to 1}\dfrac{x^{100}-2x+1}{x^{50}-2x+1}$ គ. $\lim\limits_{x\to \frac{\pi}{3}}\dfrac{\sin x-\sqrt{3}\cos x}{\sin 3x}$

**II** ក្នុងថង់មួយមានប៊ូលក្រហម 4 ប៊ូលខ្មៅ 3 និងប៊ូលស 1 ។ គេយកប៊ូល 3 ចេញពីក្នុងថង់ព្រមគ្នាដោយ ចៃដន្យ។ រកប្រូបាបដែលគេយកបាន:

ក. ប៊ូលក្រហមពីរយ៉ាងតិច។ ខ. ប៊ូលពីរយ៉ាងតិចមានពណ៌ដូចគ្នា។ គ. ប៊ូលនីមួយៗមានពណ៌ខុសគ្នា។

**III** គេមានចំនួនកុំផ្លិច $z_1=1+i\sqrt{3}$ និង $z_2=6\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)$ ។

ក. សរសេរ $z_1$ ជាទម្រង់ត្រីកោណមាត្រ។ ខ. សរសេរ $z_1\times z_2$ ជាទម្រង់ពីជគណិត។

គ. សរសេរ $z_1\times z_2$ ជាទម្រង់ត្រីកោណមាត្រ។

**IV** គណនាអាំងតេក្រាល:

ក. $I=\int_1^2 (3+x-x^2)\,dx$ ខ. $J=\int_0^{\frac{\pi}{2}} (\cos x+\sin x)^2\,dx$ គ. $K=\int_0^2 \dfrac{x^2+(x+1)^2}{x^2+1}\,dx$

**V** ១. គេមានចំណុច: $A(-2,1,0)$, $B(0,1,1)$, $C(1,2,2)$ និង $D(0,3,-4)$ ក្នុងតម្រុយ $\left(O,\vec{i},\vec{j},\vec{k}\right)$ ។

ក. រកវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC},\overrightarrow{BD},\overrightarrow{CD}$ រួចគណនាប្រវែង $AB, AC, AD, BD, CD$ ។

ខ. ចូរបង្ហាញថា ត្រីកោណ $ABD$ និង $ACD$ កែងត្រង់ $A$ ។

២. គេមានប៉ារ៉ាបូល $(P)$ មួយ មានកំពូលនៅត្រង់ចំណុច $O(0,0)$ និងកំណុំ $F$ ស្ថិតនៅលើអ័ក្សអរដោនេ។

ក. រកសមីការស្តង់ដានៃប៉ារ៉ាបូល $(P)$ បើគេដឹងថាវាកាត់តាមចំណុច $A(2,6)$

ខ. រកតម្លៃនៃ $x_1$ បើ $B\left(x_1,\frac{3}{2}\right)$ ស្ថិតលើប៉ារ៉ាបូល $(P)$ រួចសង់ប៉ារ៉ាបូល $(P)$ ។

**VI** គេមានសមីការឌីផេរ៉ង់ស្យែល $(E)$ : $y'+2y=x^2$ ។

ក. កំណត់អនុគមន៍ពហុធា $g$ មានដឺក្រេទីពីរជាចម្លើយនៃ $(E)$ ។

ខ. បង្ហាញថា អនុគមន៍ $f$ ជាចម្លើយនៃ $(E)$ លុះត្រាតែ $f-g$ ជាចម្លើយនៃសមីការ $(E')$ : $y'+2y=0$ ។ ដោះស្រាយសមីការ $(E')$ : $y'+2y=0$ ។

**VII** គេឱ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=x-2+\dfrac{4}{e^x+1}$ មានខ្សែកោង $C$ ។

១. គណនាលីមីតនៃ $f$ ត្រង់ $-\infty$ និងត្រង់ $+\infty$ ។ សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_1$ ដែលមានសមីការ $(d_1)$ : $y=x-2$ ។

២. ចូរស្រាយបំភ្លឺថា នៅលើ $\mathbb{R}$ គេបានដេរីវេនៃអនុគមន៍ $f$ គឺ $f'(x)=\left(\dfrac{e^x-1}{e^x+1}\right)^2$ ។

សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់តារាងអថេរភាពនៃ $f$ លើ $\mathbb{R}$ ។

៣. បង្ហាញថា បន្ទាត់ $d_2$ ដែលមានសមីការ $y=x+2$ ជាអាស៊ីមតូតទ្រេតទៅនឹងក្រាប $C$ ត្រង់ $-\infty$ ។

សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹង បន្ទាត់ $d_2$ ។ សង់ក្រាប $C$ និងអាស៊ីមតូត $d_1$ និង $d_2$ របស់វា។

# ដំណោះស្រាយ

**I** គណនាលីមីត

ក. $\lim\limits_{x\to -1}\dfrac{\sqrt{2+x}-1}{\sqrt{5+x}-2}$ រាងមិនកំណត់ $\dfrac{0}{0}$

គេបាន $\lim\limits_{x\to -1}\dfrac{\sqrt{2+x}-1}{\sqrt{5+x}-2}=\lim\limits_{x\to -1}\dfrac{\left(\sqrt{2+x}-1\right)\left(\sqrt{2+x}+1\right)\left(\sqrt{5+x}+2\right)}{\left(\sqrt{5+x}-2\right)\left(\sqrt{5+x}+2\right)\left(\sqrt{2+x}+1\right)}$

$$=\lim_{x\to -1}\frac{(2+x-1)\left(\sqrt{5+x}+2\right)}{(5+x-4)\left(\sqrt{2+x}+1\right)}$$

$$=\lim_{x\to -1}\frac{(x+1)\left(\sqrt{5+x}+2\right)}{(x+1)\left(\sqrt{2+x}+1\right)}$$

$$=\lim_{x\to -1}\frac{\sqrt{5+x}+2}{\sqrt{2+x}+1}$$

$$=\frac{\sqrt{5-1}+2}{\sqrt{2-1}+1}$$

$$=\frac{4}{2}$$

$$=2$$

ដូចនេះ $\boxed{\lim\limits_{x\to -1}\dfrac{\sqrt{2+x}-1}{\sqrt{5+x}-2}=2}$ ។

ខ. $\lim\limits_{x\to 1}\dfrac{x^{100}-2x+1}{x^{50}-2x+1}$ រាងមិនកំណត់ $\dfrac{0}{0}$

គេបាន $\lim\limits_{x\to 1}\dfrac{x^{100}-2x+1}{x^{50}-2x+1}=\lim\limits_{x\to 1}\dfrac{x^{100}-x^2+x^2-2x+1}{x^{50}-x^2+x^2-2x+1}$

$$=\lim_{x\to 1}\frac{x^2\left(x^{98}-1\right)+(x-1)^2}{x^2\left(x^{48}-1\right)+(x-1)^2}$$

$$=\lim_{x\to 1}\frac{x^2(x-1)\left(x^{97}+x^{96}+x^{95}+\ldots+x+1\right)+(x-1)^2}{x^2(x-1)\left(x^{47}+x^{46}+x^{45}+\ldots+x+1\right)+(x-1)^2}$$

$$=\lim_{x\to 1}\frac{(x-1)\left[x^2\left(x^{97}+x^{96}+x^{95}+\ldots+x+1\right)+(x-1)\right]}{(x-1)\left[x^2\left(x^{47}+x^{46}+x^{45}+\ldots+x+1\right)+(x-1)\right]}$$

$$=\lim_{x\to 1}\frac{x^2\left(x^{97}+x^{96}+x^{95}+\ldots+x+1\right)+(x-1)}{x^2\left(x^{47}+x^{46}+x^{45}+\ldots+x+1\right)+(x-1)}$$

$$=\frac{1^2(1+1+1+\ldots+1+1)+0}{1^2(1+1+1+\ldots+1+1)+0}$$

$$=\frac{98}{48}$$

$$=\frac{49}{24}$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\dfrac{x^{100}-2x+1}{x^{50}-2x+1}=\dfrac{49}{24}}$ ។

គ. $\lim_{x\to\frac{\pi}{3}}\dfrac{\sin x-\sqrt{3}\cos x}{\sin 3x}$ រាងមិនកំណត់ $\dfrac{0}{0}$

គេបាន $\lim_{x\to\frac{\pi}{3}}\dfrac{\sin x-\sqrt{3}\cos x}{\sin 3x}=\lim_{x\to\frac{\pi}{3}}\dfrac{2\left(\frac{1}{2}\sin x-\frac{\sqrt{3}}{2}\cos x\right)}{\sin 3x}$

$$=\lim_{x\to\frac{\pi}{3}}\frac{2\left(\sin x\cos\frac{\pi}{3}-\sin\frac{\pi}{3}\cos x\right)}{\sin 3x}$$

$$=\lim_{x\to\frac{\pi}{3}}\frac{2\sin\left(x-\frac{\pi}{3}\right)}{\sin 3x}$$

តាង $t=x-\dfrac{\pi}{3}\Rightarrow 3x=\pi+3t$

ពេល $x\to\dfrac{\pi}{3}\Rightarrow t\to 0$

គេបាន $\lim_{x\to\frac{\pi}{3}}\dfrac{2\sin\left(x-\frac{\pi}{3}\right)}{\sin 3x}=\lim_{t\to 0}\dfrac{2\sin t}{\sin(\pi+3t)}$

$$=\lim_{t\to 0}\frac{2\sin t}{-\sin 3t}$$

$$=\lim_{t\to 0}\left(-\frac{2\frac{\sin t}{t}}{3\frac{\sin 3t}{3t}}\right)$$

$$=-\frac{2}{3}$$

ដូចនេះ: $\boxed{\lim_{x\to\frac{\pi}{3}}\dfrac{\sin x-\sqrt{3}\cos x}{\sin 3x}=-\dfrac{2}{3}}$ ។

## II រកប្រូបាបដែលគេយកបាន:

ក. ប៊ូលក្រហមពីរយ៉ាងតិច

តាង $A$: ព្រឹត្តិការណ៍ដែលគេយកបានប៊ូលក្រហមពីរយ៉ាងតិច

ដោយគេយកប៊ូល 3 ព្រមគ្នា ចេញពីក្នុងថង់ដែលមានប៊ូល 8 ដោយចៃដន្យ

គេបាន ចំនួនករណីអាច $n(S)=C(8,3)$

$$=\frac{8\times7\times6}{1\times2\times3}$$

$$=56$$

ម្យ៉ាងទៀត គេយកបានប៊ូលក្រហមពីរយ៉ាងតិច នោះគេអាចយកបានប៊ូលក្រហម 2 ឬ ប៊ូលក្រហម 3

គេបាន ចំនួនករណីស្រប $n(A)=C(4,2)\times C(4,1)+C(4,3)$

$$=\frac{4\times3}{2}\times4+4$$

$$=6\times4+4$$

$$=28$$

នាំឱ្យ $P(A)=\dfrac{n(A)}{n(S)}=\dfrac{28}{56}=\dfrac{1}{2}$

ដូចនេះ: $\boxed{P(A)=\dfrac{1}{2}}$ ។

ខ. ប៊ូលពីរយ៉ាងតិចមានពណ៌ដូចគ្នា

តាង $B$ : ព្រឹត្តិការណ៍ដែលគេយកបានប៊ូលពីរយ៉ាងតិចមានពណ៌ដូចគ្នា

នោះគេអាចយកបាន ប៊ូលក្រហម 2 ឬ ប៊ូលខ្មៅ 2 ឬប៊ូលក្រហមទាំងបី ឬប៊ូលខ្មៅទាំងបី

គេបាន ចំនួនករណីស្រប $n(B) = C(4,2)\times C(4,1)+C(3,2)\times C(5,1)+C(4,3)+C(3,3)$

$$= 6\times 4+3\times 5+4+1$$

$$= 24+15+5$$

$$= 44$$

នាំឱ្យ $P(B) = \dfrac{n(B)}{n(S)} = \dfrac{44}{56} = \dfrac{11}{14}$

ដូចនេះ $\boxed{P(B) = \dfrac{11}{14}}$ ។

គ. ប៊ូលនីមួយៗមានពណ៌ខុសគ្នា

តាង $C$ : ព្រឹត្តិការណ៍ដែលគេយកបានប៊ូលនីមួយៗមានពណ៌ខុសគ្នា

នោះគេអាចយកបាន ប៊ូលក្រហម 1និងប៊ូលខ្មៅ 1និងប៊ូលស 1

គេបាន ចំនួនករណីស្រប $n(C) = C(4,1)\times C(3,1)\times C(1,1)$

$$= 4\times 3\times 1$$

$$= 12$$

នាំឱ្យ $P(C) = \dfrac{n(C)}{n(S)} = \dfrac{12}{56} = \dfrac{3}{14}$

ដូចនេះ $\boxed{P(C) = \dfrac{3}{14}}$ ។

**III** ក. សរសេរ $z_1$ ជាទម្រង់ត្រីកោណមាត្រ

គេមាន $z_1 = 1+i\sqrt{3}$

ម៉ូឌុល $r = \sqrt{a^2+b^2} = \sqrt{1^2+\left(\sqrt{3}\right)^2} = 2$

អាគុយម៉ង់

$$\left.\begin{aligned} \cos\alpha &= \frac{a}{r} = \frac{1}{2} \\ \sin\alpha &= \frac{b}{r} = \frac{\sqrt{3}}{2} \end{aligned}\right| \Rightarrow \alpha = \frac{\pi}{3}$$

គេបាន $z_1 = r(\cos\alpha + i\sin\alpha)$

$$= 2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$$

ដូចនេះ $\boxed{z_1 = 2\left(\cos\dfrac{\pi}{3}+i\sin\dfrac{\pi}{3}\right)}$ ។

ខ. សរសេរ $z_1\times z_2$ ជាទម្រង់ពីជគណិត

គេមាន $z_1 = 1+i\sqrt{3}$

និង $z_2 = 6\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$

$$= 6\left(\frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2}\right)$$

$$= 3\sqrt{2} + 3i\sqrt{2}$$

គេបាន $z_1 \times z_2 = \left(1 + i\sqrt{3}\right)\left(3\sqrt{2} + 3i\sqrt{2}\right)$

$$= 3\sqrt{2} + 3i\sqrt{2} + 3i\sqrt{6} - 3\sqrt{6}$$

$$= 3\left(\sqrt{2} - \sqrt{6}\right) + 3i\left(\sqrt{2} + \sqrt{6}\right)$$

ដូចនេះ $\boxed{z_1 \times z_2 = 3\left(\sqrt{2} - \sqrt{6}\right) + 3i\left(\sqrt{2} + \sqrt{6}\right)}$ ។

គ. សរសេរ $z_1 \times z_2$ ជាទម្រង់ត្រីកោណមាត្រ

គេមាន $z_1 = 2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)$

$z_2 = 6\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)$

គេបាន $z_1 \times z_2 = \left[2\left(\cos\frac{\pi}{3} + i\sin\frac{\pi}{3}\right)\right]\left[6\left(\cos\frac{\pi}{4} + i\sin\frac{\pi}{4}\right)\right]$

$$= 2 \times 6\left[\cos\left(\frac{\pi}{3} + \frac{\pi}{4}\right) + i\sin\left(\frac{\pi}{3} + \frac{\pi}{4}\right)\right]$$

$$= 12\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)$$

ដូចនេះ $\boxed{z_1 \times z_2 = 12\left(\cos\frac{7\pi}{12} + i\sin\frac{7\pi}{12}\right)}$ ។

**IV** គណនាអាំងតេក្រាល:

ក. $I = \int_1^2 (3 + x - x^2)dx$

គេបាន $I = \int_1^2 (3 + x - x^2)dx$

$$= \left[3x + \frac{x^2}{2} - \frac{x^3}{3}\right]_1^2$$

$$= \left(3 \cdot 2 + \frac{2^2}{2} - \frac{2^3}{3}\right) - \left(3 + \frac{1}{2} - \frac{1}{3}\right)$$

$$= 6 + 2 - \frac{8}{3} - 3 - \frac{1}{2} + \frac{1}{3}$$

$$= 5 - \frac{1}{2} - \frac{7}{3}$$

$$= \frac{30 - 3 - 14}{6}$$

$$= \frac{13}{6}$$

ដូចនេះ $\boxed{I = \frac{13}{6}}$ ។

ខ. $J=\int_0^{\frac{\pi}{2}}(\cos x+\sin x)^2dx$

គេបាន $J=\int_0^{\frac{\pi}{2}}(\cos x+\sin x)^2dx$

$=\int_0^{\frac{\pi}{2}}\left(\cos^2x+2\cos x\sin x+\sin^2x\right)dx$

$=\int_0^{\frac{\pi}{2}}(1+2\cos x\sin x)\,dx$

$=\int_0^{\frac{\pi}{2}}dx+2\int_0^{\frac{\pi}{2}}\cos x\sin x dx$

$=\int_0^{\frac{\pi}{2}}dx+2\int_0^{\frac{\pi}{2}}\sin x\cdot d(\sin x)$

$=\left[x+\sin^2x\right]_0^{\frac{\pi}{2}}$

$=\frac{\pi}{2}+1$

ដូចនេះ $\boxed{J=1+\frac{\pi}{2}}$ ។

គ. $K=\int_0^2\frac{x^2+(x+1)^2}{x^2+1}dx$

គេបាន $K=\int_0^2\frac{x^2+(x+1)^2}{x^2+1}dx$

$=\int_0^2\frac{x^2+x^2+2x+1}{x^2+1}dx$

$=\int_0^2\frac{2x^2+2x+1}{x^2+1}dx$

$=\int_0^2\left(2+\frac{2x-1}{x^2+1}\right)dx$

$=\int_0^2 2\,dx+\int_0^2\frac{2x}{x^2+1}dx-\int_0^2\frac{dx}{x^2+1}$

$=[2x]_0^2+\int_0^2\frac{(x^2+1)'}{x^2+1}dx-[\arctan x]_0^2$

$=[2x]_0^2+\left[\ln|x^2+1|\right]_0^2-[\arctan x]_0^2$

$=\left[2x+\ln|x^2+1|-\arctan x\right]_0^2$

$=(4+\ln 5-\arctan 2)-(0+\ln 1-\arctan 0)$

$=4+\ln 5-\arctan 2$

ដូចនេះ $\boxed{K=4+\ln 5-\arctan 2}$ ។

V ១. ក. រកវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC},\overrightarrow{BD},\overrightarrow{CD}$ រួចគណនាប្រវែង $AB, AC, AD, BD, CD$

គេមានចំណុច: $A(-2,1,0)$, $B(0,1,1)$, $C(1,2,2)$ និង $D(0,3,-4)$

គេបានៈ

- $\overrightarrow{AB}=(2,0,1)\Rightarrow AB=\sqrt{2^2+0^2+1^2}=\sqrt{5}$
- $\overrightarrow{AC}=(3,1,2)\Rightarrow AC=\sqrt{3^2+1^2+2^2}=\sqrt{14}$
- $\overrightarrow{AD}=(2,2,-4)\Rightarrow AD=\sqrt{2^2+2^2+(-4)^2}=2\sqrt{6}$
- $\overrightarrow{BD}=(0,2,-5)\Rightarrow BD=\sqrt{0^2+2^2+(-5)^2}=\sqrt{29}$
- $\overrightarrow{CD}=(-1,1,-6)\Rightarrow CD=\sqrt{(-1)^2+1^2+(-6)^2}=\sqrt{38}$

ខ. បង្ហាញថា ត្រីកោណ $ABD$ និង $ACD$ កែងត្រង់ $A$

គេមាន $\overrightarrow{AB}=(2,0,1)$ និង $\overrightarrow{AD}=(2,2,-4)$

គេបាន $\overrightarrow{AB}\cdot\overrightarrow{AD}=(2\times 2)+(0\times 2)+[1\times(-4)]$

$$=4+0-4$$

$$=0$$

ដោយ $\overrightarrow{AB}\cdot\overrightarrow{AD}=0$

គេទាញបាន ត្រីកោណ $ABD$ ជាត្រីកោណកែង កែងត្រង់ $A$ ( ពិត )

ម្យ៉ាងទៀត $\overrightarrow{AC}=(3,1,2)$ និង $\overrightarrow{AD}=(2,2,-4)$

គេបាន $\overrightarrow{AC}\cdot\overrightarrow{AD}=(3\times 2)+(1\times 2)+[2\times(-4)]$

$$=6+2-8$$

$$=0$$

ដោយ $\overrightarrow{AC}\cdot\overrightarrow{AD}=0$

គេទាញបាន ត្រីកោណ $ACD$ ជាត្រីកោណកែង កែងត្រង់ $A$ ( ពិត )

ដូចនេះ បញ្ជាក់ថាត្រីកោណ $ABD$ និង $ACD$ កែងត្រង់ $A$ ។

២. ក. រកសមីការស្តង់ដានៃប៉ារ៉ាបូល $(P)$

ដោយប៉ារ៉ាបូល $P$ មានកំពូល $V(0,0)$ និងកំណុំ $F$ ស្ថិតនៅលើអ័ក្សអរដោនេ

នោះប៉ារ៉ាបូលមាន អ័ក្សឆ្លុះ ស្ថិតលើអ័ក្សអរដោនេ

គេបានសមីការស្តង់ដាមានរាង : $(x-0)^2=4P(y-0)$

តែប៉ារ៉ាបូល $P$ កាត់តាម $A(2,6)$

គេបាន $2^2=4P\times 6$

$$4=24P$$

$$\Rightarrow P=\frac{1}{6}$$

ដូចនេះ សមីការស្តង់ដាគឺ $\boxed{(P):\quad (x-0)^2=\frac{2}{3}(y-0)}$ ។

ខ. ▷ រកតម្លៃនៃ $x_1$

គេមាន $(P):\quad x^2=\frac{4}{6}y$

ដោយ $B\left(x_1,\frac{3}{2}\right)$ ស្ថិតលើ $(P)$

គេបាន ${x_1}^2=\frac{2}{3}\times\frac{3}{2}$

$${x_1}^2=1$$

$$\Rightarrow x_1=\pm 1$$

ដូចនេះ $\boxed{x_1=\pm 1}$ ។

▷ សង់ប៉ារ៉ាបូល $(P)$ :

ប៉ារ៉ាបូល $(P)$ មាន :

- កំពូល $V(0,0)$
- កំណុំ $F(0,0+P)$ នោះ $F\left(,\frac{1}{6}\right)$

- បន្ទាត់ប្រាប់ទិស $(\Delta)$ : $\quad y=0-P$ នោះ $(\Delta)$ : $\quad y=-\dfrac{1}{6}$




**VI** ក. កំណត់អនុគមន៍ពហុធា $g$ មានដឺក្រេទីពីរជាចម្លើយនៃ $(E)$

តាង $g(x)=ax^2+bx+c$ ជាចម្លើយនៃ $(E)$

គេបាន $g'(x)=2ax+b$

ដោយ $g$ ជាចម្លើយនៃ $(E)$ នោះ $g$ ផ្ទៀងផ្ទាត់សមីការ $(E)$

គេបាន
$$g'(x)+2g(x)=x^2$$
$$2ax+b+2\left(ax^2+bx+c\right)=x^2$$
$$2ax+b+2ax^2+2bx+2c=x^2$$
$$2ax^2+(2a+2b)x+(b+2c)=x^2$$

$$\Rightarrow\begin{cases}2a=1\\2a+2b=0\\b+2c=0\end{cases}\Leftrightarrow\begin{cases}a=\dfrac{1}{2}\\b=-\dfrac{1}{2}\\c=\dfrac{1}{4}\end{cases}$$

គេបាន $g(x)=\dfrac{1}{2}x^2-\dfrac{1}{2}x+\dfrac{1}{4}$

ដូចនេះ $\boxed{g(x)=\dfrac{1}{2}x^2-\dfrac{1}{2}x+\dfrac{1}{4}}$ ។

ខ. ▷ បង្ហាញថា អនុគមន៍ $f$ ជាចម្លើយនៃ $(E)$ លុះត្រាតែ $f-g$ ជាចម្លើយនៃសមីការ $(E')$ : $y'+2y=0$

- បើអនុគមន៍ $f$ ជាចម្លើយនៃ $(E)$ នោះ $f-g$ ជាចម្លើយនៃសមីការ $(E')$ : $y'+2y=0$

  គេមាន $(E)$ : $y'+2y=x^2$

  ដោយ $f$ ជាចម្លើយនៃ $(E)$ នោះ $f'(x)+2f(x)=x^2 \quad (1)$

  តែ $g$ ជាចម្លើយនៃ $(E)$ នោះ $g'(x)+2g(x)=x^2 \quad (2)$

  យក $(1)$ ដក $(2)$

  គេបាន $\left(f'(x)+2f(x)\right)-\left(g'(x)+2g(x)\right)=x^2-x^2$
  $$\left(f'(x)-g'(x)\right)+2\left(f(x)-g(x)\right)=0$$
  $$(f-g)'(x)+2(f-g)(x)=0$$ ជាចម្លើយនៃ $(E')$ : $y'+2y=0$ (ពិត) ។

- បើ $f-g$ ជាចម្លើយនៃសមីការ $(E')$ : $y'+2y=0$ នោះ អនុគមន៍ $f$ ជាចម្លើយនៃ $(E)$ : $y'+2y=x^2$

  ដោយ $f-g$ ជាចម្លើយនៃសមីការ $(E')$ : $y'+2y=0$

គេបាន $(f-g)'(x)+2(f-g)(x)=0$

$$f'(x)-g'(x)+2f(x)-2g(x)=0$$

$$f'(x)+2f(x)=g'(x)+2g(x)$$

តែ $g$ ជាចម្លើយនៃ $(E)$ នោះ $g'(x)+2g(x)=x^2$

នាំឱ្យ $f'(x)+2f(x)=x^2$ ជាចម្លើយនៃ $(E)$ (ពិត) ។

ដូចនេះ បញ្ជាក់ថា អនុគមន៍ $f$ ជាចម្លើយនៃ $(E)$ លុះត្រាតែ

$f-g$ ជាចម្លើយនៃសមីការ $(E'):\ y'+2y=0$ ។

▷ ដោះស្រាយសមីការ $(E'):\ y'+2y=0$

មានសមីការសម្គាល់ $r+2=0 \quad \Rightarrow r=-2$

គេបានចម្លើយនៃសមីការ $(E')$ គឺ $y=Ae^{-2x}$ ដែល $A\in\mathbb{R}$

ដូចនេះ ចម្លើយនៃសមីការ $(E')$ គឺ $\boxed{y=Ae^{-2x} \text{ ដែល } A\in\mathbb{R}}$ ។

**VII**

១. • គណនាលីមីតនៃ $f$ ត្រង់ $-\infty$ និងត្រង់ $+\infty$

គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=x-2+\dfrac{4}{e^x+1}$

▷ $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x-2+\dfrac{4}{e^x+1}\right)$

$=-\infty$

▷ $\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty}\left(x-2+\dfrac{4}{e^x+1}\right)$

$=+\infty$

ដូចនេះ $\boxed{\lim\limits_{x\to\mp\infty} f(x)=\mp\infty}$ ។

• សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងបន្ទាត់ $d_1$ ដែលមានសមីការ $(d_1):\ y=x-2$

គេមាន $f(x)=x-2+\dfrac{4}{e^x+1}$ និង $(d_1):\ y=x-2$

តាង $g(x)=f(x)-(d_1)$

$=x-2+\dfrac{4}{e^x+1}-(x-2)$

$=\dfrac{4}{e^x+1}>0\ \forall x\in\mathbb{R}$

ដូចនេះ ក្រាប $C$ ស្ថិតនៅផ្នែកខាងលើនៃបន្ទាត់ $(d_1)$ គ្រប់តម្លៃ $x$ ។

២. • ចូរស្រាយបំភ្លឺថា នៅលើ $\mathbb{R}$ គេបានដេរីវេនៃអនុគមន៍ $f$ គឺ $f'(x)=\left(\dfrac{e^x-1}{e^x+1}\right)^2$

គេមាន $f(x)=x-2+\dfrac{4}{e^x+1}\Rightarrow f'(x)=1-\dfrac{4e^x}{(e^x+1)^2}$

$=\dfrac{(e^x+1)^2-4e^x}{(e^x+1)^2}$

$=\dfrac{(e^x)^2+2e^x+1-4e^x}{(e^x+1)^2}$

$=\dfrac{(e^x)^2-2e^x+1}{(e^x+1)^2}$

$=\dfrac{(e^x-1)^2}{(e^x+1)^2}$

$=\left(\dfrac{e^x-1}{e^x+1}\right)^2$ ពិត

ដូចនេះ នៅលើ $\mathbb{R}$ គេបានដេរីវេនៃអនុគមន៍ $f$ គឺ $f'(x)=\left(\dfrac{e^x-1}{e^x+1}\right)^2$ ។

• សិក្សាអថេរភាពនៃអនុគមន៍ $f$ និងសង់តារាងអថេរភាពនៃ $f$ លើ $\mathbb{R}$

ដោយ $f'(x)=\left(\dfrac{e^x-1}{e^x+1}\right)^2\geq 0\ \forall x\in\mathbb{R}$

– បើ $f'(x)=0 \Leftrightarrow \left(\frac{e^x-1}{e^x+1}\right)^2=0$

$$\frac{e^x-1}{e^x+1}=0\ ,\ e^x+1>0\ \forall x\in\mathbb{R}$$

$$\Rightarrow\ e^x-1=0$$

$$e^x=1$$

$$e^x=e^0$$

$$\Rightarrow\ x=0$$

– បើ $f'(x)>0 \Leftrightarrow \left(\frac{e^x-1}{e^x+1}\right)^2>0$

$$\Rightarrow \left[\begin{array}{l}\frac{e^x-1}{e^x+1}>0\\ \frac{e^x-1}{e^x+1}<0\end{array}\right.$$

$$\Rightarrow \left[\begin{array}{l}x>0\\ x<0\end{array}\right.$$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | 0 | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | + | 0 | + | |

– $f(0)=0-2+\frac{4}{e^0+1}=0$

តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | 0 | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | + | 0 | + | |
| $f(x)$ | $-\infty$ | ↗ | 0 | ↗ | $+\infty$ |

ដូចនេះ

– ចំពោះ $x\in(-\infty,0)$ អនុគមន៍ $f$ កើនពី $-\infty$ ទៅ 0

– ចំពោះ $x=0$ នោះអនុគមន៍ $f$ មានតម្លៃស្មើ 0

– ចំពោះ $x\in(0,+\infty)$ អនុគមន៍ $f$ កើនពី 0 ទៅ $+\infty$ ។

៣. • បង្ហាញថា បន្ទាត់ $d_2$ ដែលមានសមីការ $y=x+2$ ជាអាសុីមតូតទ្រេតទៅនឹងក្រាប $C$ ត្រង់ $-\infty$

គេមាន $f(x)=x-2+\dfrac{4}{e^x+1}$

$=x+2-4+\dfrac{4}{e^x+1}$

$=x+2+\dfrac{4-4e^x-4}{e^x+1}$

$=x+2-\dfrac{4e^x}{e^x+1}$

$=x+2-\dfrac{4}{1+\frac{1}{e^x}}$

ដោយ $\lim\limits_{x\to-\infty}\left(-\dfrac{4}{1+\frac{1}{e^x}}\right)=0$

នាំឱ្យ បន្ទាត់ $y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ត្រង់ $-\infty$

ដូចនេះ បន្ទាត់ $y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ត្រង់ $-\infty$ ។

- សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹង បន្ទាត់ $d_2$

តាង $h(x)=f(x)-(d_2)$

$=x-2+\dfrac{4}{e^x+1}-(x+2)$

$=x-2+\dfrac{4}{e^x+1}-x-2$

$=\dfrac{4}{e^x+1}-4$

$=\dfrac{4-4e^x-4}{e^x+1}$

$=-\dfrac{4e^x}{e^x+1}<0\ \forall x\in\mathbb{R}$

ដូចនេះ ក្រាប $C$ ស្ថិតនៅផ្នែកខាងក្រោមនៃបន្ទាត់ $(d_2)$ គ្រប់តម្លៃ $x$ ។

- សង់ក្រាប $C$ និងអាស៊ីមតូត $d_1$ និង $d_2$ របស់វា

▷ $(d_1)\ :\ y=x-2$

| | | |
|---|---|---|
| $x$ | 0 | 2 |
| $y$ | $-2$ | 0 |

▷ $(d_2)\ :\ y=x+2$

| | | |
|---|---|---|
| $x$ | 0 | $-2$ |
| $y$ | 2 | 0 |



**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________________

ថ្ងៃខែឆ្នាំកំណើត៖________________ អក្សរសម្ងាត់

ហត្ថលេខា៖________________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

$\frac{\quad}{125}$

# ៣

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី

រៀបរៀងដោយ៖ **ម៉ី ចន្ទមករា**

អក្សរសម្ងាត់

**I** គេមានចំនួនកុំផ្លិច $z=\dfrac{\cos\frac{\pi}{4}+i\sin\frac{\pi}{4}}{\sqrt{3}+i}$ ។

ក. សរសេរ $z$ ជាទម្រង់ពិជគណិត។

ខ. សរសេរ $z$ ជាទម្រង់ត្រីកោណមាត្រ រួចទាញតម្លៃប្រាកដនៃ $\cos\dfrac{\pi}{12}$ និង $\sin\dfrac{\pi}{12}$ ។

**II** គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 0}\dfrac{\sqrt{x+3}-\sqrt{3}}{x}$  ខ. $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}$  គ. $\lim\limits_{x\to 0}\dfrac{(e^x-1)(1-\cos 2x)\sin x}{x^4}$

**III** ១. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលដែលមានលក្ខណៈដើម៖ $(E): y''-2y'+3y=0,\ y(0)=2,\ y'(0)=0$ ។

២. រកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែអូម៉ូសែនលំដាប់ទី 2 មានមេគុណថេរដែលមានចម្លើយ $f(x)=(x+2)e^{3x}$ ។

**IV** ក្នុងប្រអប់មួយមានប៊ិកប្រភេទដូចគ្នាចំនួន 20 ដើម ដែលមានពណ៌ខៀវ 14 ដើម និងពណ៌ក្រហម 6 ដើម។ គេយកប៊ិក 5 ដើម ព្រមគ្នាដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តការណ៍៖

ក. យកបានប៊ិកខៀវទាំង 5 ដើម។

ខ. យកបានប៊ិកខៀវ 3 ដើមនិងក្រហម 2 ដើម។

គ. យកបានប៊ិកក្រហម 1 ដើមយ៉ាងតិច។

**V** គណនាអាំងតេក្រាល៖ $I=\displaystyle\int\frac{\cos^3 x}{\sin^4 x}dx$ និង $J=\displaystyle\int_1^e\frac{1+\ln x}{x}dx$

**VI** អនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{1+x^2+2\ln x}{x^2}$ ។ $(C)$ ជាក្រាបនៃ $f$ នៅក្នុងតម្រុយអរតូណរម៉ាល់ $(o,\vec{i},\vec{j})$ ។

១. រកដែនកំណត់នៃអនុគមន៍ $f$ រួចរកលីមីតនៃ $f$ ត្រង់ចុងដែនកំណត់។ ទាញរកសមីការអាស៊ីមតូតនៃក្រាប $(C)$ ។

២. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញាដេរីវេ $f'(x)$ ។ បង្ហាញថាអនុគមន៍ $f(x)$ មានតម្លៃអតិបរមាត្រង់ $x=1$ ។ គណនា $f(1)$។ សង់តារាងអថេរភាពនៃ $f(x)$ ។

៣. បង្ហាញថាក្រាប $(C)$ មានចំណុចរបត់មួយ។គណនាកូអរដោនេចំណុចរបត់នោះ។

(គេយក $\sqrt[3]{e}=1.4$)

៤. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $(C)$ និងអាស៊ីមតូតដេករបស់វា។

៥. សង់ក្រាប $(C)$

**VII** ១. គេឲ្យប៉ារ៉ាបូល $P:\dfrac{1}{4}y^2-x-y+3=0$ ។ សរសេរសមីការស្តង់ដារប៉ារ៉ាបូល រួចទាញរកកូអរដោនេនៃកំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិស។

២. ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(0,\vec{i},\vec{j},\vec{k})$ មួយ គេឲ្យ $A(2,3,0)$ ,$B(0,-3,2)$ និង $C(-2,3,4)$ ។

ក. ចូរសង់ត្រីកោណ $ABC$

ខ. រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{BA}$ និង $\overrightarrow{BC}$ ។បង្ហាញថា $\triangle ABC$ ជាត្រីកោណសមបាត។

# ដំណោះស្រាយ

**I** ចំនួនកុំផ្លិច $z=\dfrac{\cos\frac{\pi}{4}+i\sin\frac{\pi}{4}}{\sqrt{3}+i}$ ។

ក. សរសេរ $z$ ជាទម្រង់ពិជគណិត

គេបាន $z=\dfrac{\cos\frac{\pi}{4}+i\sin\frac{\pi}{4}}{\sqrt{3}+i}=\dfrac{\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2}}{\sqrt{3}+i}$ ;ព្រោះ $\boxed{\cos\frac{\pi}{4}=\frac{\sqrt{2}}{2},\ \sin\frac{\pi}{4}=\frac{\sqrt{2}}{2}}$

$$=\frac{\frac{\sqrt{2}}{2}(1+i)}{\sqrt{3}+i}$$

$$=\frac{\frac{\sqrt{2}}{2}(1+i)(\sqrt{3}-i)}{(\sqrt{3}+i)(\sqrt{3}-i)}$$

$$=\frac{\sqrt{2}}{2}\times\frac{\sqrt{3}-i+i\sqrt{3}+1}{4},\quad (i^2=-1)$$

$$=\frac{\sqrt{6}-i\sqrt{2}+i\sqrt{6}+\sqrt{2}}{8}$$

ដូចនេះ $\boxed{z=\dfrac{\sqrt{6}+\sqrt{2}}{8}+i\dfrac{\sqrt{6}+\sqrt{2}}{8}}$

ខ. សរសេរ $z$ ជាទម្រង់ពិជគណិត

យើងមាន $z=\dfrac{\cos\frac{\pi}{4}+i\sin\frac{\pi}{4}}{\sqrt{3}+i}=\dfrac{\cos\frac{\pi}{4}+i\sin\frac{\pi}{4}}{2\left(\frac{\sqrt{3}}{2}+i\frac{1}{2}\right)}$

$$=\frac{1}{2}\cdot\frac{\cos\frac{\pi}{4}+i\sin\frac{\pi}{4}}{\cos\frac{\pi}{6}+i\sin\frac{\pi}{6}}$$

$$=\frac{1}{2}\left[\cos\left(\frac{\pi}{4}-\frac{\pi}{6}\right)+i\sin\left(\frac{\pi}{4}-\frac{\pi}{6}\right)\right]$$

$$=\frac{1}{2}\left(\cos\frac{\pi}{12}+\sin\frac{\pi}{12}\right)$$

ដូចនេះ $\boxed{z=\dfrac{1}{2}\left(\cos\frac{\pi}{12}+\sin\frac{\pi}{12}\right)}$

+ ទាញរកតម្លៃប្រាកដនៃ $\cos\frac{\pi}{12}$ និង $\cos\frac{\pi}{12}$

ទម្រង់ត្រីកោណមាត្រ $z=\dfrac{1}{2}\left(\cos\frac{\pi}{12}+\sin\frac{\pi}{12}\right)$

ទម្រង់ពិជគណិត $z=\dfrac{1}{2}\cdot\dfrac{\sqrt{6}+\sqrt{2}}{4}+i\dfrac{\sqrt{6}+\sqrt{2}}{4}$

ដូចនេះ $\boxed{\cos\frac{\pi}{12}=\dfrac{\sqrt{6}+\sqrt{2}}{4},\ \sin\frac{\pi}{12}=\dfrac{\sqrt{6}-\sqrt{2}}{4}}$

**II** គណនាលីមីត៖

ក. $\lim\limits_{x\to 0}\dfrac{\sqrt{x+3}-\sqrt{3}}{x}$ រាង $\left(\dfrac{0}{0}\right)$

គេបាន $\lim_{x\to 0}\frac{\sqrt{x+3}-\sqrt{3}}{x}=\lim_{x\to 0}\frac{(\sqrt{x+3}-\sqrt{3})(\sqrt{x+3}+\sqrt{3})}{x(\sqrt{x+3}+\sqrt{3})}$

$a^2-b^2=(a-b)(a+b)$

$$=\lim_{x\to 0}\frac{(x+3-3)}{x(\sqrt{x+3}+\sqrt{3})}$$
$$=\lim_{x\to 0}\frac{x}{x(\sqrt{x+3}+\sqrt{3})}$$
$$=\lim_{x\to 0}\frac{1}{(\sqrt{x+3}+\sqrt{3})}$$
$$=\frac{1}{2\sqrt{3}}$$
$$=\frac{\sqrt{3}}{6}$$

ដូចនេះ $\boxed{\lim_{x\to 0}\frac{\sqrt{x+3}-\sqrt{3}}{x}=\frac{\sqrt{3}}{6}}$

ខ. $\lim_{x\to\frac{\pi}{2}}\frac{\pi-2x}{\cos x}$ រាង $\frac{0}{0}$

$\sin(\frac{\pi}{2}-\theta)=\cos\theta$

គេបាន $\lim_{x\to\frac{\pi}{2}}\frac{\pi-2x}{\cos x}=\lim_{x\to\frac{\pi}{2}}\frac{2\left(\frac{\pi}{2}-x\right)}{\sin\left(\frac{\pi}{2}-x\right)}$

តាង $t=\frac{\pi}{2}-x$

ដោយ $x\to\frac{\pi}{2}$ នោះ $t\to 0$

យើងបាន $\lim_{t\to 0}\frac{2t}{\sin t}=\lim_{t\to 0}\frac{\frac{2t}{t}}{\frac{\sin t}{t}}=\frac{2}{1}=2$

ដូចនេះ $\boxed{\lim_{x\to\frac{\pi}{2}}\frac{\pi-2x}{\cos x}=2}$

គ. $\lim_{x\to 0}\frac{(e^x-1)(1-\cos 2x)\sin x}{x^4}$ រាង $\frac{0}{0}$

$1-\cos 2x=2\sin^2 x$

គេបាន $\lim_{x\to 0}\frac{(e^x-1)(1-\cos 2x)\sin x}{x^4}=\lim_{x\to 0}\frac{(e^x-1)(2\sin^2 x)\sin x}{x^4}$

$$=\lim_{x\to 0}\frac{(e^x-1)}{x}\cdot\frac{2\sin^2 x}{x^2}\cdot\frac{\sin x}{x}$$

$$=1\times 2\times 1$$ ព្រោះ $\boxed{\lim_{x\to 0}\frac{(e^x-1)}{x}=1,\lim_{x\to 0}\frac{\sin x}{x}=1}$

$$=2$$

**III** ១. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលដែលមានលក្ខណៈដើម៖

$(E): y''-2y'+3y=0,\ y(0)=2,\ y'(0)=0$

សមីការសម្គាល់ $\lambda^2-2\lambda+3=0$

យើងបាន $\Delta'=(-1)^2-1\cdot 3=-2<0$

ឫស $\lambda_{1,2}=\frac{-b'\pm\sqrt{\Delta'}}{a}=1\pm i\sqrt{2}$

$\Rightarrow(\alpha=1,\beta=\sqrt{2})$

ចម្លើយទូទៅ $y=(A\cos\beta x+B\sin\beta x)e^{\alpha x}=(A\cos\sqrt{2}x+B\sin\sqrt{2}x)e^x\quad ,A,B\in\mathbb{R}$

$\Rightarrow y'=(-A\sqrt{2}\sin\sqrt{2}x+B\sqrt{2}\cos\sqrt{2}x)e^x+e^x(A\cos\sqrt{2}x+B\sin\sqrt{2}x)$

$= e^x[(B-A\sqrt{2})\sin\sqrt{2}x + (B\sqrt{2}+A)\cos\sqrt{2}x]$

ដោយ $\begin{cases} y(0) &= 2 \\ y'(0) &= 0 \end{cases}$ និង $\begin{cases} \sin 0 &= 0 \\ \cos 0 &= 1 \\ e^0 &= 1 \end{cases}$

$\Rightarrow \begin{cases} A+0 &= 2 \\ 0+(B\sqrt{2}+A) &= 0 \end{cases}$ គេបាន $\begin{cases} A &= 2 \\ B &= -\sqrt{2} \end{cases}$

ដូចនេះ $\boxed{y = (2\cos\sqrt{2}x - \sqrt{2}\sin\sqrt{2}x)e^x}$

២. រកសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែអូម៉ូសែនលំដាប់ទី២ មានគុណថេរ $(E): y'' + by' + cy = 0$

ដែលមានចម្លើយ $f(x) = (x+2)e^{3x}$

• $f'(x) = e^{3x} + 3e^{3x}(x+2)$

$= e^{3x}(3x+7)$

• $f''(x) = 3e^{3x}(3x+7) + 3e^{3x}$

$= e^{3x}(9x+24)$

យក $f''(x), f'(x)$ និង $f(x)$ ជំនួសក្នុងសមីការ $(E)$

យើងបាន $e^{3x}(9x+24) + be^{3x}(3x+7) + c(x+2)e^{3x} = 0$

$e^{3x}(9x+24+3bx+7b+cx+2c) = 0$

$(9+3b+c)x + (24+7b+2c) = \frac{0}{e^{3x}} = 0$

$\Longrightarrow \begin{cases} 9+3b+c &= 0 \quad (1) \\ 24+7b+2c &= 0 \quad (2) \end{cases}$

•$(1) \Rightarrow c = -9-3b \quad (3)$

• យក (3)ជំនួសក្នុង (2)

$24+7b+18-6b = 0$

$6+b = 0$

$b = -6$

• ជួសក្នុង (3)

$\Rightarrow c = -9-3(-6) = 9$

ដូចនេះ $\boxed{(E): y'' - 6y' + 9y = 0}$

**IV** ក្នុងប្រអប់មានប៊ិកសរុប 20 ដើម ក្នុងនោះខៀវ 14 ដើម និងក្រហម 6 ដើម គេចាប់យក 5 ដើមដោយចៃដន្យ

នោះចំនួនករណីអាចគឺ $n(s) = c(20,5) = \frac{20!}{(20-5)!5!} = \frac{20\times19\times18\times17\times16}{5\times4\times3\times2\times1} = 15540$ ករណី

ក. រកប្រូបាបនៃព្រឹត្តិការណ៍យកបានប៊ិកខៀវទាំង 5 ដើម

តាង $A$ ជាព្រឹត្តិការណ៍យកបានប៊ិកខៀវទាំង 5 ដើម

នោះ $n(A) = C(14,5) = \frac{14!}{(14-5)!5!} = 2002$ ករណី

យើងបាន $P(A) = \frac{2002}{15540} = 0.1291$

ដូចនេះ $\boxed{P(A) = 0.1291}$

ខ. យកបានប៊ិកខៀវ 3 ដើមនិងក្រហម 2 ដើម

តាង $B$ ជាប្រូបាបយកបានប៊ិកខៀវ 3 ដើមនិងក្រហម 2 ដើម

នោះ $n(B) = C(14,3) \times C(6,2) = \dfrac{14!}{(14-3)!3!} \times \dfrac{6!}{(6-2)!2!} = 5460$ ករណី

យើងបាន $P(B) = \dfrac{5460}{15540} = 0.3521$

ដូចនេះ $\boxed{P(A) = 0.3521}$

គ. យកបានប៊ិកក្រហម 1 ដើមយ៉ាងតិច

តាង $C$ ជាប្រូបាបយកបានប៊ិកក្រហម 1 ដើមយ៉ាងតិច

$C$ ជាព្រឹត្តិការណ៍ប្រាស់នៃព្រឹត្តិការណ៍ $A$

យើងបាន $P(C) = 1 - P(A) = 1 - 0.1291 = 0.8709$

ដូចនេះ $\boxed{P(A) = 0.8709}$

**V** គណនាអាំងតេក្រាល

$$I = \int \frac{\cos^3 x}{\sin^4 x} dx$$
$$= \int \frac{\cos^2 x}{\sin^4 x} \cos x dx$$
$$= \int \frac{1-\sin^2 x}{\sin^4 x} \cos x dx$$

តាង $u = \sin x \Rightarrow du = \cos x dx$

យើងបាន $I = \displaystyle\int \frac{1-u^2}{u^4} du$

$$= \int \left( \frac{1}{u^4} - \frac{u^2}{u^4} du \right)$$
$$= \frac{-1}{3u^3} - \frac{-1}{u} + C$$
$$= \frac{-1}{3\sin^3 x} - \frac{-1}{\sin x} + C$$

ដូចនេះ $\boxed{I = \dfrac{1}{\sin x} - \dfrac{1}{3\sin^3 x} + C, (C \in \Re)}$

$$J=\int_1^e \frac{1-\ln x}{x}dx$$
$$=\int_1^e\left(\frac{1}{x}+\frac{1}{x}\ln x\right)dx$$
$$=\int_1^e\left[\frac{1}{x}+(\ln x)'\ln x\right]dx$$
$$=\left[\ln x+\frac{\ln^2 x}{2}\right]_1^e$$
$$=\left(\ln e+\frac{\ln^2 e}{2}\right)-\left(\ln 1+\frac{\ln^2 1}{2}\right)$$
$$=\left(1+\frac{1}{2}\right)-(0+0)=\frac{3}{2}$$

ដូចនេះ $\boxed{J=\frac{3}{2}}$

**VI** អនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{1+x^2+2\ln x}{x^2}$

១. រកដែនកំណត់នៃអនុគមន៍ $f$

អនុគមន៍ $f$ មានន័យលុះត្រាតែ $\begin{cases} x & >0 \\ x^2 & \neq 0 \end{cases} \Leftrightarrow x>0$

ដូចនេះ $\boxed{D=(0,+\infty)}$

$+$ រកលីមីតនៃ $f$ត្រង់ $0^+$ និង $+\infty$

- $\lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\dfrac{1+x^2+2\ln x}{x^2}=-\infty$
- $\lim\limits_{x\to +\infty} f(x)=\lim\limits_{x\to +\infty}\dfrac{1+x^2+2\ln x}{x^2}$

$$=\lim_{x\to +\infty}\left(\frac{1}{x^2}+1+2\frac{\ln x}{x^2}\right)$$
$$=0+1+2\cdot 0$$
$$=1$$

$+$ ទាញរកអាស៊ីមតូតនៃក្រាប $(C)$

- ដោយ $\lim\limits_{x\to 0^+} f(x)=-\infty$

ដូចនេះ $\boxed{\text{បន្ទាត់ } x=0 \text{ ជាអាស៊ីមតូតឈរនៃក្រាប } (C)}$

- ដោយ $\lim\limits_{x\to +\infty} f(x)=1$

ដូចនេះ $\boxed{\text{បន្ទាត់ y=1 ជាអាស៊ីមតូតដេកនៃក្រាប } (C)}$

២. គណនាដេរីវេ $f'(x)$

$$\bullet\ f'(x)=\frac{\left(2x+\dfrac{2}{x}\right)\cdot x^2-2x\left(1+x^2+2\ln x\right)}{x^4}$$
$$=\frac{2x^3+2x-2x-2x^3-4x\ln x}{x^4}$$
$$=\frac{-4x\ln x}{x^4}$$

ដូចនេះ $\boxed{f'(x)=\dfrac{-4x\ln x}{x^4}}$

+ សញ្ញានៃ $f'(x)$ យកតាម $(-\ln x)$

$\bullet(-\ln x)=0\Leftrightarrow \ln x=0\Leftrightarrow x=e^0=1$

$\bullet(-\ln x)>0\Leftrightarrow \ln x<0\Leftrightarrow x<e^0=1$

$\bullet(-\ln x)<0\Leftrightarrow \ln x>0\Leftrightarrow x>e^0=1$

+ តារាងសញ្ញាដេរីវេ $f'(x)$

| $x$ | $0$ $\qquad$ $1$ $\qquad$ $+\infty$ |
|---|---|
| $f'(x)$ | ‖ $\quad +\quad 0\quad -$ |

ត្រង់$x=1$ នោះ $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$

ដូចនេះ $\boxed{\text{អនុគមន៍ } f \text{ មានអតិបរមាត្រង់ } x=1}$

+ គណនា $f(1)$

$\bullet f(1)=\dfrac{1+1+2\ln 1}{1}=\dfrac{1+1+0}{1}=2$

+ តារាងអថេរភាព

| $x$ | $0$ $\qquad$ $1$ $\qquad$ $+\infty$ |
|---|---|
| $f'(x)$ | ‖ $\quad +\quad 0\quad -$ |
| $f(x)$ | ‖ $-\infty\ \nearrow\ 2\ \searrow\ 1$ |

៣. បង្ហាញថាក្រាប $(C)$ មានចំណុចរបត់មួយ

$\bullet$ ដេរីវេទី១: $f'(x)=\dfrac{-4\ln x}{x^3}$

• ដេរីវេទី២: $f''(x) = -4\dfrac{\frac{1}{x}\cdot x^3 - 3x^2\ln x}{x^6}$

$$= -4\frac{x^2 - 3x^2\ln x}{x^6}$$

$$= \frac{-4x^2(1-3\ln x)}{x^6}$$

$$= \frac{(3\ln x - 1)}{x^4}$$

+ សញ្ញានៃ $f''(x)$ យកតាម $(3\ln x - 1)$

•$3\ln x - 1 = 0 \Leftrightarrow \ln x = \dfrac{1}{3} \Leftrightarrow x = e^{\frac{1}{3}} = \sqrt[3]{e}$

•$3\ln x - 1 > 0 \Leftrightarrow \ln x > \dfrac{1}{3} \Leftrightarrow x > \sqrt[3]{e}$

•$3\ln x - 1 < 0 \Leftrightarrow \ln x < \dfrac{1}{3} \Leftrightarrow x < \sqrt[3]{e}$

តារាងសិក្សាសញ្ញា $f''(x)$

| $x$ | $0$ | | $\sqrt[3]{e}$ | | $+\infty$ |
|---|---|---|---|---|---|
| $f''(x)$ | ‖ | $-$ | $0$ | $+$ | |

• ត្រង់ $x = \sqrt[3]{e}$ នោះ $f''(x) = 0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$

ដូចនេះ: ក្រាប $(C)$ មានចំណុចរបត់មួយត្រង់ $x = \sqrt[3]{e}$

+ រកកូអរដោនេចំណុចរបត់

• $f(\sqrt[3]{e}) = \dfrac{1 + (\sqrt[3]{e}) + 2\ln e^{\frac{1}{3}}}{(\sqrt[3]{e})^2}$

$$= \frac{1 + (1.4)^2 + 2\cdot\frac{1}{3}}{(1.4)^2}$$

$$= 1.85$$

ដូចនេះ: ចំណុចរបត់គឺ $I(1.4, 1.85)$

៤. រកកូអរដោនេចំណុចប្រសព្វរវាងក្រាប $(C)$ និងអាស៊ីមតូតដេក

សមីការអាប់ស៊ីសចំណុចប្រសព្វគឺ

$$\frac{1 + x^2 + 2\ln x}{x^2} = 1$$

$$1 + x^2 + 2\ln x = x^2$$

$$\ln x = -\frac{1}{2}$$

$$x = e^{\frac{-1}{2}} = \frac{1}{\sqrt{e}} = 0.6$$

ដូចនេះ: ចំណុចរបត់គឺ $I(0.6, 1)$

៥. ក្រាប




**VII**

១. ប៉ារ៉ាបូល $(P): \frac{1}{4}y^2 - x^2 - y + 3 = 0$

សរសេរសមីការស្តង់ដារ ទាញរកកូអរដោនេនៃកំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិស

$P: \frac{1}{4}y^2 - x - y + 3 = 0$

$$y^2 - 4x - 4y + 12 = 0$$

$$y^2 - 4y = 4x - 12$$

$$y^2 - 4y + 2^2 = 4x - 12 + 2^2$$

$$(y-2)^2 = 4x - 8$$

ដូចនេះសមីការស្តង់ដារប៉ារ៉ាបូល $\boxed{P: (y-2)^2 = 4x - 8}$ មានអ័ក្សឆ្លុះដេក

យើងទាញបាន $\begin{cases} k = 2, h = 2 \\ 4p = 4 \Rightarrow p = 1 \end{cases}$

- កំពូល $V(h,k) \Rightarrow V(2,2)$
- កំណុំ $F(h+p,k) \Rightarrow F(3,2)$
- សមីការបន្ទាត់ប្រាប់ទិស $x = h - p = 1$

២. ក. សង់ត្រីកោណ $ABC$




ខ. កូអរដោនេនៃវ៉ិចទ័រ $\overrightarrow{BA},\overrightarrow{BC}$ ។ បង្ហាញថា $\Delta ABC$ ជាត្រីកោណសមបាត

$\overrightarrow{BA}=(2-0,3-3,0-2)=(2,0,2)$

$\overrightarrow{BC}=(-2-0,3+3,4-2)=(-2,6,2)$

បង្ហាញថា $\Delta ABC$ ជាត្រីកោណសមបាត

$\bullet BA=|\overrightarrow{BA}|=\sqrt{2^2+6^2+(-2)^2}=\sqrt{44}=2\sqrt{11}$

$\bullet BC=|\overrightarrow{BC}|=\sqrt{(-2)^2+6^2+2}=\sqrt{44}=2\sqrt{11}$

យើងបាន $BA=BC=2\sqrt{11}$

ដូចនេះ $\Delta ABC$ ជាត្រីកោណសមបាតដែលមានបាត $[AC]$ ។

**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖____________________ មណ្ឌលប្រឡង៖____________________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖____________________

ថ្ងៃខែឆ្នាំកំណើត៖____________________

ហត្ថលេខា៖____________________

| អក្សរសម្ងាត់ |
|---|

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាល់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

✂ - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

____ / 125

**៤**

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី

រៀបរៀងដោយ៖ **ជិក ជី**

| អក្សរសម្ងាត់ |
|---|

**I** គណនាលីមីតខាងក្រោម :

ក. $\lim\limits_{x\to 0}\dfrac{2021x-\sin 2023x}{2020x+\sin 2025x}$ ខ. $\lim\limits_{x\to 2}\dfrac{5x^2-20}{\sqrt[3]{3x+2}-2}$ គ. $\lim\limits_{x\to 0}\dfrac{e^{2021x}-e^{-2021x}}{\sin 2x}$

**II** ក្នុងថង់មួយមានឃ្លីពណ៌មានឃ្លីពណ៌សចំនួន2 ឃ្លីពណ៌ក្រហមចំនួន4 និងឃ្លីពណ៌ខៀវចំនួន 4 ។ គេចាប់យកឃ្លីចំនួន 3 ព្រមគ្នាដោយចៃដន្យ ។ រកប្រូបាបនៃព្រឹត្តិការណ៍ :

A ឃ្លីទាំង 3 មានពណ៌ក្រហម ។ B យ៉ាងតិចមានឃ្លី 2 មានពណ៌ខៀវ ។

C ឃ្លីទាំង 3 មានពណ៌ខុសៗគ្នា ។

**III** គេមានចំនួនកុំផ្លិច $z_1=3+3i\sqrt{3}$ និង $z_2=\sqrt{3}+i$ ។

ក. គណនា $z_1\times z_2$ និង $\dfrac{z_1}{z_2}$ ។ ខ. សរសេរ $z_1\times z_2$ និង $\left(\dfrac{z_1}{z_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ ។

គ. សរសេរ $\left(\dfrac{z_1}{z_2}\right)^3$ ជាទម្រង់ពីជគណិត ។

**IV** គណនាអាំងតេក្រាល ៖ $I=\int_1^2(2-x+3x^2)dx$ $J=\int_0^{\frac{\pi}{4}}(\cos 2x-\dfrac{1}{2}\cos 4x)dx$

និង $K=\int_2^3(3x-2+\dfrac{1}{x-1})dx$ ។

**V** ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $E: y''-y'+2y=0$ ។

ខ. រកចម្លើយនៃ $E$ បើគេដឹងថាអនុគមន៍ចម្លើយមានបរមារស្មើ 3 ត្រង់ $x=0$ ។

**VI** ១. គេមានសមីការ $(E): 9x^2+4y^2+18x-24y+9=0$ ។

ក. បង្ហាញថាសមីការនេះជាសមីការអេលីប ។

ខ. រកប្រវែងអ័ក្សធំ ប្រវែងអ័ក្សតូច កូអរដោនេផ្ចិត កំពូល កំណុំ រួចសង់អេលីបនេះ ។

២. គេមានបីចំណុច $A(-1;1;2);B(0;2;4)$ និង $C(-1;3;1)$ ។

ក. គណនាផលគុណនៃពីរវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ ។ រួចទាញបញ្ជាក់ថា ចំណុច $A;B$ និង $C$ រត់មិនត្រង់គ្នា

ខ. ចូររកផ្ទៃក្រឡាត្រីកោណ $ABC$ ។

**VII** គេមានអនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $f(x)=\dfrac{4e^x}{e^x+1}$ ។ គេតាងដោយ $C$ ក្រាបរបស់អនុគមន៍នៅក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ក. គណនា $\lim\limits_{x\to-\infty}f(x)$និង $\lim\limits_{x\to+\infty}f(x)$ ។ ទាញរកសមីការអាស៊ីមតូតនៃក្រាប $C$ ។

ខ. សិក្សាអថេរភាពនៃ $f$ ។ រកកូអរដោនេនៃចំណុច $A$ ជាប្រសព្វរវាងក្រាប $C$ និងអ័ក្សអរដោនេ រួចបង្ហាញថាចំណុច $A$ ជាផ្ចិតឆ្លុះនៃក្រាប $C$ ។

គ. រកសមីការបន្ទាត់ $T$ ប៉ះនឹងក្រាប $C$ ត្រង់ណុច $A$ ។

ឃ. សង់ក្រាប $C$ និងបន្ទាត់ $T$ នៅក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j})$ ។

ង. គណនាផ្ទៃក្រឡាខណ្ឌដោយក្រាប $C$ និងអ័ក្ស $(x'ox)$ លើចន្លោះ $[o,1]$ ។

# ដំណោះស្រាយ

**I** គណនាលីមីត

ក $\lim_{x\to 0}\dfrac{2021x-\sin 2023x}{2020x+\sin 2025x}$ រាង $\dfrac{0}{0}$

គេបាន $\lim_{x\to 0}\dfrac{2021x-\sin 2023x}{2020x+\sin 2025x}=\lim_{x\to 0}\dfrac{\frac{2021x-\sin 2023x}{x}}{\frac{2020x+\sin 2025x}{x}}$

$=\lim_{x\to 0}\dfrac{2021-\frac{\sin 2023x}{x}}{2020+\frac{\sin 2025x}{x}}$

$=\dfrac{2021-2023}{2020+2025}=\dfrac{-2}{4045}$

ដូចនេះ $\boxed{\lim_{x\to 0}\dfrac{2021x-\sin 2023x}{2020x+\sin 2025x}=-\dfrac{2}{4045}}$

ក $\lim_{x\to 2}\dfrac{5x^2-20}{\sqrt[3]{3x+2}-2}$ រាង $\dfrac{0}{0}$

គេបាន $\lim_{x\to 2}\dfrac{5x^2-20}{\sqrt[3]{3x+2}-2}=\lim_{x\to 2}\dfrac{5(x^2-4)(\sqrt[3]{(3x+2)^2}+2\sqrt[2]{3x+2}+4}{3x+2-8}$

$=\lim_{x\to 2}\dfrac{5(x+2)(x-2)(\sqrt[3]{(3x+2)^2}+2\sqrt[2]{3x+2}+4)}{3x-6}$

$=\lim_{x\to 0}\dfrac{5(x+2)(x-2)(\sqrt[3]{(3x+2)^2}+2\sqrt[2]{3x+2}+4)}{3(x-2)}$

$=\lim_{x\to 0}\dfrac{5(x+2)(\sqrt[3]{(3x+2)^2}+2\sqrt[2]{3x+2}+4)}{3}$

$=\dfrac{5(2+2)(\sqrt[3]{(6+2)^2}+2\sqrt[3]{6+2}+4)}{3}$

$=\dfrac{20(2^2+2\times 2+4)}{3}=\dfrac{20\times 12}{3}$

$=20\times 4=80$

ដូចនេះ $\boxed{\lim_{x\to 2}\dfrac{5x^2-20}{\sqrt[3]{3x+2}-2}=80}$

ក $\lim_{x\to 0}\dfrac{e^{2021}-e^{-2021x}}{2x}$ រាង $\dfrac{0}{0}$

គេបាន $\lim_{x\to 0}\dfrac{e^{2021}-e^{-2021x}}{2x}=\lim_{x\to 0}\dfrac{e^{2021x}-1+1-e^{-20212}}{2x}$

$=\lim_{x\to 0}(\dfrac{e^{2021x}-1}{2x}-\dfrac{e^{-2021x}-1}{2x})$

$=\dfrac{2021}{2}-\dfrac{-2021}{2}=\dfrac{4042}{2}=2021$

ដូចនេះ $\boxed{\lim_{x\to 0}\dfrac{e^{2021}-e^{-2021x}}{2x}=2021}$

**II** រកប្រូបាបនៃព្រឹត្តិការណ៍ :

បម្រាប់ ៖ ឃ្លីស 2 ឃ្លីក្រហម 4 និងឃ្លីខៀវ 4 នោះឃ្លីសរុប $=10$

ក្នុងការចាប់យកឃ្លី 3 ចេញពីថង់ គេបាន

ចំនួនករណីអាច $n(S)=C(10,3)=\dfrac{10!}{(10-3)!\times 3!}=\dfrac{10\times 9\times 8\times 7!}{7!\times 3\times 2\times 1}=120$ ករណី

A ឃ្លីទាំង 3 មានពណ៌ក្រហម :

តាមរូបមន្ត $P(A)=\dfrac{n(A)}{nS}$

ដោយ $n(A)=C(4,1)=4$ ករណី

$\Rightarrow P(A)=\frac{4}{120}=\frac{1}{30}$

ដូចនេះ $\boxed{P(A)=\frac{1}{30}}$

B យ៉ាងតិចមានឃ្លី 2 ពណ៌ខៀវ :

តាម $P(B)=\frac{n(B)}{n(S)}$

ដោយ $n(B)=C(4,2)\times C(6,1)+C(4,3)=\frac{4!}{(4-2)!\times 2!}+\frac{4!}{(4-3)!\times 3!}$

$=\frac{4\cdot 3}{2\cdot 1}+\frac{4}{1}=10$ ករណី

$\Rightarrow P(B)=\frac{10}{120}=\frac{1}{12}$

ដូចនេះ $\boxed{P(B)=\frac{1}{12}}$

C ឃ្លីទាំង 3 មានពណ៌ខុសគ្នា :

តាម $P(C)=\frac{n(C)}{n(S)}$

ដោយ $n(C)=C(2,1)\cdot C(4,1)\cdot C(4,1)=2\cdot 4\cdot 4=32$ ករណី

$\Rightarrow P(C)=\frac{32}{120}=\frac{4}{15}$

ដូចនេះ $\boxed{P(C)=\frac{4}{15}}$

**III** គេមាន $z_1=3+3i\sqrt{3}$ និង $z_2=\sqrt{3}+i$

ក គណនា $z_1\times z_2$ និង $\frac{z_1}{z_2}$

គេបាន $z_1\times z_2=(3+3i\sqrt{3})(\sqrt{3}+i)$

$=3\sqrt{3}+3i+3i\sqrt{3^2}-3\sqrt{3}$

$=3i+9i=12i$

$\frac{z_1}{z_2}=\frac{3+3i\sqrt{3}}{\sqrt{3}+i}$

$=\frac{(3+3i\sqrt{3})(\sqrt{3}-i)}{(\sqrt{3}+i)(\sqrt{3}-i)}$

$=\frac{3\sqrt{3}-3i+3i\sqrt{3^2}+3\sqrt{3}}{3-1}$

$=\frac{6\sqrt{3}+6i}{2}=3\sqrt{3}+3i$

ដូចនេះ $\boxed{\begin{array}{l} z_1\times z_2=12i \\ \frac{z_1}{z_2}=3\sqrt{3}+3i \end{array}}$

ក សរសេរ $z_1\times z_2$ និង $\left(\frac{z_1}{z_2}\right)^2$ ជាទម្រង់ត្រីកោណមាត្រ

គេបាន $z_1 \times z_2 = 12i = 12(0+i) = 12(\cos\frac{\pi}{2} + i\sin\frac{\pi}{2})$

$$\frac{z_1}{z_2} = 3\sqrt{3} + 3i$$

$$= 3(\sqrt{3}+i) = 3\times 2(\frac{\sqrt{3}}{2} + i\frac{1}{2})$$

$$= 6(\cos\frac{\pi}{6} + i\sin\frac{\pi}{6})$$

$$\Rightarrow \left(\frac{z_1}{z_2}\right)^2 = [6(\cos\frac{\pi}{6} + i\sin\frac{\pi}{6})]^2$$

$$= 36(\cos\frac{2\pi}{6} + i\sin\frac{2\pi}{6})$$

$$= 36(\cos\frac{\pi}{3} + i\sin\frac{\pi}{3})$$

ដូចនេះ: $\boxed{z_1 \times z_2 = 12(\cos\frac{\pi}{2} + i\sin\frac{\pi}{2}) \quad \left(\frac{z_1}{z_2}\right)^2 = 36(\cos\frac{\pi}{3} + i\sin\frac{\pi}{3})}$

ក សរសេរ $\left(\frac{z_1}{z_2}\right)^3$ ជាទម្រង់ពីជគណិត

ដោយ $\left(\frac{z_1}{z_2}\right) = 6(\cos\frac{\pi}{6} + i\sin\frac{\pi}{6})$

$$\Rightarrow \left(\frac{z_1}{z_2}\right)^3 = [6(\cos\frac{\pi}{6} + i\sin\frac{\pi}{6})]^3$$

$$= 6^3(\cos\frac{3\pi}{6} + i\sin\frac{3\pi}{6})$$

$$= 216(\cos\frac{\pi}{2} + i\sin\frac{\pi}{2})$$

$$= 216(0+i)$$

ដូចនេះ: $\boxed{0+216i}$

**IV** គណនាអាំងតេក្រាល ៖

- $I = \int_1^2 (2-x+3x^2)dx = \left[2x - \frac{x^2}{2} + \frac{3x^3}{3}\right]_1^2$

$$= \left[2(2) - \frac{2^2}{2} + 2^3\right] - \left[2(1) - \frac{1^2}{2} + 1^3\right]$$

$$= (4-2+8) - (2+\frac{1}{2})$$

$$= 10 - \frac{5}{2} = \frac{20-5}{2} = \frac{15}{2}$$

ដូចនេះ: $\boxed{I = \frac{15}{2}}$

- $J = \int_0^{\frac{\pi}{4}} (\cos 2x - \frac{1}{2}\cos 4x)dx = \left[\frac{\sin 2x}{2} - \frac{1}{8}\sin 4x\right]_0^{\frac{\pi}{4}}$

$$= \left[\frac{\sin\frac{\pi}{2}}{2} - \frac{1}{8}\sin\pi\right] - \left[\frac{\sin 0}{2} - \frac{1}{8}\sin 0\right] = (\frac{1}{2} - 0) - (0-0) = \frac{1}{2}$$

ដូចនេះ: $\boxed{J = \frac{1}{2}}$

- $K=\int_2^3 (3x-2+\frac{1}{x-1})dx=\left[\frac{3x^2}{2}-2x+\ln|x-1|\right]_2^3$

  $=(\frac{3\times 3^2}{2}-2\times 3+\ln|3-1|)-(\frac{3\times 2^2}{2}-2\times 2+\ln|2-1|)$

  $=\frac{27}{2}-6+\ln 2-6+4+\ln 1=\frac{27-12}{2}+\ln 2=\frac{15}{2}+\ln 2$

  ដូចនេះ $\boxed{K=\frac{15}{2}+\ln 2}$

**V** ក ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

យើងមានសមីការ $E: y''-y'+2y=0$

មានសមីការសម្គាល់ : $r^2-r+2=0$

$(r-2)(r-1)=0$

គេបាន $r_1=-1, r_2=2$

ចម្លើយទូទៅនៃ $E$ គឺ $y=Ae^{r_1x}+Be^{r_2x}$ , $(A,B\in\mathbb{R})$

ដូចនេះ $\boxed{y=Ae^{-x}+Be^{2x} \text{ ជាចម្លើយទូទៅនៃ } (E)}$ , $(A,B\in\mathbb{R})$

ក រកចម្លើយនៃ $(E)$ :

ដោយដឹងថា អនុគមន៍ចម្លើយមានបរមាស្មើ 3 ត្រង់ $x=0$

គេបាន $\begin{cases} y(0)=3 \\ y'(0)=0 \end{cases}$

តែ $y=Ae^{-x}+Be^{2x}$

$\Rightarrow y'=-Ae^{-x}+2Be^{2x}$

- $y(0)=3\Rightarrow A+B=3$

  $\Rightarrow A=3-B \quad (1)$
- $y'(0)=0\Rightarrow -A+2B=0 \quad (2)$

យកសមីការ (1) ជំនួសក្នុង 2 គេបាន

$-(3-B)+2B=0$

$-3+B+2B=0$

$3B=3\Rightarrow B=\frac{3}{3}=1$

$(1)\Rightarrow A=3-1=2$

ដូចនេះ $\boxed{y=2e^{-x}+e^{2x} \text{ ជាចម្លើយនៃ } E \text{ ។}}$

**VI** ១. យើងមានសមីការ $(E): 9x^2+4y^2+18x-24y+9=0$

ក បង្ហាញថាសមីការ ជាសមីការអេលីប

គេបាន $(E): 9x^2+4y^2+18x-24y+9=0$

$$(9x^2+18x)+(4y^2-24y)=-9$$
$$9(x^2+2x+1)-9+4(y^2-6y+9)-36=-9$$
$$9(x+1)^2+4(y-3)^2=36$$
$$\frac{9(x+1)^2}{36}+\frac{4(y-3)^2}{36}=1$$
$$\frac{(x+1)^2}{4}+\frac{(y-3)^2}{9}=1 \text{មានទម្រង់}$$
$$\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1 \quad \text{អ័ក្សធំឈរ}$$

ដូចនេះ: $(E): \frac{(x+1)^2}{4}+\frac{(y-3)^2}{9}=1$ ជាសមីការអេលីប ។

ក រកប្រវែងអ័ក្សធំ ប្រវែងអ័ក្សតូច កូអរដោនេផ្ចិត កំពូល កំណុំ រួចសង់អេលីបនេះ

តាមសមីការខាងលើ គេបាន

$h=-1; k=3$

$a^2=9 \Rightarrow a=3$

$b^2=4 \Rightarrow b=2$

$c^2=a^2-b^2=9-4=5 \Rightarrow c=\sqrt{5}$

គេបាន

- ប្រវែងអ័ក្សធំ $2a=2\times 3=6$ (ឯកតាប្រវែង)
- ប្រវែងអ័ក្សតូច $2b=2\times 2=4$ (ឯកតាប្រវែង)
- កូអរដោនេផ្ចិត $I=(h,k)=(-1,3)$
- កូអរដោនេកំពូល $V=(h,k\pm a) \Rightarrow V_1=(-1,3+3)=(-1,6)$
  $\Rightarrow V_2=(-1,3-3)=(-1,0)$
- កូអរដោនេកំណុំ $F=(h,k\pm C)$
  $\Rightarrow F_1=(-1,3+\sqrt{5})$
  $\Rightarrow F_2=(-1,3-\sqrt{5})$
- សង់អេលីប




២. គេមានចំណុច $A(-1;1;2)$ $B(0;2;4)$ និង$B(-1;3;1)$ :

ក គណនាផលគុណ $\overrightarrow{AB}\times\overrightarrow{AC}$

ដោយ $\overrightarrow{AB}=(0+1,2-1,4-2)=(1,1,2)$

$\overrightarrow{AC}=(-1+1,3-1,1-2)=(0,2,-1)$

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 1 & 2\\ 0 & 2 & -1\end{vmatrix}$

$=\begin{vmatrix}1 & 2\\ 2 & -1\end{vmatrix}\vec{i}-\begin{vmatrix}1 & 2\\ 0 & -1\end{vmatrix}\vec{j}+\begin{vmatrix}1 & 1\\ 0 & 2\end{vmatrix}\vec{k}$

$=[2(2)-1(-1)]\vec{i}-[0(2)-(1)(-1)]\vec{j}+[(0)(1)-(1)(2)]\vec{k}$

$=5\vec{i}-\vec{j}-2\vec{k}$

ដូចនេះ $\boxed{\overrightarrow{AB}\times\overrightarrow{AC}=5\vec{i}-\vec{j}-2\vec{k}}$

+បង្ហាញថា ចំណុច $A;B$ និង $C$ រត់មិនត្រង់គ្នា

ដោយ $\overrightarrow{AB}\times\overrightarrow{AC}=5\vec{i}-\vec{j}-2\vec{k}\neq 0$

ដូចនេះ $\boxed{\text{ចំណុច } A;B \text{ និង } C \text{ រត់មិនត្រង់គ្នា។}}$

៣. គណនាផ្ទៃក្រឡាត្រីកោណ $ABC$

តាមរូបមន្ត $S_{\Delta ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|$

$\Rightarrow S_{\Delta ABC}=\frac{1}{2}\sqrt{5^2+(-1)^2+(-2)^2}=\frac{1}{2}\sqrt{30}$ ( ឯកតាប្រវែង )

ដូចនេះ $\boxed{S_{\Delta ABC}=\frac{1}{2}\sqrt{30}\text{ ( ឯកតាប្រវែង ) ។}}$

**VII** គេមាន $f(x)=\dfrac{4e^x}{e^x+1}$ កំណត់លើ $\in\mathbb{R}$ :

ក គណនាលីមីត និងទាញរកអាស៊ីមតូតនៃក្រាប $C$

$\lim\limits_{x\to-\infty}f(x)=\lim\limits_{x\to-\infty}\dfrac{4e^x}{e^x+1}=\dfrac{4(0)}{0+1}=\boxed{0}$ (ព្រោះ $\lim\limits_{x\to-\infty}e^x=0$)

$\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\dfrac{4e^x}{e^x+1}=\lim\limits_{x\to+\infty}\dfrac{4e^x}{e^x(1+\frac{1}{e^x})}=\dfrac{4}{1+0}=\boxed{4}$

ដោយ $\lim\limits_{x\to-\infty}f(x)=0$ នោះ $\boxed{\text{បន្ទាត់ } x=0 \text{ ជាអាស៊ីមតូតដេកនៃ } C \text{ ខាង } -\infty}$

ដោយ $\lim\limits_{x\to+\infty}f(x)=4$ នោះ $\boxed{\text{បន្ទាត់ } x=0 \text{ ជាអាស៊ីមតូតដេកនៃ } C \text{ ខាង } +\infty}$

ក សិក្សាអថេរភាពនៃ $f$ :

គេបាន $f'(x)=4(\dfrac{e^x(e^x+1)-e^x\cdot e^x}{(e^x+1)^2})=4(\dfrac{e^{2x}+e^x-e^{2x}}{(e^x+1)^2})=\dfrac{4e^x}{(e^x+1)^2}$

ដោយ $e^x>0,\forall x\in\mathbb{R}$ នោះ $f'(x)=\dfrac{4e^x}{(e^x+1)^2}>0$ ជានិច្ច $\forall x\in\mathbb{R}$

នោះគេបាន $f$ ជាអនុគមន៍កើនជានិច្ចលើ $\mathbb{R}$ ។

- រកកូអរដោនេនៃ ចំណុច $A$

ដោយ $C\cap(y'oy)$ ត្រង់ $A(0,y)$

$\Rightarrow f(0)=y$

$\dfrac{4e^0}{e^0+1}=y\Rightarrow y=\dfrac{4}{2}=2$

ដូចនេះ $\boxed{A(0,2)}$

- បង្ហាញថា $A(0,2)$ ជាផ្ចិតឆ្លុះនៃក្រាប $C$ :

  បើ $A(a,b)$ ជាផ្ចិតឆ្លុះនោះ $f(2a-x)+f(x)=2b$

  គេបាន $f(2a-x)+f(x)=\dfrac{4e^{-x}}{e^{-x}+1}+\dfrac{4e^{x}}{e^{x}+1}=\dfrac{4}{1+e^{x}}+\dfrac{4e^{x}}{1+e^{x}}=4=2b$ ( ពិត )

  ដូចនេះ $\boxed{A(0,2) \text{ ជាផ្ចិតឆ្លុះនៃក្រាប } C}$ ។

ក រកសមីការបន្ទាត់ $T$ ប៉ះនឹង $C$ ត្រង់ចំណុច $A$

សមីការបន្ទាត់ $T$ ប៉ះនឹង $C$ ត្រង់ចំណុច $A$ គឺ

$$T: y = f'(x_A)(x-x_A)+f(x_A)$$

$$=(\frac{4x^0}{(e^0+1)^2}(x-0)+\frac{4e^0}{e^0+1}$$

$$=x+2$$

ដូចនេះ $\boxed{T: y=x+2}$

ក សង់ក្រាប $C$ និង បន្ទាត់ $T$ :




ក គណនាផ្ទៃក្រឡាខណ្ឌដោយក្រាប $C$ និងអ័ក្ស $(x'ox)$ លើចន្លោះ $[0,1]$

តាង $S$ ជាផ្ទៃក្រឡាខាងលើ

តាមក្រាបគេបាន $S=\displaystyle\int_0^1 f(x)dx=\int_0^1 \frac{4e^x}{e^x+1}dx$

$$=4\left[\ln|e^x+1|\right]_0^1=4(\ln(e+1)-\ln(e^0+1))$$

$$=4\ln\frac{e+1}{2}$$

ដូចនេះ $\boxed{S=4\ln\dfrac{e+1}{2}}$ ( ឯកតាផ្ទៃ ) ។

ក្រសួងអប់រំ យុវជន និងកីឡា
ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**

លេខបន្ទប់៖________
លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________
ថ្ងៃខែឆ្នាំកំណើត៖________
ហត្ថលេខា៖________

អក្សរសម្ងាត់

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

✂ - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

____ / 125

**៥**

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី
រៀបរៀងដោយ៖ **ផល ផានុ**

អក្សរសម្ងាត់

**I** គេឱ្យចំនួនកុំផ្លិច $Z_1=\sqrt{3}+i$ , $Z_2=1+i$ និង $Z_3=1+i\sqrt{3}$ ។

១. រកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $Z_1,Z_2$ និង $Z_3$ ។

២. សរសេរចំនួនកុំផ្លិច $W=\dfrac{Z_3}{Z_2^2}$ ជាទម្រង់ពីជគណិត ហើយជាទម្រង់ត្រីកោណមាត្រ រួចគណនាឫសការេនៃ $W$ ។

**II** គណនាលីមីត

ក. $A=\lim\limits_{x\to 0}\dfrac{\sqrt{x+1}-\sqrt{2x+1}}{\sqrt{x+3}-\sqrt{2x+3}}$

ខ. $B=\lim\limits_{x\to 0}\dfrac{\ln(1+x)}{\sin x}$

គ. $C=\lim\limits_{x\to 0}\dfrac{(e^{\sin x}-1)(1-\cos 2x)}{\sin^3 x}$

ឃ. $D=\lim\limits_{x\to +\infty}(2-\ln\dfrac{2x-1}{2x})$

**III** គេមានអនុគមន៍ $f$ មួយកំណត់ដោយ $f(x)=\dfrac{e^x}{1-e^x}$ ចំពោះគ្រប់ $x\neq 0$ ។

១. រកចំនួនពិត $A$ និង $B$ ដើម្បីឱ្យ $f(x)=A+\dfrac{B}{1-e^x}$

២. គណនា $I(x)=\displaystyle\int\frac{e^x}{1-e^x}dx$ រួចទាញរក $J(x)=\displaystyle\int\frac{dx}{1-e^x}$ ។

**IV** នៅក្នុងប្រអប់មួយមានប៊ិចក្រហមចំនួន 7 ដើម និងប៊ិចខៀវចំនួន 5 ដើម។
គេយកប៊ិច 4 ដើមព្រមគ្នាចេញពីប្រអប់ដោយចៃដន្យ ។ រកប្រូបាបនៃព្រឹត្តិការណ៍ :

ក. ″ យកបានប៊ិចក្រហមទាំង 4 ដើម ″

ខ. ″ យកបានប៊ិចខៀវយ៉ាងតិច 1 ដើម ″

គ. ″ យកបានប៊ិចក្រហមចំនួន 3 ដើមគត់ ″

**V** គេមានសមីការឌីផេរ៉ង់ស្យែល $(E): y''-2y'+5y=nx^2+px+q$ ។

១. ដោះស្រាយសមីការ $(F): y''-2y'+5y=0$ ។ រកចម្លើយនៃ $(F)$ បើ $y(0)=2$ និង $y'(0)=6$ ។

២. រកចំនួនពិត $n,p,$ និង $q$ ដោយដឹងថា $y=2x^2+3x+1$ ជាចម្លើយនៃ $(E)$ ។ រកចម្លើយទូទៅ $y$ នៃសមីការ $(E)$ ។

**VI** ក្នុងតម្រុយអរតូណម៉ាល់មានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ មួយគេឱ្យចំណុច $A(1,-2,0),B(1,0,4)$ និង $C(0,3,3)$ ។

១. ចូរសង់ត្រីកោណ $ABC$ ក្នុងតម្រុយ $(O,\vec{i},\vec{j},\vec{k})$ ។

២. រកសមីការប្លង់ $(\alpha)$ ជាប្លង់មេដ្យាទ័រនៃ $[AB]$ ។

៣. រកសមីការនៃស្វ៊ែ $S$ ដែលមានអង្កត់ផ្ចិត $[AB]$ ។

៤. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ ។ ទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$ ។

៥. គណនា $P=(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$ ។ ទាញរកមាឌនៃតេត្រាអែត $OABC$ ។ រួចទាញរកចម្ងាយពី $O$ ទៅប្លង់ $ABC$ ។

**VII** អនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $y=f(x)=(x+2)e^{-x}$ ហើយមានក្រាប $C$ ។

១. គណនា $\lim\limits_{x\to -\infty}f(x)$ និង $\lim\limits_{x\to +\infty}f(x)$ ។ ទាញរកសមីការអាស៊ីមតូតដេកនៃក្រាប $C$ ។

២. បង្ហាញថាអនុគមន៍ $f$ មានតម្លៃអតិបរមាមួយត្រង់ $x=-1$ ។ គណនា $f(-1)$ រួចសង់តារាងអថេរភាពនៃ $f$ ។

៣. បង្ហាញថាក្រាប $C$ មានចំណុចរបត់មួយ ។ រកកូអរដោនេនៃចំណុចរបត់ ។

៤. គណនា $f(-2)$ និង $f(2)$ ដោយយក $e^{-2}=0.13$ រួចសង់ក្រាប $C$ ។

៥. គណនាផ្ទៃក្រឡានៃផ្ទៃប្លង់ខណ្ឌដោយក្រាប $C$ អ័ក្ស $(x'ox)$ អ័ក្ស $(y'oy)$ និងបន្ទាត់ឈរ $x=2$ ។

៦. ដោយប្រើក្រាប $C$ ចូរកំណត់តម្លៃនៃប៉ារ៉ាម៉ែត $m$ ដើម្បីឱ្យសមីការ $me^x-x-2=0$ មានឫសពីរផ្ទៀងផ្ទាត់ $x_1<0<x_2$

# ដំណោះស្រាយ

**I** គេមាន $Z_1 = \sqrt{3}+i$ , $Z_2 = 1+i$ និង $Z_3 = 1+i\sqrt{3}$

១. រកម៉ូឌុល និងអាគុយម៉ង់នៃចំនួនកុំផ្លិច $Z_1, Z_2$ និង $Z_3$

• $Z_1 = \sqrt{3}+i$

$$= 2(\frac{\sqrt{3}}{2}+\frac{1}{2}i)$$

$$= 2(\cos\frac{\pi}{6}+i\sin\frac{\pi}{6})$$

ដូចនេះ: $\boxed{|Z_1| = 2\ ,\ arg(Z_1) = \frac{\pi}{6}+2k\pi\ , k\in\mathbb{Z}}$

• $Z_2 = 1+i$

$$= \sqrt{2}(\frac{\sqrt{2}}{2}+i\frac{\sqrt{2}}{2})$$

$$= \sqrt{2}(\cos\frac{\pi}{4}+i\sin\frac{\pi}{4})$$

ដូចនេះ: $\boxed{|Z_2| = \sqrt{2}\ ,\ arg(Z_2) = \frac{\pi}{4}+2k\pi\ , k\in\mathbb{Z}}$

• $Z_3 = 1+i\sqrt{3}$

$$= 2(\frac{1}{2}+i\frac{\sqrt{3}}{2})$$

$$= 2(\cos\frac{\pi}{3}+i\sin\frac{\pi}{3})$$

ដូចនេះ: $\boxed{|(Z_3)| = 2\ ,\ arg(Z_3) = \frac{\pi}{3}+2k\pi\ , k\in\mathbb{Z}}$

២. សរសេរចំនួនកុំផ្លិច $W = \frac{Z_3}{Z_2^2}$ ជាទម្រង់ពីជគណិត ហើយទម្រង់ត្រីកោណមាត្រ

• $W = \frac{Z_3}{Z_2^2} = \frac{1+i\sqrt{3}}{(1+i)^2}$

$$= \frac{1+i\sqrt{3}}{2i}$$

$$= \frac{i(1+i\sqrt{3})}{2i^2}$$

$i^2 = -1$

$$= \frac{i-\sqrt{3}}{-2}$$

$$= \frac{\sqrt{3}}{2}-\frac{1}{2}i$$

ដូចនេះ: $\boxed{W = \frac{\sqrt{3}}{2}-\frac{1}{2}i}$

• $W = \frac{\sqrt{3}}{2}-\frac{1}{2}i$

$-\sin(\alpha) = \sin(-\alpha) = \sin(2\pi-\alpha)$

$$= \cos\frac{\pi}{6}-i\sin\frac{\pi}{6}$$

$$= \cos\frac{11\pi}{6}+i\sin\frac{11\pi}{6}$$

ដូចនេះ: $\boxed{W = \cos\frac{11\pi}{6}+i\sin\frac{11\pi}{6}}$

• គណនាឫសការេនៃ $W$

គេមាន $W=\cos\frac{11\pi}{6}+i\sin\frac{11\pi}{6}$

គេបានឫសការេនៃ $W$ គឺ $W_k=\cos(\frac{\frac{11\pi}{6}+2k\pi}{2})+i\sin(11\frac{\frac{\pi}{6}+2k\pi}{2})$ , $k=0,1,2,3,...$

ចំពោះ $k=0$ គេបាន $W_0=\cos(\frac{11\pi}{12})+i\sin(\frac{11\pi}{12})$

ចំពោះ $k=1$ គេបាន $W_1=\cos(\frac{23\pi}{12})+i\sin(\frac{23\pi}{12})$

## II គណនាលីមីត

ក. $\lim_{x\to 0}\frac{\sqrt{x+1}-\sqrt{2x+1}}{\sqrt{x+3}-\sqrt{2x+3}}$ រាង $\frac{0}{0}$

$(\sqrt{a}+\sqrt{b})(\sqrt{a}-\sqrt{b})=a-b$

$=\lim_{x\to 0}\frac{(x+1-2x-1)(\sqrt{x+3}+\sqrt{2x+3})}{(x+3-2x-3)(\sqrt{x+1}+\sqrt{2x+1})}$

$=\lim_{x\to 0}\frac{(-x)(\sqrt{x+3}+\sqrt{2x+3})}{(-x)(\sqrt{x+1}+\sqrt{2x+1})}$

$=\lim_{x\to 0}\frac{\sqrt{x+3}+\sqrt{2x+3}}{\sqrt{x+1}+\sqrt{2x+1}}$

$=\frac{\sqrt{3}+\sqrt{3}}{\sqrt{1}+\sqrt{1}}=\frac{2\sqrt{3}}{2}$

$=\sqrt{3}$

ដូចនេះ $\boxed{A=\sqrt{3}}$

ខ. $\lim_{x\to 0}\frac{\ln(1+x)}{\sin x}$ រាង $\frac{0}{0}$

$\lim_{x\to 0}\frac{\ln(1+x)}{x}=1$ , $\lim_{x\to 0}\frac{\sin x}{x}=1$

$=\lim_{x\to 0}\frac{\ln(1+x)}{\sin x}$

$=\lim_{x\to 0}\frac{\frac{\ln(1+x)}{x}}{\frac{\sin x}{x}}$

$=\frac{1}{1}=1$

ដូចនេះ $\boxed{B=1}$

គ. $\lim_{x\to 0}\frac{(e^{\sin x}-1)(1-\cos 2x)}{\sin^3 x}$ រាង $\frac{0}{0}$

$\lim_{x\to 0}\frac{e^u-1}{u}=1$

$=\lim_{x\to 0}\frac{e^{\sin x}-1}{\sin x}\times\frac{2\sin^2 x}{\sin^2 x}$

$=1\times 2$

ដូចនេះ $\boxed{C=2}$

ឃ. $\lim_{x\to+\infty}(2-\ln\frac{2x-1}{2x})$ រាង $\frac{\infty}{\infty}$

$=\lim_{x\to+\infty}(2-\ln\frac{2x(1-\frac{1}{2x})}{2x})$

$=\lim_{x\to+\infty}(2-\ln(1-\frac{1}{2x})$

$\ln 1=0$

$=2-\ln 1=2$

ដូចនេះ $\boxed{D=2}$

**III** អនុគមន៍ $f(x)=\dfrac{e^x}{1-e^x}$ ចំពោះគ្រប់ $x\neq 0$ , $D=\mathbb{R}\setminus\bowtie\{0\}$

១. រកចំនួនពិត $A$ និង $B$

ដោយ $f(x)=\dfrac{e^x}{1-e^x}$
$=\dfrac{e^x-1+1}{1-e^x}$
$=-\dfrac{1-e^x}{1-e^x}+\dfrac{1}{1-e^x}$
$=-1+\dfrac{1}{1-e^x}$

តែ $f(x)=A+\dfrac{B}{1-e^x}$

គេបាន $A=-1$ , $B=1$

ដូចនេះ: $\boxed{A=-1\ , B=1}$

២. គណនា $I(x)=\displaystyle\int\frac{e^x}{1-e^x}dx$

ដោយ $I(x)=\displaystyle\int\frac{e^x}{1-e^x}dx$
$=-\displaystyle\int\frac{(1-e^x)'}{1-e^x}dx$
$=-\ln|1-e^x|+c\ ,\ c\in\mathbb{R}$

ដូចនេះ: $\boxed{I(x)=-\ln|1-e^x|+c\ ,\ c\in\mathbb{R}}$

ទាញរក $J(x)=\displaystyle\int\frac{dx}{1-e^x}$

ដោយ $f(x)=\dfrac{e^x}{1-e^x}=-1+\dfrac{1}{1-e^x}$

$1+\dfrac{e^x}{1-e^x}=\dfrac{1}{1-e^x}$

$J(x)=\displaystyle\int\frac{dx}{1-e^x}$
$=\displaystyle\int(1+\frac{e^x}{1-e^x})dx$

$J(x)=x-\ln|1-e^x|+c\ ,\ c\in\mathbb{R}$

ដូចនេះ: $\boxed{J(x)=x-\ln|1-e^x|+c\ ,\ c\in\mathbb{R}}$

**IV** រកប្រូបាបនៃព្រឹត្តិការណ៍៖

ដោយប៊ិចសរុបមាន 12 ដើម គេចាប់យក 4 ដើមដោយចៃដន្យ

គេបានចំនួនករណីអាច $n(S)=C(12,4)=\dfrac{12!}{(12-4)!4!}=\dfrac{12\times11\times10\times9\times8!}{8!\times4\times3\times2\times1}=495$

ក. "យកបានប៊ិចក្រហមទាំង 4 ដើម"

ចំនួនករណីស្រប $n(A)=C(7,4)=\dfrac{7!}{(7-4)!4!}=\dfrac{7\times6\times5\times4!}{3!\times4!}=35$

គេបាន $P(A)=\dfrac{n(A)}{n(S)}=\dfrac{35}{495}=\dfrac{7}{99}$

ដូចនេះ: $\boxed{P(A)=\dfrac{7}{99}}$

ខ. "យកប៊ិចខៀវយ៉ាងតិច 1 ដើម"

វិភាគ

| ខៀវ | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| ក្រហម | 4 | 3 | 2 | 1 | 0 |

គេបាន $P(A)+P(B)=1$

$$P(B)=1-P(A)$$
$$P(B)=1-\frac{7}{99}$$
$$P(B)=\frac{92}{99}$$

ដូចនេះ $\boxed{P(B)=\frac{92}{99}}$

គ. ″យកបានប៊ិចក្រហមចំនួន 3 ដើមគត់″

C ជាព្រឹត្តិការណ៍យកបានប៊ិចក្រហម 3 ដើម និងប៊ិចខៀវ

ចំនួនករណីស្រប $n(C)=C(7,3)\times C(5,1)=\frac{7!}{4!3!}\times 5=\frac{7\times 6\times 5}{3\times 2\times 1}\times 5=35\times 5=175$

គេបាន $P(C)=\frac{n(C)}{n(S)}=\frac{175}{495}=\frac{35}{99}$

ដូចនេះ $\boxed{P(C)=\frac{35}{99}}$

**V** សមីការឌីផេរ៉ង់ស្យែល $(E): y''-2y'+5y=nx^2+px+q$

១. ដោះស្រាយសមីការ $(F)$

$(F): y''-2y'+5y=0$

សមីការសម្គាល់: $\lambda^2-2\lambda+5=0$

$\Delta'=(b')^2-ac=(-1)^2-1\times 5=-4$

$\lambda=\frac{-b'\pm\sqrt{\Delta'}}{a}=\frac{1\pm\sqrt{-4}}{1}=1\pm 2i=\alpha\pm\beta i$

$\Longrightarrow \quad \alpha=1\,,\ \beta=2$

ចម្លើយទូទៅមានទម្រង់ $(F): y=(A\cos\beta x+B\sin\beta x)e^{\alpha x}$

ដូចនេះ ចម្លើយទូទៅ $\boxed{(F): y=(A\cos 2x+B\sin 2x)e^x\,,\ (A,B\in\mathbb{R})}$

• រកចម្លើយនៃ $(F)$

ដោយ $y(0)=2\,,\ y'(0)=6$

$(F): y=(A\cos 2x+B\sin 2x)e^x$

$\Longrightarrow y'=(-2A\sin 2x+2B\cos 2x)e^x+(A\cos 2x+B\sin 2x)e^x$

នោះ $y(0)=(A\cos 0+B\sin 0)e^0$

$$2=A+0$$
$$A=2$$

$y'(0)=(-2A\sin 0+2B\cos 0)e^0+(A\cos 0+B\sin 0)e^0$

$$6=2B+A$$
$$6=2B+2$$
$$B=2$$

ដូចនេះ ចម្លើយទូទៅ $\boxed{(F): y=(2\cos 2x+2\sin 2x)e^x}$

២. រកចំនួនពិត $n,p$ និង $q$

ដោយ $y=2x^2+3x+1$ ជាចម្លើយពិសេសនៃសមីការ $(E)$

$\Longrightarrow y'=4x+3$

$\Longrightarrow y'' = 4$

គេបានសមីការ $(E): y'' - 2y' + 5y = nx^2 + px + q$

$$4 - 2(4x+3) + 5(2x^2+3x+1) = nx^2 + px + q$$
$$4 - 8x - 6 + 10x^2 + 15x + 5 = nx^2 + px + q$$
$$10x^2 + 7x + 3 = nx^2 + px + q$$

ដូចនេះ $\boxed{n = 10\ ,\ p = 7\ ,\ q = 3}$

• រកចម្លើយនៃសមីការ $(E)$

ចម្លើយនៃសមីការ $(E)$ គឺ $y = y_c + y_p$

ដោយ $y_c = (A\cos 2x + B\sin 2x)e^x$

$y_p = 2x^2 + 3x + 1$

ដូចនេះ $\boxed{y = (A\cos 2x + B\sin 2x)e^x + 2x^2 + 3x + 1\ ,\ (A,B) \in \mathbb{R}}$

**VI** គេឱ្យចំណុច $A(1,-2,0), B(1,0,4)$ និង $C(0,3,3)$

១. សង់ត្រីកោណ $ABC$ ក្នុងតម្រុយ $(O, \vec{i}, \vec{j}, \vec{k})$




២. រកសមីការប្លង់ $(\alpha)$

សមីការប្លង់ $(\alpha): \ a(x-x_0) + b(y-y_0) + c(z-z_0) = 0$

ដោយប្លង់ $(\alpha)$ ប្លង់មេដ្យាទ័រនៃអង្កត់ $[AB] \Rightarrow (\alpha) \perp AB$ ត្រង់ចំណុចកណ្តាលនៃ $[AB]$

$$\Rightarrow \begin{cases} x_0 = \dfrac{x_A + x_B}{2} = \dfrac{1+1}{2} = 1 \\ y_0 = \dfrac{y_A + y_B}{2} = \dfrac{-2+0}{2} = -1 \\ z_0 = \dfrac{z_A + z_B}{2} = \dfrac{0+4}{2} = 2 \end{cases}$$

ហើយ $(\alpha) \perp \overrightarrow{AB}$ ដែល $\overrightarrow{AB} = (1,0,4) - (1,-2,0) = (0,2,4)$

គេបានប្លង់ $(\alpha): \ 0(x-1) + 2(y+1) + 4(z-2) = 0$

$$0 + 2y + 2 + 4z - 8 = 0$$
$$2y + 4z - 6 = 0$$

ដូចនេះ $\boxed{(\alpha): \ 2y + 4z - 6 = 0}$

៣. រកសមីការនៃស្វ៊ែ $S$

សមីការស្វ៊ែ $(S):\ (x-x_0)^2+(y-y_0)^2+(z-z_0)^2=r^2$

ដោយស្វ៊ែ $(S)$ មានអង្កត់ផ្ចិត $[AB]$

គេបាន $I(1,-1,2)$ ជាផ្ចិតនៅកណ្ដាលនៃ $[AB]$

ហើយកាំ $r=\frac{1}{2}AB=\frac{1}{2}\sqrt{(1-1)^2+(0+2)^2+(4+0)^2}=\frac{1}{2}\sqrt{20}=\sqrt{5}$

គេបាន $(S):\ (x-1)^2+(y+1)^2+(z-2)^2=\sqrt{5}^2$

ដូចនេះ $\boxed{(S):\ (x-1)^2+(y+1)^2+(z-2)^2=5}$

៤. គណនា $\overrightarrow{n}=\overrightarrow{AB}\times\overrightarrow{AC}$

$\overrightarrow{AB}=(0,2,4)$ , $\overrightarrow{AB}=(0,3,3)-(1,-2,0)=(-1,5,3)$

គេបាន $\overrightarrow{n}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ 0 & 2 & 4\\ -1 & 5 & 3\end{vmatrix}=\begin{vmatrix}2 & 4\\ 5 & 3\end{vmatrix}\overrightarrow{i}-\begin{vmatrix}0 & 4\\ -1 & 3\end{vmatrix}\overrightarrow{j}+\begin{vmatrix}0 & 2\\ -1 & 5\end{vmatrix}\overrightarrow{k}$

$\Longrightarrow \overrightarrow{n}=(6-20)\overrightarrow{i}-(0+4)\overrightarrow{j}+(0+2)\overrightarrow{k}$

ដូចនេះ $\boxed{\overrightarrow{n}=-14\overrightarrow{i}-4\overrightarrow{j}+2\overrightarrow{k}}$

• ទាញរកផ្ទៃក្រឡានៃត្រីកោណ $ABC$

តាមរូបមន្ត $S_{ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|$

$=\frac{1}{2}\sqrt{(-14)^2+(-4)^2+2^2}$

$=\frac{1}{2}\times2\sqrt{7^2+2^2+1^2}=\sqrt{54}=3\sqrt{6}$

ដូចនេះ $\boxed{S_{ABC}=3\sqrt{6}\text{ ឯកតាផ្ទៃ}}$

៥. គណនា $P=(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$

ដោយ $\overrightarrow{n}=\overrightarrow{AB}\times\overrightarrow{AC}=(-14,-4,2)$ , $\overrightarrow{OA}=-(1,-2,0)=(-1,2,0)$

គេបាន $P=(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$

$=-14(-1)-4(2)+2(0)$

$=14-8$

ដូចនេះ $\boxed{P=6}$

• ទាញរកមាឌនៃតេត្រាអែត $OABC$

តាមរូបមន្ត $V_{OABC}=\frac{1}{6}|(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}|=\frac{1}{6}\times6=1$

ដូចនេះ $\boxed{\text{មាឌនៃតេត្រាអែត } V_{OABC}=1\text{ ឯកតាមាឌ}}$

• រួចទាញរកចម្ងាយពី $O$ ទៅប្លង់ $ABC$

តាមរូបមន្ត $V_{OABC}=\frac{1}{3}S_{ABC}\times d(O,ABC)$

$d(O,ABC)=3\frac{V_{OABC}}{S_{ABC}}$

$d=\frac{3}{3\sqrt{6}}=\frac{\sqrt{6}}{6}$

ដូចនេះ $\boxed{d(O,ABC)=\frac{\sqrt{6}}{6}\text{ ឯកតាប្រវែង}}$

**VII** អនុគមន៍ $f$ កំណត់លើ $\mathbb{R}$ ដោយ $y=f(x)=(x+2)e^{-x}$ ហើយមានក្រាប $C$ ។

១. គណនា $\lim\limits_{x\to-\infty}f(x)$ និង $\lim\limits_{x\to+\infty}f(x)$

$\lim\limits_{x\to-\infty} e^{-x} = +\infty$

- $\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty} (x+2)e^{-x} = (-\infty)(+\infty) = -\infty$
- $\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty} (x+2)e^{-x} = \lim\limits_{x\to+\infty} (\frac{x}{e^x} + \frac{2}{e^x}) = 0$

ដូចនេះ: $\boxed{\lim\limits_{x\to-\infty} f(x) = -\infty\ ,\ \lim\limits_{x\to+\infty} f(x) = 0}$

ទាញរកសមីការអាស៊ីមតូតដេកនៃក្រាប $C$

ដោយ $\lim\limits_{x\to+\infty} f(x) = 0$

ដូចនេះ: $\boxed{y = 0}$ ជាអាស៊ីមតូតដេកនៃក្រាប $C$ ខាង $+\infty$

២. បង្ហាញថាអនុគមន៍ $f$ មានតម្លៃអតិបរមាមួយត្រង់ $x = -1$

ដោយ $f(x) = (x+2)e^{-x}$

$\Longrightarrow f'(x) = (x+2)'e^{-x} + (x+2)(e^{-x})'$

$= e^{-x} - (x+2)e^{-x}$

$= e^{-x}(-x-1)$

ដោយ $e^{-x} > 0\ ,\ \forall x \in \mathbb{R}$

$f'(x)$ មានសញ្ញាតាម $(-x-1)$

បើ $f'(x) = 0 \Longleftrightarrow -x-1 = 0 \Longrightarrow x = -1$

- តារាងសញ្ញានៃ $f'(x)$

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |

ត្រង់ $x = -1 \Longrightarrow f'(x) = 0$ ហើយប្តូរសញ្ញាពី $(+)$ ទៅ $(-)$ ។

ដូចនេះ: អនុគមន៍ $f$ មានតម្លៃអតិបរមាមួយត្រង់ $x = -1$ (in a box)

- គណនា $f(-1)$

ដោយ $f(x) = (x+2)e^{-x}$

$\Longrightarrow f(-1) = (-1+2)e^1 = 2.71$

- រួចសង់តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | |
| $f''(x)$ | $-\infty$ | ↗ | $2.71$ | ↘ | $0$ |

៣. បង្ហាញថាក្រាប $C$ មានចំណុចរបត់មួយ

$f'(x) = e^{-x}(-x-1)$

$f''(x) = (e^{-x})'(-x-1) + e^{-x}(-x-1)'$

$= -e^{-x}(-x-1) - e^{-x}$

$= e^{-x}(x+1-1)$

$= xe^{-x}$

ដោយ $e^{-x} > 0$ , $\forall x \in \mathbb{R}$

បើ $f''(x) = 0 \Longleftrightarrow x = 0$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f''(x)$ | | $-$ | $0$ | $+$ | |

ត្រង់ $x = 0 \Longrightarrow f''(x) = 0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ ។

ដូចនេះ **ក្រាប $C$ មានចំណុចរបត់មួយត្រង់ $x = 0$**

• រកកូអរដោនេនៃចំណុចរបត់

$$f(x) = (x+2)e^{-x}$$

$\Longrightarrow f(0) = (0+2)e^{0} = 2$

៤. គណនា $f(-2)$ និង $f(2)$

$$f(x) = (x+2)e^{-x}$$

$\Longrightarrow f(-2) = (-2+2)e^{2} = 0$

$\Longrightarrow f(2) = (2+2)e^{-2} = 4 \times 0.13 = 0.52$

• រួចសង់ក្រាប $C$




៥. គណនាផ្ទៃក្រឡា $S$

ដោយផ្ទៃក្រឡា $S$ ខណ្ឌដោយក្រាប $C$ អ័ក្ស $(x'ox)$ អ័ក្ស $(y'oy)$ និងបន្ទាត់ឈរ $x = 2$

គេបាន $S = \int_0^2 f(x)dx = \int_0^2 (x+2)e^{-x}dx$

• រក$I = \int (x+2)e^{-x}dx$

តាង $u = x+2 \Longrightarrow du = dx$ , $dv = e^{x} \Longrightarrow v = \int e^{x}dx = -e^{x}$

គេបាន $I=-e^{-x}(x+2)+\int e^{-x}dx$

$=-e^{-x}(x+2)-e^{-x}+C \quad , \quad C\in\mathbb{R}$

$=-e^{-x}(x+3)+C \quad , \quad C\in\mathbb{R}$

យើងបាន $S=[-e^{-x}(x+3)]_0^2$

$=-e^{-2}(2+3)+e^{0}(0+3)$

$=-0.13(5)+3$

$=2.35$

ដូចនេះៈ ផ្ទៃក្រឡា $S=2.35$ ឯកតាផ្ទៃក្រឡា

៦. កំណត់តម្លៃនៃប៉ារ៉ាម៉ែត $m$ ដោយប្រើក្រាប $C$

សមីការ $me^x-x-2=0$

$me^x=x+2$

$m=\dfrac{x+2}{e^x}m \quad =(x+2)e^{-x}$

សមីការនេះជាសមីការអាប់ស៊ីសចំណុចប្រសព្វរវាងក្រាប $C$ និង បន្ទាត់ដេក $\Delta: y=m$

ដើម្បីឱ្យសមីការ $me^x-x-2=0$ មានឫសពីរផ្ទៀងផ្ទាត់ $x_1<0<x_2$

លុះត្រាតែ $m\in(0,2)$

ដូចនេះៈ $m\in(0,2)$ សមីការមានឫសពីរផ្ទៀងផ្ទាត់ $x_1<0<x_2$

ក្រសួងអប់រំ យុវជន និងកីឡា
ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________
**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________________
ថ្ងៃខែឆ្នាំកំណើត៖________________
ហត្ថលេខា៖________________

លេខបន្ទប់៖________
លេខតុ៖________

អក្សរសម្ងាត់

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

____ / 125

# ៦

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី
រៀបរៀងដោយ៖ **ថា មករា**

អក្សរសម្ងាត់

**I** គេឱ្យចំនួនកុំផ្លិច $x=-\frac{1}{2}-\frac{\sqrt{3}}{2}i$ និង $y=-\frac{1}{2}+\frac{\sqrt{3}}{2}i$ ។

១. គណនា $A=x-y^2$ និង $B=x^2+x+1$ ។

២. សរសេរ $x$ និង$y$ ជាទម្រង់ត្រីកោណមាត្រ។ បង្ហាញថា $C=x^{2019}+y^{2019}$ ជាចំនួនពិត ។

**II** គណនាលីមីតខាងក្រោម៖

$\mathrm{A}=\lim\limits_{x\to\sqrt{3}}\frac{x^3-3\sqrt{3}}{x^2-3}$ $\quad\mathrm{B}=\lim\limits_{x\to 0}\frac{e^{5x+3}-e^3}{2x}$ $\quad\mathrm{C}=\lim\limits_{x\to 0}\frac{\tan x-\sin x}{x^3}$

**III** ចតុកោណកែងមួយមានបរិមាត្រ 400m ។ រកប្រវែងជ្រុងដើម្បីឱ្យចតុកោណកែងនេះមានផ្ទៃក្រឡាធំបំផុត។

**IV** នៅក្នុងប្រអប់មានប៊ិចចំនួន១០ដើម ដែលក្នុងនោះមានប៊ិចក្រហមចំនួន៤ដើម និងប៊ិចខៀវចំនួន៦ដើម។ គេចាប់យកប៊ិច៣ដើម ក្នុងពេលតែមួយចេញពីប្រអប់នោះដោយចៃដន្យ។ គណនាប្រូបាបនៃព្រឹត្តិការណ៍

A .˝ចាប់បានប៊ិចខៀវទាំងបីដើម˝ ។ B .˝ចាប់បានប៊ិចក្រហមមួយដើម និងខៀវពីរដើម˝ ។

C .˝ចាប់បានប៊ិចខៀវតែមួយដើមគត់˝ ។

**V** គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E): y''+6y'+8y=8x+10$ ។

១. ដោះស្រាយសមីការ $(E_1): y''+6y'+8y=0$។ កំណត់ចម្លើយពិសេសមួយនៃ $(E_1)$ ដែល $y(0)=-1$ និង $y'(0)=4$ ។

២. កំណត់ចំនួនពិត $a$ និង $b$ ដើម្បីឱ្យ $g(x)=ax+b$ ជាចម្លើយនៃ $(E)$ ។

**VI** ក្នុងតម្រុយអរតូណរម៉ាល់នៃលំហមានទិសដៅវិជ្ជមាន $(O,\vec{i},\vec{j},\vec{k})$ គេឱ្យចំណុច $A(1,0,0),B(0,1,0)$ និង $C(0,0,1)$។

១. បង្ហាញថាត្រីកោណ $ABC$ ជាត្រីកោណសម័ង្ស ។

២. គណនាផលគុណនៃវ៉ិចទ័រ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ រួចសរសេរសមីការប្លង់ $ABC$ ។

៣. រកចម្ងាយពីចំណុច $D(0,1,1)$ ទៅប្លង់ $ABC$ ។

៤. រកសមីការស្វ៊ែ $S$ ដែលមានអង្កត់ផ្ចិត $AC$ ។

៥. រកសមីការប្លង់ $P$ ប៉ះស្វ៊ែ $S$ ត្រង់ $C$ ។

**VII** $f$ ជាអនុគមន៍កំណត់ចំពោះ $x>0$ ដោយ $f(x)=1+2\left(\frac{\ln x}{x}\right)$ ហើយមានក្រាប$C$ ។

១. គណនា $\lim\limits_{x\to 0^+}f(x)$ និង $\lim\limits_{x\to+\infty}f(x)$ ។ កំណត់សមីការអាស៊ីមតូតឈរនិងដេកនៃក្រាប $C$ ។

២. គណនាដេរីវេ $f'(x)$ និងសិក្សាសញ្ញានៃ $f'(x)$ ។ សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

៣. កំណត់កូអរដោនេនៃចំណុចប្រសព្វ $A$ រវាងក្រាប $C$ និងបន្ទាត់ $D: y=1$។ កំណត់សមីការបន្ទាត់ $L$ ដែលប៉ះនឹងក្រាប $C$ ត្រង់ចំណុច $A$ ។

៤. គណនា $f\left(\frac{1}{2}\right)$។ សង់បន្ទាត់ $L$ អាស៊ីមតូត និងក្រាប $C$ នៅក្នុងតម្រុយតែមួយ។ (គេឱ្យ$e=2.7$, $\frac{2}{e}=0.7, \ln 2=0.7$)

# ដំណោះស្រាយ

**I**

១. គណនា $A=x-y^2$ និង $B=x^2+x+1$

គេមាន $x=-\frac{1}{2}-\frac{\sqrt{3}}{2}i$ និង $y=-\frac{1}{2}+\frac{\sqrt{3}}{2}i$

គេបាន $A=-\frac{1}{2}-\frac{\sqrt{3}}{2}i-\left(-\frac{1}{2}+\frac{\sqrt{3}}{2}i\right)^2=-\frac{1}{2}-\frac{\sqrt{3}}{2}i-\left[\frac{1}{4}+2\left(-\frac{1}{2}\right)\left(\frac{\sqrt{3}}{2}i\right)-\frac{3}{4}\right]$ ដូចនេះ $A=$

$$=-\frac{1}{2}-\frac{\sqrt{3}}{2}i-\frac{1}{4}+\frac{\sqrt{3}}{2}i+\frac{3}{4}=-\frac{1}{2}+\frac{1}{2}-\frac{\sqrt{3}}{2}i+\frac{\sqrt{3}}{2}=0$$

0 ។

ហើយ $B=x^2+x+1=\left(-\frac{1}{2}-\frac{\sqrt{3}}{2}i\right)^2-\frac{1}{2}-\frac{\sqrt{3}}{2}i+1$

$$=\frac{1}{4}-2\left(-\frac{1}{2}\right)\left(\frac{\sqrt{3}}{2}i\right)-\frac{3}{4}-\frac{1}{2}-\frac{\sqrt{3}}{2}i+1=\frac{1}{4}+\frac{\sqrt{3}}{2}i-\frac{3}{4}-\frac{1}{2}-\frac{\sqrt{3}}{2}i+1$$

$$=-1+1=0$$

ដូចនេះ: $B=0$ ។

២. សរសេរ$x$ និង$y$ជាទម្រង់ត្រីកោណមាត្រ

គេបាន $x=-\frac{1}{2}-\frac{\sqrt{3}}{2}i=\cos\frac{7\pi}{6}+i\sin\frac{7\pi}{6}$

ហើយ $y=-\frac{1}{2}+\frac{\sqrt{3}}{2}i=\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}$

ដូចនេះ: $x=\cos\frac{7\pi}{6}+i\sin\frac{7\pi}{6}$ និង$y=\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}$ជាទម្រង់ត្រីកោណមាត្រ ។

+បង្ហាញថា$C=x^{2019}+y^{2019}$ជាចំនួនពិត

គេបាន $C=\left(\cos\frac{7\pi}{6}+i\sin\frac{7\pi}{6}\right)^{2019}+\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)^{2019}$

$$=\cos\frac{7\pi\times 2019}{6}+i\sin\frac{7\pi\times}{6}+\cos\frac{5\pi\times 2019}{6}+i\sin\frac{5\pi\times 2019}{6}$$

$$=\cos\frac{3365\pi}{6}+i\sin\frac{3365\pi}{6}+\cos\frac{4711\pi}{2}+i\sin\frac{4711\pi}{6}$$

$$=\cos\left(1682\pi+\frac{\pi}{2}\right)+i\sin\left(1682\pi+\frac{\pi}{2}\right)+\cos\left(2354\pi+\frac{3\pi}{2}\right)+i\sin\left(2354\pi+\frac{3\pi}{2}\right)$$

$$=\cos\frac{\pi}{2}+i\sin\frac{\pi}{2}+\cos\frac{3\pi}{2}+i\sin\frac{3\pi}{2}=0+i+0-i=0 \quad \text{(ពិត)}$$

ដូចនេះ: $C=x^{2019}+y^{2019}$ជាចំនួនពិត ។

**II** គណនាលីមីត

$$A=\lim_{x\to\sqrt{3}}\frac{x^3-3\sqrt{3}}{x^2-3} \text{ រាង} \frac{0}{0}$$

គេបាន$A=\lim_{x\to\sqrt{3}}\frac{x^3-(\sqrt{3})^3}{x^2-(\sqrt{3})^2}=\frac{(x-\sqrt{3})(x^2+x\sqrt{3}+3)}{(x-\sqrt{3})(x+\sqrt{3})}=\lim_{x\to\sqrt{3}}\frac{x^2+x\sqrt{3}+3}{x+\sqrt{3}}$

$$=\frac{3+3+3}{\sqrt{3}+\sqrt{3}}=\frac{9}{2\sqrt{3}}=\frac{9\sqrt{3}}{2\times 3}=\frac{3\sqrt{3}}{2}$$

ដូចនេះ: $A=\frac{3\sqrt{3}}{2}$ ។

$$B=\lim_{x\to 0}\frac{e^{5x+3}-e^3}{2x} \text{ រាង} \frac{0}{0}$$

គេបាន $C=\lim_{x\to 0}\frac{e^3\left(e^{5x}-1\right)}{2x}=\lim_{x\to 0}\frac{e^3\left(e^{5x}-1\right)}{5x}\times\frac{5}{2}=\frac{5e^3}{2}$

ដូចនេះ: $B=\frac{5e^3}{2}$ ។

C $=\lim\limits_{x\to0}\frac{\tan x-\sin x}{x^3}$ រាង $\frac{0}{0}$

គេបាន $C=\lim\limits_{x\to0}\frac{\tan x-\tan x\cdot\cos x}{x^3}=\lim\limits_{x\to0}\frac{\tan x(1-\cos x)}{x^3}=\lim\limits_{x\to0}=\lim\limits_{x\to0}\frac{2\tan x\cdot\sin^2\frac{x}{2}}{x^3}$

$$=\lim_{x\to0}2\left(\frac{\tan x}{x}\cdot\frac{\sin^2\frac{x}{2}}{\frac{x^2}{4}}\cdot\frac{1}{4}\right)=\lim_{x\to0}\frac{1}{2}\left[\frac{\tan x}{x}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2\right]=\frac{1}{2}\times1\times1^2=\frac{1}{2}$$

ដូចនេះ: $C=\frac{1}{2}$ ។

**III** រកប្រវែងជ្រុងដើម្បីឱ្យចតុកោណកែងនេះមានផ្ទៃក្រឡាធំបំផុត

តាង$x$ជាទទឹង




$y$ជាបណ្តោយ

លក្ខខណ្ឌ $0<x\le y<400$

-បរិមាត្រចតុកោណកែង

$P=2(x+y)$

$x+y=\frac{P}{2}=\frac{400}{2}=200$

$y=200-x\qquad(1)$

-ផ្ទៃក្រឡាចតុកោណកែង

$S=xy\qquad(2)$

យក(1) ជំនួស(2)គេបាន

$S(x)=x(200-x)=200x-x^2$

$\Rightarrow S'(x)=200-2x$

-បើ$S'(x)=0\Leftrightarrow200-2x=0\Rightarrow x=100$

-តារាងអថិរភាព

| $x$ | $-\infty$ | 100 | $+\infty$ |
|---|---|---|---|
| $S'(x)$ | + | 0 | − |
| $S(x)$ | ↗ | $S(100)$ | ↘ |

តាមតារាងអថិរភាពខាងលើ គេបានផ្ទៃក្រឡាចតុកោណកែងធំបំផុត

-បើ $x=100$ តាម(1)គេបាន

$y=200-100=100$

ដូចនេះ: ប្រវែងជ្រុងចតុកោណកែងគឺ$x=y=100$m ។

**IV** ដោយក្នុងប្រអប់មានប៊ិចចំនួន១០ដើម ហើយគេចាប់យកប៊ិច៣ដើមពីក្នុងប្រអប់ដោយចៃដន្យក្នុងពេលតែមួយ នោះចំនួនករណីអាចគឺ

$n(S)=C(10,3)=\frac{10!}{(10-3)!3!}=\frac{10\times9\times8\times7!}{7!\times1\times2\times3}=\frac{720}{6}=120$ ករណី

រកប្រូបាបនៃព្រឹត្តិការណ៍

A .˝ចាប់បានប៊ិចខៀវទាំងបីដើម˝

ដោយប៊ិចខៀវក្នុងប្រអប់ទាំងអស់មាន៦ដើម នោះចំនួនករណីស្របគឺ

$n(A)=C(6,3)=\dfrac{6!}{(6-3)!3!}=\dfrac{6\times5\times4\times3!}{3\times2\times1\times3!}=\dfrac{6\times5\times4}{6}=20$ ករណី

តាម $P(A)=\dfrac{n(A)}{n(S)}=\dfrac{20}{120}=\dfrac{1}{6}$

ដូចនេះ ប្រូបាបនៃព្រឹត្តិការណ៍ចាប់បានប៊ិចខៀវទាំងបីដើមគឺ$P(A)=\dfrac{1}{6}$ ។

B ."ចាប់បានប៊ិចក្រហមមួយដើម និងខៀវពីរដើម"

ដោយក្នុងប្រអប់មានប៊ិចខៀវទាំងអស់៦ដើម និងប៊ិចក្រហម៤ដើម នោះចំនួនករណីស្របគឺ

$n(B)=C(6,2)\times C(4,1)=\dfrac{6!}{(6-2)!2!}\times\dfrac{4!}{(4-1)!1!}=\dfrac{6\times5\times4!}{4!\times2!}\times\dfrac{4\times3!}{3!}$

$=\dfrac{30}{2}\times4=60$ករណី

តាម $P(B)=\dfrac{n(B)}{n(S)}=\dfrac{60}{120}=\dfrac{1}{2}$

ដូចនេះ ប្រូបាបនៃព្រឹត្តិការណ៍ចាប់បានប៊ិចក្រហមមួយដើម និងខៀវពីរដើមគឺ $P(B)=\dfrac{1}{2}$ ។

C ."ចាប់បានប៊ិចខៀវតែមួយដើមគត់"

គេបាន ចំនួនករណីស្រប

$n(C)=C(6,1)\times C(4,2)=\dfrac{6!}{(6-1)!1!}\times\dfrac{4!}{(4-2)!2!}=\dfrac{6\times5!}{5!}\times\dfrac{4\times3\times2!}{2\times1\times2!}$

$=6\times\dfrac{4\times3}{2}=36$ករណី

តាម $P(C)=\dfrac{n(C)}{n(S)}=\dfrac{36}{120}=\dfrac{3}{10}$

ដូចនេះ ប្រូបាបនៃព្រឹត្តិការណ៍ចាប់បានប៊ិចខៀវតែមួយដើមគត់គឺ$P(C)=\dfrac{3}{10}$ ។

**V** គេមាន $(E):y''+6y'+8y=8x+10$

១. ដោះស្រាយសមីការ$(E_1):y''+6y'+8y=0$

សមីការសម្គាល់ $\lambda^2-6\lambda+8=0$

$(\lambda-1)(\lambda-4)=0$

$\Rightarrow\lambda_1=2,\lambda_2=4$

គេបាន ចម្លើយទូទៅនៃ$(E_1)$គឺ $y=Ae^{4x}+Be^{2x}$ ,$A,B\in\mathbb{R}$

ដូចនេះ ចម្លើយទូទៅនៃ$(E_1)$គឺ $y=Ae^{4x}+Be^{2x}$ $A,B\in\mathbb{R}$ ។

+កំណត់ចម្លើយពិសេសនៃ$(E_1)$

គេមាន $y(0)=-1,y'(0)=4$

គេបាន $y'=4Ae^{4x}+2Be^{2x}$ ,$A,B\in\mathbb{R}$

ដោយ $\begin{cases}y(0)=-1\\y'(0)=0\end{cases}\Rightarrow\begin{cases}A+B=-1\\4A+2B=4\end{cases}\Rightarrow\begin{cases}A+B=-1 & (1)\\2A+B=2 & (2)\end{cases}$

យក$(1)-(2)$គេបាន

$-A=-3\Rightarrow A=3$ជំនួស$(1)$គេបាន

$3+B=-1\Rightarrow B=-4$

នោះ ចម្លើយពិសេសនៃសមីការ$(E_1)$ គឺ$y=3e^{4x}-4e^{2x}$

ដូចនេះ ចម្លើយពិសេសនៃសមីការ$(E_1)$ គឺ$y=3e^{4x}-4e^{2x}$ ។

២. កំណត់ចំនួនពិត$a$ និង$b$

គេមាន $g(x)=ax+b$

$\Rightarrow g'(x) = a$

$\Rightarrow g''(x) = 0$

ដោយ$g$ជាចម្លើយពិសេសនៃ$(E)$ គេបាន

$g''(x) - 6g(x) + 8g(x) = 8x + 10$

$0 - 6a + 8(ax + b) = 8x + 10$

$8ax + 8b - 6a = 8x + 10$

$$\begin{cases} 8a = 8 \\ 8b - 6a = 10 \end{cases} \Rightarrow \begin{cases} a = 1 \\ 8b = 10 + 6 \end{cases} \Rightarrow \begin{cases} a = 1 \\ b = 2 \end{cases}$$

ដូចនេះ តម្លៃ$a = 1$ និង$b = 2$ ។

**VI**

១. បង្ហាញថាត្រីកោណ$ABC$ជាត្រីកោណសម័ង្ស

គេមាន $A(1,0,0), B(0,1,0)$ និង$C(0,0,1)$

គេបាន $\overrightarrow{AB} = (0-1, 1-0, 0-0) = (-1,1,0)$

$\overrightarrow{AC} = (0-1, 0-0, 1-0) = (-1,0,1)$

$\overrightarrow{BC} = (0-0, 0-1, 1-0) = (0,-1,1)$

នោះ $\left|\overrightarrow{AB}\right| = \sqrt{(-1)^2 + 1^2 + 0} = \sqrt{2}$

$\left|\overrightarrow{AC}\right| = \sqrt{(-1)^2 + 0 + 1^2} = \sqrt{2}$

$\left|\overrightarrow{BC}\right| = \sqrt{0 + (-1)^2 + 1^2} = \sqrt{2}$

ដោយ $\left|\overrightarrow{AB}\right| = \left|\overrightarrow{AC}\right| = \left|\overrightarrow{BC}\right| = \sqrt{2}$ នោះត្រីកោណ$ABC$ជាត្រីកោណសម័ង្ស (ពិត)

ដូចនេះ ត្រីកោណ$ABC$ជាត្រីកោណសម័ង្ស ។

២. គណនាផលគុណនៃវ៉ិចទ័រ$\overrightarrow{n} = \overrightarrow{AB} \times \overrightarrow{AC}$

គេបាន $\overrightarrow{n} = \overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \overrightarrow{i} & \overrightarrow{j} & \overrightarrow{k} \\ -1 & 1 & 0 \\ -1 & 0 & 1 \end{vmatrix} = \begin{vmatrix} 1 & 0 \\ 0 & 1 \end{vmatrix}\overrightarrow{i} - \begin{vmatrix} -1 & 0 \\ -1 & 1 \end{vmatrix}\overrightarrow{j} + \begin{vmatrix} -1 & 1 \\ -1 & 0 \end{vmatrix}\overrightarrow{k}$

$= (1-0)\overrightarrow{i} - (-1-0)\overrightarrow{j} + (0+1)\overrightarrow{k} = \overrightarrow{i} + \overrightarrow{j} + \overrightarrow{k} = (1,1,1)$

ដូចនេះ $\overrightarrow{n} = \overrightarrow{AB} \times \overrightarrow{AC} = (1,1,1)$ ។

+រកសមីការប្លង់$ABC$

ដោយប្លង់$ABC$កាត់តាមចំណុច$A(1,0,0)$ និងមានវ៉ិចទ័រណរម៉ាល់$\overrightarrow{n} = (1,1,1)$

តាម $ABC : a(x - x_0) + b(y - y_0) + c(z - z_0) = 0$

$: 1(x-1) + 1(y-0) + 1(z-0) = 0$

$: x + y + z - 1 = 0$

ដូចនេះ សមីការប្លង់$ABC$គឺ$ABC : x + y + z - 1 = 0$ ។

៣. រកចម្ងាយពីចំណុច$D(0,1,1)$ ទៅប្លង់$ABC$

គេមាន $D(0,1,1)$ និង$ABC : x + y + z - 1 = 0$

តាម $d(D, ABC) = \dfrac{|ax_0 + by_0 + cz_0 + d|}{\sqrt{a^2 + b^2 + c^2}}$

គេបាន $d(D,ABC)=\dfrac{|1\times 0+1\times 1+1\times 1-1|}{\sqrt{1^2+1^2+1^2}}=\dfrac{|0+1+1-1|}{\sqrt{3}}$ ឯកតាប្រវែង

$=\dfrac{\sqrt{3}}{3}$

ដូចនេះ ចម្ងាយពីចំណុច$D$ទៅប្លង់ $ABC$គឺ $d(D,ABC)=\dfrac{\sqrt{3}}{3}$ ឯកតាប្រវែង ។

៤. រកសមីការស្វ៊ែ$S$ ដែលមានអង្កត់ផ្ចិត$AC$

តាង $I$ជាផ្ចិតនៃនៃស្វ៊ែ$S$ដែលមានអង្កត់ផ្ចិត$AC$

តាម $I\left(\dfrac{x_1+x_2}{2},\dfrac{y_1+y_2}{2},\dfrac{z_1+z_2}{2}\right)=I\left(\dfrac{1+0}{2},\dfrac{0+0}{2},\dfrac{0+1}{2}\right)=I\left(\dfrac{1}{2},0,\dfrac{1}{2}\right)$

កាំ $r=\dfrac{AC}{2}=\dfrac{\sqrt{2}}{2}$ ឯកតាប្រវែង

តាម $S:(x-a)^2+(y-b)^2+(z-c)^2=r^2$

គេបាន $S:\left(x-\dfrac{1}{2}\right)^2+(y-0)^2+\left(z-\dfrac{1}{2}\right)^2=\left(\dfrac{\sqrt{2}}{2}\right)^2$

$:\left(x-\dfrac{1}{2}\right)^2+y^2+\left(z-\dfrac{1}{2}\right)^2=\dfrac{1}{2}$

ដូចនេះ សមីការស្វ៊ែ$S$ គឺ $S:\left(x-\dfrac{1}{2}\right)^2+y^2+\left(z-\dfrac{1}{2}\right)^2=\dfrac{1}{2}$ ។

៥. រកសមីការប្លង់$P$ ប៉ះស្វ៊ែ$S$ ត្រង់$C$

ដោយប្លង់ $P$ ប៉ះស្វ៊ែ $S$ ត្រង់ចំណុច$C$នោះ$P$កែង$\overrightarrow{IC}$

គេបាន $\overrightarrow{IC}=\left(0-\dfrac{1}{2},0-0,1-\dfrac{1}{2}\right)=\left(-\dfrac{1}{2},0,\dfrac{1}{2}\right)$

តាម $P:a(x-x_0)+b(y-y_0)+c(z-z_0)=0$

នាំឱ្យ $P:-\dfrac{1}{2}(x-0)+0(y-0)+\dfrac{1}{2}(z-1)=0$

$:-\dfrac{1}{2}x+\dfrac{1}{2}z-\dfrac{1}{2}=0$

ដូចនេះ សមីការប្លង់ $P$ គឺ $P::-\dfrac{1}{2}x+\dfrac{1}{2}z-\dfrac{1}{2}=0$ ។

**VII** គេមាន$f(x)=1+2\left(\dfrac{\ln x}{x}\right)$ ហើយមានក្រាប$C$

១. គណនា $\lim\limits_{x\to 0^+}f(x)$ និង $\lim\limits_{x\to+\infty}f(x)$

គេបាន $\lim\limits_{x\to 0^+}f(x)=\lim\limits_{x\to 0^+}\left[1+2\left(\dfrac{\ln x}{x}\right)\right]=1+2(-\infty)=-\infty$

$\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}\left[1+2\left(\dfrac{\ln x}{x}\right)\right]=1+2\times 0=1$

ដូចនេះ $\lim\limits_{x\to 0^+}f(x)=-\infty$ និង $\lim\limits_{x\to+\infty}f(x)=1$ ។

+ កំណត់សមីការអាស៊ីមតូតឈរនិងដេកនៃក្រាប$C$

ដោយ $\lim\limits_{x\to 0^+}f(x)=-\infty$

ដូចនេះ បន្ទាត់$x=0$ជាអាស៊ីមតូតឈរនៃក្រាប$C$ ។

ហើយ $\lim\limits_{x\to+\infty}f(x)=1$

ដូចនេះ បន្ទាត់$y=1$ជាអាស៊ីមតូតដេកនៃក្រាប$C$ ។

២. គណនាដេរីវេ$f'(x)$ និងសិក្សាសញ្ញានៃ$f'(x)$

គេបាន $f'(x)=2\times\dfrac{(\ln x)'x-(x)'\ln x}{x^2}=\dfrac{2-2\ln x}{x^2}$

ដូចនេះ $f'(x)=\dfrac{2-2\ln x}{x^2}$ ។

+សិក្សាសញ្ញានៃ$f'(x)$

បើ$f'(x)=0$

$\Leftrightarrow \dfrac{2-2\ln x}{x^2}$

$2-2\ln x=0$

$\ln x=1=\ln e$

$\Rightarrow x=e$

តារាងសញ្ញានៃ$f'(x)$

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |

• បើ $x\in(0,e)$ គេបាន $f'(x)>0$នោះ$f$ជាអនុគមន៍កើន

• បើ $x=e$គេបាន$f'(x)=0$នោះ$f$ជាអនុគមន៍ថេរ

• បើ $x\in(e,+\infty)$គេបាន$f'(x)<0$នោះ$f$ជាអនុគមន៍ចុះ ។

+សង់តារាងអថេរភាព

បើ $x=e\Rightarrow f(e)=1+2\left(\dfrac{\ln e}{e}\right)=1+\dfrac{2}{e}=1.7$ ជាតម្លៃអតិបរមា

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | ‖ | $+$ | $0$ | $-$ | |
| $f(x)$ | ‖ $-\infty$ | ↗ | $1.7$ | ↘ | $1$ |

៣. កំណត់កូអរដោនេនៃចំណុចប្រសព្វ$A$រវាងក្រាប$C$ និងបន្ទាត់$D:y=1$

គេបាន $f(x)=y$

$1+2\left(\dfrac{\ln x}{x}\right)=1$

$2\left(\dfrac{\ln x}{x}\right)=0$

$\dfrac{\ln x}{x}=0$

$\ln x=0=\ln 1$

$\Rightarrow x=1$

ដូចនេះ កូអរដោនេនៃចំណុចប្រសព្វ$A$រវាងក្រាប$C$ និងបន្ទាត់$D:y=1$គឺ $A(1,1)$ ។

+កំណត់សមីការបន្ទាត់$L$ដែលប៉ះនឹងក្រាប$C$ត្រង់ចំណុច$A$

គេមាន $A(1,1)\Rightarrow x_0=1, y_0=1$

តាម $L:y=f'(x_0)(x-x_0)+y_0$

ដោយ $f'(x_0)=f'(1)=\dfrac{2-2\ln 1}{1}=2$

គេបាន $L:y=2(x-1)+1=2x-2+1=2x-1$

ដូចនេះ សមីការបន្ទាត់ប៉ះគឺ$L:y=2x-1$ ។

៤. គណនា$f\left(\dfrac{1}{2}\right)$

គេបាន $f\left(\frac{1}{2}\right)=1+2\left(\frac{\ln\frac{1}{2}}{\frac{1}{2}}\right)=1+2(-0.7\times 2)=1-2.8=-1.8$

ដូចនេះ $f\left(\frac{1}{2}\right)=-1.8$ ។

+សង់បន្ទាត់$L$អាស៊ីមតូត និងក្រាប$C$នៅក្នុងតម្រុយតែមួយ

តារាងតម្លៃលេខ

| $x$ | $0$ | $1$ |
|---|---|---|
| $y=2x-1$ | $-1$ | $1$ |



**ក្រសួងអប់រំ យុវជន និងកីឡា**

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**

លេខបន្ទប់៖________ លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________ អក្សរសម្ងាត់

ហត្ថលេខា៖________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

$\frac{\quad}{125}$

# ៧

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី

រៀបរៀងដោយ៖ **រស់ មាន**

អក្សរសម្ងាត់

**I** គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to 1}\frac{x^7-1}{x^2-4x+3}$ ខ. $\lim\limits_{x\to 0}\frac{\sin^2 x}{1-\cos x}$ គ. $\lim\limits_{x\to 0}\frac{e^{2021x}-\cos 2020x}{\sin x}$

**II** នៅក្នុងថង់មួយមានឃ្លីព៌ណស ៤ គ្រាប់និងឃ្លីពណ៌ក្រហម ៥ គ្រាប់។ គេចាប់យកឃ្លី ៣ គ្រាប់ចេញពីថង់ដោយចៃដន្យ។ គណនាប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោមៈ

ក. $A$ "យកបានឃ្លីពណ៌ក្រហមទាំង ៣ គ្រាប់"

ខ. $B$ "យកបានឃ្លីពណ៌ស ២ គ្រាប់ និងពណ៌ក្រហម ១ គ្រាប់"

គ. $C$ "យ៉ាងតិចបានឃ្លីពណ៌ស ១ គ្រាប់"

**III** គណនាអាំងតេក្រាលខាងក្រោមៈ

ក. $\int(x^2+2x-3)dx$ ខ. $\int\frac{e^x}{1-e^x}dx$

គ. $\int \ln x dx$ ឃ. $\int\frac{1}{\cos x}dx$

**IV** គេឲ្យសមីការឌីផេរ៉ង់ស្យែល $(E): y''+y'-6y=(x+2)e^x$ ។

ក. ដោះស្រាយសមីការអូម៉ូហ្សែន $(F): y''+y'-6y=0$

ខ. រកចំនួនពិត $a, b$ ដើម្បីឲ្យ $y_p=(ax+b)e^x$ ជាចម្លើយពិសេសសមីការមិនអូម៉ូហ្សែន

គ. បង្ហាញថា $y=y_c+y_p$ ជាចម្លើយទូទៅសមីការ $(E)$ ដែល $y_c$ ជាចម្លើយទូទៅសមីការអូម៉ូហ្សែន និង $y_p$ ជាចម្លើយពិសេសសមីការមិនអូម៉ូហ្សែន រួចទាញរក $y$ ។

**V** គេឲ្យសមីការអេលីបមួយ $(E): 25x^2+9y^2-50x-90y+25=0$ ។

ក. សរសេរសមីការ $(E)$ ជាទម្រង់ស្តង់ដារ ។

ខ. គណនា ផ្ចិត កំពូល កំណុំ និងអ៊ិចសង់ទ្រីស៊ីតេរបស់អេលីប ។

គ. សង់អេលីប $(E)$ ក្នុងតម្រុយ $(O,\vec{i},\vec{j})$ ។

**VI** គេឲ្យអនុគមន៍ $f$ មួយកំណត់ដោយ $f(x)=x-\frac{2}{e^x-1}$ មានខ្សែកោង $C$ ។

ក. រកដែនកំណត់នៃអនុគមន៍ $f$ ។

ខ. សិក្សាលីមីតចុងដែនកំណត់ រួចរកអាស៊ីមតូតទាំងអស់នៃអនុគមន៍ $f$ ។

គ. គណនាដេរីវេ $f'(x)$ រួចសិក្សាសញ្ញាដេរីវេ ។

ឃ. សង់តារាងអថេរភាពនៃអនុគមន៍ $f$ ។

ង. សង់អាស៊ីមតូត និងក្រាប $C$ ក្នុងតម្រុយអរតូណរមេ $(O,\vec{i},\vec{j})$ ។

# ដំណោះស្រាយ

**I** គណនាលីមីតខាងក្រោម

ក. $\lim\limits_{x\to 1}\dfrac{x^7-1}{x^2-4x+3}$ រាងមិនកំណត់ $\dfrac{0}{0}$

$$\text{គេបាន} = \lim_{x\to 1}\frac{(x-1)(x^6+x^5+\cdots+x+1)}{x^2-x-3x+3}$$
$$= \lim_{x\to 1}\frac{(x-1)(x^6+x^5+\cdots+x+1)}{x(x-1)-3(x-1)}$$
$$= \lim_{x\to 1}\frac{(x-1)(x^6+x^5+\cdots+x+1)}{(x-1)(x-3)}$$
$$= \lim_{x\to 1}\frac{(x^6+x^5+\cdots+x+1)}{(x-3)}$$
$$= \frac{1^6+1^5+\cdots+1+1}{1-3} = -\frac{7}{2}$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\dfrac{x^7-1}{x^2-4x+3} = -\dfrac{7}{2}}$

ខ. $\lim\limits_{x\to 0}\dfrac{\sin^2 x}{1-\cos x}$ រាងមិនកំណត់ $\dfrac{0}{0}$

$$\text{គេបាន} = \lim_{x\to 0}\frac{\sin^2 x}{1-\cos x}$$
$$= \lim_{x\to 0}\frac{1-\cos^2 x}{1-\cos x}$$
$$= \lim_{x\to 0}\frac{(1-\cos x)(1+\cos x)}{1-\cos x}$$
$$= \lim_{x\to 0}(1+\cos x)$$
$$= (1+1) = 2$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{\sin^2 x}{1-\cos x} = 2}$

គ. $\lim\limits_{x\to 0}\dfrac{e^{2021x}-\cos 2020x}{\sin x}$ រាងមិនកំណត់ $\dfrac{0}{0}$

$$\text{គេបាន} = \lim_{x\to 0}\frac{e^{2021x}-1+1-\cos 2020x}{\sin x}$$
$$= \lim_{x\to 0}\left(\frac{e^{2021x}-1}{\sin x}+\frac{1-\cos 2020x}{\sin x}\right)$$
$$= \lim_{x\to 0}\left(\frac{e^{2021x}-1}{x}\times\frac{x}{\sin x}+\frac{2\sin^2 1010x}{\sin x}\right)$$
$$= \lim_{x\to 0}\left(\frac{2021(e^{2021x}-1)}{2021x}\times\frac{x}{\sin x}+\frac{2020\sin 1010x}{1010x}\times\frac{x}{\sin x}\times\sin 1010x\right)$$
$$= (2021\times 1+2020\times 1\times 1\times 0) = 2021$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\dfrac{e^{2021x}-\cos 2020x}{\sin x} = 2021}$

**II** គណនាប្រូបាបនៃព្រឹត្តិការណ៍

ក. $A$ "យកបានឃ្លីពណ៌ក្រហមទាំង 3 គ្រាប់"

* <u>ករណីអាច</u>

ដោយក្នុងថង់មានឃ្លីសរុប 9 គ្រាប់ គេចាប់យក 3 គ្រាប់ ចេញពីថង់ដោយចៃដន្យ

យើងបានចំនួនករណីអាច $n(S) = C(9,3) = \dfrac{9!}{(9-3)!3!}$

$$= \frac{9\times8\times7\times6!}{6!\times3\times2\times1}$$

$$= \frac{9\times8\times7}{3\times2\times1}$$

$$= 3\times4\times7 = 84 \quad Case$$

*ករណីស្រប

$A$ ជាព្រឹត្តិការណ៍យកបានឃ្លីពណ៌ក្រហមទាំង 3 គ្រាប់

ដោយក្នុងថង់មានឃ្លីក្រហម 5 គ្រាប់យើងចង់បានឃ្លីពណ៌ក្រហមទាំង 3 គ្រាប់

យើងបានចំនួនករណីស្រប $n(A) = C(5,3) = \dfrac{5!}{(5-3)!3!}$

$$= \frac{5\times4\times3!}{3!\times2\times1}$$

$$= \frac{5\times4}{2\times1}$$

$$= 5\times2 = 10 \quad Case$$

ដោយ$P(A) = \dfrac{n(A)}{n(S)} = \dfrac{10}{84} = \dfrac{5}{42}$

ដូចនេះ $\boxed{P(A) = \dfrac{5}{42}}$

ខ. $B$ ”យកបានឃ្លីពណ៌ស ២ គ្រាប់ និងពណ៌ក្រហម ១ គ្រាប់”

ដោយក្នុងថង់មានឃ្លីស 4 គ្រាប់និងឃ្លីក្រហម 5 គ្រាប់ ហើយយើងចង់បាន ឃ្លីពណ៌ស ២ គ្រាប់ និងពណ៌ក្រហម ១ គ្រាប់

យើងបាន $n(B) = C(4,2)\times C(5,1) = \dfrac{4!}{2!2!}\times\dfrac{5!}{4!1!}$

$$= \frac{4\times3\times2!}{2!\times2\times1}\times\frac{5\times4!}{4!\times1}$$

$$= 6\times5 = 30 \quad Case$$

ដោយ$P(B) = \dfrac{n(B)}{n(S)} = \dfrac{30}{84} = \dfrac{5}{14}$

ដូចនេះ $\boxed{P(B) = \dfrac{5}{14}}$

គ. $C$ ”យ៉ាងតិចបានឃ្លីពណ៌ស 1 គ្រាប់”

ដោយព្រឹត្តិការណ៍យ៉ាងតិចបានឃ្លីពណ៌ស 1 គ្រាប់ ជាព្រឹត្តិការណ៍ផ្ទុយជាមួយ ព្រឹត្តិការណ៍យកបានឃ្លីពណ៌ក្រហមទាំង 3 គ្រាប់

តាមប្រូបាបនៃព្រឹត្តិការណ៍ផ្ទុយ $P(C) = 1 - P(A)$

$$= 1 - \frac{5}{42} = \frac{37}{42}$$

ដូចនេះ $\boxed{P(C) = \dfrac{37}{42}}$

**III** គណនាអាំងតេក្រាលខាងក្រោម:

ក. $\displaystyle\int (x^2+2x-3)dx$

$= \int (x^2+2x-3)dx$

$= \int x^2dx + \int 2xdx - \int 3dx$

$= \frac{1}{3}x^3 + x^2 - 3x + C$

ដូចនេះ $\boxed{\int (x^2+2x-3)dx = \frac{1}{3}x^3 + x^2 - 3x + C, C \in \Re}$

ខ. $\int \frac{e^x}{1-e^x}dx$

$= -\int \frac{-e^x}{1-e^x}dx$

$= -\int \frac{(1-e^x)'}{1-e^x}dx$

$= -\ln|1-e^x| + C$

ដូចនេះ $\boxed{\int \frac{e^x}{1-e^x}dx = -\ln|1-e^x| + C, C \in \Re}$

គ. $\int \ln x dx$

តាមរូបមន្តអាំងតេក្រាលដោយផ្នែក $\int udv = uv - \int vdu$

តាង$u = \ln x => du = \frac{1}{x}dx$

$dv = dx => v = \int dx = x + c$

$\Leftrightarrow \int \ln x dx = x\ln x - \int x \cdot \frac{1}{x}dx$

$= x\ln x - \int dx$

$= x\ln x - x + C$

$= x(\ln x - 1) + C$

ដូចនេះ $\boxed{\int \ln x dx = x(\ln x - 1) + C, C \in \Re}$

ឃ. $\int \frac{1}{\cos x}dx$

$\int \frac{1}{\cos x}dx = \int \frac{\cos x}{\cos^2 x}dx$

$= \int \frac{\cos x}{1-\sin^2 x}dx$

$= \int \frac{\cos x}{(1-\sin x)(1+\sin x)}dx$

$* \frac{\cos x}{(1-\sin x)(1+\sin x)} = \frac{a\cos x}{(1-\sin x)} + \frac{b\cos x}{(1+\sin x)}$

$= \frac{a\cos x(1+\sin x) + b\cos x(1-\sin x}{(1-\sin x)(1+\sin x)}$

$\cos x = a\cos x + a\cos x\sin x + b\cos x - b\cos x\sin x$

$\cos x = (a+b)\cos x + (a-b)\cos x\sin x$

$$\Leftrightarrow + \begin{cases} a+b=1 & (1) \\ a-b=0 & (2) \end{cases}$$

$\Leftrightarrow \quad 2a+0=1$

$\Rightarrow \quad a=\frac{1}{2}, b=\frac{1}{2}$

$\Rightarrow \frac{\cos x}{(1-\sin x)(1+\sin x)}=\frac{\frac{1}{2}\cos x}{(1-\sin x)}+\frac{\frac{1}{2}\cos x}{(1+\sin x)}$

$$\Leftrightarrow \int \frac{1}{\cos x}dx=\int \frac{\frac{1}{2}\cos x}{(1-\sin x)}+\frac{\frac{1}{2}\cos x}{(1+\sin x)}dx$$
$$=\frac{1}{2}\int \frac{\cos x}{(1-\sin x)}dx+\frac{1}{2}\int \frac{\cos x}{(1+\sin x)}dx$$
$$=-\frac{1}{2}\int \frac{(1-\sin x)'}{(1-\sin x)}dx+\frac{1}{2}\int \frac{(1+\sin x)'}{(1+\sin x)}dx$$
$$=-\frac{1}{2}\ln|1-\sin x|+\frac{1}{2}\ln|1+\sin x|+C$$

ដូចនេះ $\boxed{\int \frac{1}{\cos x}dx=-\frac{1}{2}\ln|1-\sin x|+\frac{1}{2}\ln|1+\sin x|+C, C\in\Re}$

**IV** ក. ដោះស្រាយសមីការអូម៉ូហ្សែន $(F): y''+y'-6y=0$

$(F): y''+y'-6y=0$ មានសមីការសម្គាល់ $\lambda^2-\lambda+6=0$

$$\Delta=(1)^2+4\cdot 6=25$$
$$\Rightarrow \sqrt{\Delta}=5$$
$$\Rightarrow \lambda_1=\frac{-1-5}{2}=-3, \lambda_2=\frac{-1+5}{2}=2$$

តាម $y_c=Ae^{\lambda_1 x}+Be^{\lambda_2 x}$

យើងបានចម្លើយនៃសមីការ $F$ គឺ $y_c=Ae^{-3x}+Be^{2x} A, B\, is\, constance$

ខ. រកចំនួនពិត $a, b$ ដើម្បីឲ្យ $y_p=(ax+b)e^x$ ជាចម្លើយពិសេសសមីការមិនអូម៉ូហ្សែន

យើងមាន $y_p=(ax+b)e^x$

$$y_p'=ae^x+(ax+b)e^x=(ax+a+b)e^x$$
$$y_p''=ae^x+(ax+a+b)e^x=(ax+2a+b)e^x$$

ដើម្បីឲ្យ $y_p$ ជាចម្លើយពិសេសសមីការមិនអូម៉ូហ្សែនលុះត្រាតែ $y_p''+y_p'-6y_p=(x+2)e^x$

$\Leftrightarrow (ax+2a+b)e^x+(ax+a+b)e^x-6(ax+b)e^x=(x+2)e^x$

$$ax+2a+b+ax+a+b-6ax-6b=x+2$$
$$-4ax+3a-4b=x+2$$
$$\Leftrightarrow +\begin{cases}-4a=1\\ 3a-4b=2\end{cases}$$
$$\Rightarrow a=-\frac{1}{4}, b=-\frac{11}{16}$$

ដូចនេះ $a=-\frac{1}{4}, b=-\frac{11}{16}$ និង $y_p=(-\frac{1}{4}x-\frac{11}{16})e^x$

គ. បង្ហាញថា $y=y_c+y_p$ ជាចម្លើយទូទៅសមីការ $(E)$

ដោយ $y_c$ ជាចម្លើយទូទៅសមីការអូម៉ូហ្សែន

យើងបាន $\quad y_c''+y_c'-6y_c=0 \quad (1)$

និង $y_p$ ជាចម្លើយពិសេសសមីការមិនអូម៉ូហ្សែន

យើងបាន $y_p'' + y_p' - 6y_p = (x+2)e^x \quad (2)$

យក $(1),(2)$ យើងបាន

$$+\begin{cases} y_c'' + y_c' - 6y_c = 0 & (1) \\ y_p'' + y_p' - 6y_p = (x+2)e^x & (2) \end{cases}$$

$$y_c'' + y_p'' + y_c' + y_p' - 6y_c - 6y_p = (x+2)e^x$$

$$(y_c'' + y_p'') + (y_c' + y_p') - 6(y_c + y_p) = (x+2)e^x$$

គេបាន $y = y_c + y_p$ ផ្ទៀងផ្ទាត់សមីការ $(E)$

Therefore $y = y_c + y_p$ ជាចម្លើយទូទៅសមីការ $(E)$

$$y = y_c + y_p = Ae^{-3x} + Be^{2x} + \left(-\frac{1}{4}x - \frac{11}{16}\right)e^x$$

ដូចនេះ $\boxed{y = Ae^{-3x} + Be^{2x} - \left(\frac{1}{4}x + \frac{11}{16}\right)e^x \; A, B \; is \; constance}$

**V**

ក. សរសេរសមីការ $(E)$ ជាទម្រង់ស្តង់ដារ

យើងមានសមីការ

$$(E): 25x^2 + 9y^2 - 50x - 90y + 25 = 0$$

$$25x^2 - 50x + 25 + 9y^2 - 90y + 9 \times 5^2 - 9 \times 5^2 = 0$$

$$25(x^2 - 2x + 1) + 9(y^2 - 10y + 5^2) = 225$$

$$25(x-1)^2 + 9(y-5)^2 = 225$$

$$\frac{(x-1)^2}{9} + \frac{(y-5)^2}{25} = 1$$ ជាទម្រង់ស្តង់ដារសមីការអេលីប

ខ. គណនា ផ្ចិត កំពូល កំណុំ និងអ៊ិចសង់ទ្រីស៊ីតេរបស់អេលីប

ដោយអេលីប $(E) \; : \; \dfrac{(x-1)^2}{9} + \dfrac{(y-5)^2}{25} = 1$

មានទម្រង់ $\dfrac{(x-h)^2}{b^2} + \dfrac{(y-k)^2}{a^2} = 1$ មានអ័ក្សធំស្របអ័ក្សអរដោនេ

$\Rightarrow h = 1, k = 5, a = 5, b = 3$

$and \; c^2 = a^2 - b^2 = 5^2 - 3^2 = 16 \Rightarrow c = 4$

- ផ្ចិត $I(h,k) = (1,5)$

-កំពូល $V_1(h, k-a) = (1,0) \quad , \quad V_2(h, k+a) = (1,10)$

-កំណុំ $F_1(h, k-c) = (1,1) \quad , \quad F_2(h, k+c) = (1,9)$

-អ៊ិចសង់ទ្រីស៊ីតេ $e = \dfrac{c}{a} = \dfrac{4}{5} = 0.8$

គ. សង់អេលីប $(E)$ ក្នុងតម្រុយ $(O, \vec{i}, \vec{j})$



VI ក. រកដែនកំណត់នៃអនុគមន៍ $f$

$f(x)=x-\dfrac{2}{e^x-1}$ មានន័យកាលណា $e^x-1\neq 0$

$e^x\neq 1$

$e^x\neq e^0\Rightarrow x\neq 0$

$\therefore D=\Re-\{0\}$

ខ. សិក្សាលីមីតចុងដែនកំណត់ រួចរកអាស៊ីមតូតទាំងអស់នៃអនុគមន៍ $f$

$\triangleright \lim\limits_{x\to 0^+} f(x)=\lim\limits_{x\to 0^+}\left(x-\dfrac{2}{e^x-1}\right)$

$=0-\dfrac{2}{e^{0^+}-1}=-\dfrac{2}{0^+}$

$=-\infty$

$\triangleright \lim\limits_{x\to 0^-} f(x)=\lim\limits_{x\to 0^-}\left(x-\dfrac{2}{e^x-1}\right)$

$=0-\dfrac{2}{e^{0^-}-1}=-\dfrac{2}{0^-}$

$=+\infty$

$\triangleright \lim\limits_{x\to +\infty} f(x)=\lim\limits_{x\to +\infty}\left(x-\dfrac{2}{e^x-1}\right)$

$=+\infty-\dfrac{2}{e^{+\infty}-1}=+\infty-0$

$=+\infty$

$\triangleright \lim\limits_{x\to -\infty} f(x)=\lim\limits_{x\to -\infty}\left(x-\dfrac{2}{e^x-1}\right)$

$=-\infty-\dfrac{2}{e^{-\infty}-1}=-\infty-\dfrac{2}{0-1}$

$=-\infty+2=-\infty$

∘ដោយ $\lim\limits_{x\to 0} f(x)=\infty$ ដូចនេះបន្ទាត់ $x=0$ ជាអាស៊ីមតូតឈរ

∘ដោយ $\lim\limits_{x\to +\infty}\dfrac{-2}{e^x-1}=0$ដូចនេះបន្ទាត់ $y=x$ ជាអាស៊ីមតូតទ្រេត

∘ដោយ $\lim\limits_{x\to -\infty}\dfrac{-2}{e^x-1}=2$ដូចនេះបន្ទាត់ $y=x+2$ ជាអាស៊ីមតូតទ្រេត ។

គ. គណនាដេរីវេ $f'(x)$ រួចសិក្សាសញ្ញាដេរីវេ

$f(x)=x-\dfrac{2}{e^x-1}$

$f'(x)=1-\dfrac{-2(e^x-1)'}{(e^x-1)^2}$

$=1+\dfrac{2e^x}{(e^x-1)^2}$

$=\dfrac{(e^x-1)^2+2e^x}{e^x-1)^2}$

$=\dfrac{e^{2x}-2e^x+1+2e^x}{e^x-1)^2}$

$\therefore f'(x)=\dfrac{e^{2x}+1}{(e^x-1)^2}$

- សិក្សាសញ្ញាដេរីវេ

ដោយ $(e^{2x}+1),(e^x-1)^2 \geq 0\ \forall x \in D$

យើងបាន $f'(x) \geq\ \forall x \in D$

- គ្មានចំណុចបរមា

ឃ. សង់តារាងអថេរភាពនៃអនុគមន៍ $f$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ |
| $f(x)$ | $-\infty \nearrow +\infty$ | ‖ | $-\infty \nearrow +\infty$ |

ង. សង់អាស៊ីមតូត និងក្រាប $C$ ក្នុងតម្រុយអរតូណរមេ $(O, \vec{i}, \vec{j})$



**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________ | អក្សរសម្ងាត់ |

ហត្ថលេខា៖________

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

________ / 125

**៨**

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី

រៀបរៀងដោយ៖ **អឿន សំណាង**

| អក្សរសម្ងាត់ |

**I** គណនា លីមីត ខាងក្រោម ៖

១. $\lim\limits_{x\to 1}\dfrac{2x^2-3x+1}{\sqrt{x+3}-2}$ ២. $\lim\limits_{x\to 0}\dfrac{\sin 2x+e^x-1}{x+x^2}$ ៣. $\lim\limits_{x\to+\infty}\left(\sqrt{4x^2+3}-2x\right)$

**II** ១. កំណត់ចំនួនពិត $a$ និង $b$ ដោយដឹងថា $(3+2i)a+(2-i)b=4+5i$ ។

២. គេមាន $\alpha$ និង $\beta$ ជា ឬសនៃ សមីការ $x^2-2x+3=0$ ។

ចូរសរសេរ $z=1+\alpha^3-3\alpha^2+5\alpha-2+i(\beta^3-\beta^2+\beta+5)$ ជាទម្រង់ត្រីកោណមាត្រ ។

**III** គណនា អាំងតេក្រាលកំណត់ ខាងក្រោម ៖

១. $\int_{-1}^{1}\left(1-6x+3x^2\right)dx$ ២. $\int_{0}^{3}\left(2e^{2x}+e^x-1\right)dx$

៣. $\int_{0}^{\frac{\pi}{2}}(\sin x\cos^4 x)dx$ ៤. $\int_{0}^{1}\dfrac{x^2+x+1}{2x+3}dx$

**IV** គេមាន សមីការ $(E)\ : 2y''-y'-3y=0$ ។

ក. ដោះស្រាយ សមីការ $(E)$ ។

ខ. រកចម្លើយមួយនៃ $(E)$ ដោយដឹងថា ក្រាបនៃ អនុគមន៍ចម្លើយកាត់អ័ក្ស $(y'oy)$ ត្រង់$y=2$ ហើយបន្ទាត់ប៉ះក្រាបត្រង់ចំណុចនេះស្របទៅនឹង បន្ទាត់ $(L):\frac{1}{2}x+3$ ។

**V** រកកូអរដោនេ នៃ កំពូល កំណុំ សមីការបន្ទាត់ប្រាប់ទិស និង អ័ក្សឆ្លុះនៃប៉ារ៉ាបូល $x^2-4x+4y+12=0$ រួចសង់ក្រាប។

**VI** ក្នុងថង់មួយមានប៊ិចក្រហម 5 ដើម ប៊ិចខៀវ 8 ដើម និង ប៊ិចខ្មៅ 7 ដើម ។ គេចាប់យកប៊ិច 4 ដើមព្រមគ្នាដោយចៃដន្យចេញពីថង់ ។ គណនាប្រូបាប នៃព្រឹត្តការណ៍នីមួយៗ ខាងក្រោម ៖

១. $A=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 2 ដើម ។ ២. $B=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 3 ដើម ។

៣. $C=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 4 ដើម ។ ៤. $D=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 2 គូ ។

**VII** នៅក្នុងតម្រុយអរតូណរម៉ាល់$(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(0,4,-1)$; $B(-2,4,-5)$ ;$C(1,1,-5)$ ;$D(1,0,-4)$ និង $E(2,2,-1)$ ។

១. គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចបង្ហាញថា បីចំណុច $A;B;C$ កំណត់បានប្លង់មួយ ព្រមទាំងសរសេរសមីការប្លង់ $(ABC)$ ។

២. សរសេរ សមីការប៉ារ៉ាម៉ែត្រនៃ បន្ទាត់$(d)$កាត់តាម $C$ហើយស្របនឹងបន្ទាត់ $(DE):x-1=\dfrac{y}{2}=\dfrac{z+4}{3}$ ។

៣. រក កូអរដោនេចំណុចប្រសព្វ $M$ នៃបន្ទាត់ $(DE)$ និង ប្លង់ $(ABC)$ ។

៤. បង្ហាញថា ចំណុច $I(-1,2,-3)$ ជាផ្ចិតរបស់ស្វ៊ែរ ដែលស្វ៊ែរនោះ កាត់តាមចំណុច $A;B;C;D$ រួចសរសេរសមីការស្វ៊ែរនោះ។

**VIII** គេមានអនុគមន៍ $f$ កំណត់ដោយ$f(x)=x-\dfrac{2e^x}{e^x-1}$ មានក្រាប តំណាង $(C)$ ។

១. រកដែនកំណត់នៃ អនុគមន៍ ព្រមទាំងគណនា លីមីតត្រង់ចុងដែនកំណត់ រួចបញ្ជាក់អាស៊ីមតូចបើមាន ។

២. បង្ហាញថា $I(0,-1)$ ជាផ្ចិតឆ្លុះនៃ ខ្សែកោង ។

៣. បង្ហាញថា បន្ទាត់ $(d_1);y=x-2$និង $(d_2);y=x$ ជា អាស៊ីមតូចទ្រេតនៃ ក្រាប $(C)$ រួចសិក្សាទីតាំងធៀបនៃ $(d_1)$ $(d_2)$ ធៀបនឹង $(C)$ ។

៤. បង្ហាញថា $f$ ជា អនុគមន៍ម៉ូណូតូន គ្រប់ $x \neq 0$ និង សង់តារាងអថេរភាព នៃ $f$ ។

៥. សង់ អាស៊ីមតូតទាំង អស់ និង ក្រាប $(c)$ នៅក្នុងតម្រុយតែមួយ ។

៦. គណនា ផ្ទៃក្រឡាផ្ទៃក ប្លង់ ខ័ណ្ឌដោយខ្សែកោង $(C)$ និងបន្ទាត់ $(d_1)$ និង បន្ទាត់ $x = 2; x = 4$ ។

## ដំណោះស្រាយ

**I** គណនា លីមីត ៖

១. គេមាន $\lim\limits_{x\to 1} \dfrac{2x^2-3x+1}{\sqrt{x+3}-2}$ មានរាងមិនកំណត់ $\left(\dfrac{0}{0}\right)$

គេបាន $\lim\limits_{x\to 1} \dfrac{2x^2-3x+1}{\sqrt{x+3}-2} = \lim\limits_{x\to 1} \dfrac{2x^2-2x-x+1}{\sqrt{x+3}-2} \times \dfrac{\sqrt{x+3}+2}{\sqrt{x+3}+2}$

$$= \lim_{x\to 1} \frac{[2x(x-1)-(x-1)](\sqrt{x+3}+2)}{\sqrt{(x+3)^2}-2^2}$$

$$= \lim_{x\to 1} \frac{(x-1)(2x-1)(\sqrt{x+3}+2)}{x-1}$$

$$= \lim_{x\to 1}(2x-1)(\sqrt{x+3}+2)$$

$$= (2\times 1-1)(\sqrt{1+3}+2) = 4$$

ដូច្នេះ $\boxed{\lim\limits_{x\to 1} \dfrac{2x^2-3x+1}{\sqrt{x+3}-2} = 4}$

២. គេមាន $\lim\limits_{x\to 0} \dfrac{\sin 2x + e^x - 1}{x+x^2}$ មានរាងមិនកំណត់ $\left(\dfrac{0}{0}\right)$

គេបាន $\lim\limits_{x\to 0} \dfrac{\sin 2x + e^x - 1}{x+x^2} = \lim\limits_{x\to 0} \dfrac{\sin 2x}{x(1+x)} + \lim\limits_{x\to 0} \dfrac{e^x-1}{x(1+x)}$

$$= 2\lim_{x\to 0}\left(\frac{\sin 2x}{2x} \times \frac{1}{1+x}\right) + \lim_{x\to 0}\left(\frac{e^x-1}{x} \times \frac{1}{1+x}\right)$$

$$= 2\times 1 \times \frac{1}{1+0} + 1 \times \frac{1}{1+0} = 3$$

ដូច្នេះ $\boxed{\lim\limits_{x\to 0} \dfrac{\sin 2x + e^x - 1}{x+x^2} = 3}$

៣. គេមាន $\lim\limits_{x\to +\infty} \left(\sqrt{4x^2+3}-2x\right)$ រាងមិនកំណត់ $(+\infty-\infty)$

គេបាន $\lim\limits_{x\to +\infty} \left(\sqrt{4x^2+3}-2x\right) = \lim\limits_{x\to +\infty} \dfrac{\left(\sqrt{4x^2+3}-2x\right)\left(\sqrt{4x^2+3}+2x\right)}{\left(\sqrt{4x^2+3}+2x\right)}$

$$= \lim_{x\to +\infty} \frac{\left[\sqrt{(4x^2+3)^2}-(2x)^2\right]}{\sqrt{4x^2+3}+2x}$$

$$= \lim_{x\to +\infty} \frac{3}{\sqrt{4x^2\left(1+\frac{3}{4x^2}\right)}+2x}$$

$$= \lim_{x\to +\infty} \frac{3}{2|x|\sqrt{1+\frac{3}{4x^2}}+2x} \quad ; \text{ពេល} x \to +\infty \text{ នោះ } |x| = x$$

$$= \lim_{x\to +\infty} \frac{3}{2x\left(\sqrt{1+\frac{3}{4x^2}}+1\right)}$$

$$= \frac{3}{2(+\infty)(\sqrt{1+0}+1)} = 0 \text{ ព្រោះ } \lim_{x\to+\infty}\frac{3}{4x^2} = 0$$

ដូច្នេះ $\boxed{\lim_{x\to+\infty}\left(\sqrt{4x^2+3}-2x\right)=0}$

**II** ១. កំណត់ចំនួនពិត $a$ និង $b$ ៖

គេមាន $(3+2i)a+(2-i)b = 4+5i$

$$\Leftrightarrow 3+2ai+2b-bi = 4+5i$$

$$\Leftrightarrow (3a+2b)+(2a-b) = 4+5i$$

$$\Leftrightarrow \begin{cases} 3a+2b &= 4 \\ 2a-b &= 5 \end{cases}$$

$$\Leftrightarrow a = 2 \text{ និង } b = -1$$

ដូច្នេះ $\boxed{a = 2 \text{ និង } b = -1}$

២. សរសេរ $z$ ជា ទម្រង់ត្រីកោណមាត្រ ៖

គេមាន $\alpha$ និង $\beta$ ជាឫសនៃ សមីការ $x^2-2x+3=0$

គេបាន $\begin{cases} \alpha^2-2\alpha+3=0 \\ \beta^2-2\beta+3=0 \end{cases} \Leftrightarrow \begin{cases} \alpha^2 = 2\alpha-3 \\ \beta^2 = 2\beta-3 \end{cases}$

ដោយ $z = 1+\alpha^3-3\alpha^2+5\alpha-2+i(\beta^3-\beta^2+\beta+5)$

$$= 1+\alpha\times\alpha^2-3\alpha^2+5\alpha-2+i(\beta\times\beta^2-\beta^2+\beta+5)$$

$$= 1+\alpha(2\alpha-3)-3(2\alpha-3)+5\alpha-2+i\,[\beta(2\beta-3)-(2\beta-3)+\beta+5]$$

$$= 1+2\alpha^2-3\alpha-6\alpha+9+5\alpha-2+i(2\beta^2-3\beta-2\beta+3+\beta+5)$$

$$= 8-4\alpha+2(2\alpha-3)+i[2(2\beta-3)-4\beta+8]$$

$$= 2+2i$$

$$= 2\sqrt{2}\left(\frac{\sqrt{2}}{2}+\frac{\sqrt{2}}{2}i\right)$$

$$= 2\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)$$

ដូច្នេះ $\boxed{z = 2\sqrt{2}}$

$$\int_a^b f(x)dx = F(x)\Big|_a^b = F(b)-F(a)$$

**III** គណនា អាំងតេក្រាលកំណត់ ខាងក្រោម ៖

១. គណនា $\int_{-1}^{1}(1-6x+3x^2)dx$

គេមាន $\int_{-1}^{1}(1-6x+3x^2)dx = \left(x-3x^2+x^3\right)\Big|_{-1}^{1}$

$$= [1-3(1)^2+1^3]-[-1-3(-1)^2+(-1)^3]$$

$$= 4$$

ដូច្នេះ $\boxed{\int_{-1}^{1}(1-6x+3x^2)dx = 4}$

២. គណនា $\int_0^3 \left(2e^{2x}+e^x-1\right)dx$

គេមាន $\int_0^3 \left(2e^{2x}+e^x-1\right)dx = \left(e^{2x}+e^x-x\right)\Big|_0^3$

$$= \left(e^{2\times3}+e^3-3\right)-\left(e^{2\times0}+e^0-0\right)$$

$$= e^6+e^3-5$$

ដូច្នេះ $\boxed{\int_0^3 \left(2e^{2x}+e^x-x\right)dx = e^6+e^3-5}$

៣. គណនា $\int_0^{\frac{\pi}{2}} \left(\sin x cos^4 x\right)dx$

តាង $u=\cos x \Rightarrow du = -\sin x dx$

ពេល$x=0 \Rightarrow u=1\,; x=\dfrac{\pi}{2} \Rightarrow u=0$

គេបាន $\int_0^{\frac{\pi}{2}} \left(\sin x cos^4 x\right)dx = -\int_1^0 u^4 du$ ;សម្គាល់ $\boxed{\int_a^b f(x)dx = -\int_b^a f(x)dx}$

$$= \int_0^1 u^4 du = \left(\frac{u^5}{5}\right)\Big|_0^1 = \frac{1}{5}$$

ដូច្នេះ $\boxed{\int_0^{\frac{\pi}{2}} \left(\sin x cos^4 x\right)dx = \dfrac{1}{5}}$

៤. គណនា $\int_0^1 \dfrac{x^2+x+1}{2x+3}dx$

គេមាន $\int_0^1 \dfrac{x^2+x+1}{2x+3}dx = \int_0^1 \left(\dfrac{1}{2}x-\dfrac{1}{4}+\dfrac{7}{4(2x+3)}\right)dx$

$$= \left[\frac{x^2}{4}-\frac{1}{4}x+\frac{7}{8}\ln(2x+3)\right]\Big|_0^1$$

$$= \left(\frac{1}{4}-\frac{1}{4}+\frac{7}{8}\ln 5\right)-\left(\frac{7}{8}\ln 3\right)$$

$$= \frac{7}{8}\ln\frac{5}{3}$$

$$\begin{array}{rr|l} & x^2+x+1 & 2x+\;\;3 \\ \cline{3-3} - & x^2+\frac{3}{2}x & \frac{1}{2}x-\frac{1}{4} \\ \cline{2-2} & \frac{x}{2}+1 & \\ - & -\frac{x}{2}-\frac{3}{4} & \\ \cline{2-2} & \frac{7}{4} & \end{array}$$

ដូច្នេះ $\boxed{\int_0^1 \dfrac{x^2+x+1}{2x+3}dx = \dfrac{7}{8}\ln\dfrac{5}{3}}$

**IV**

១. ដោះស្រាយសមីការ $(E)$ ៖

សមីការសម្គាល់ $2\lambda^2-\lambda-3=0$

គេបាន $\lambda_1=-1 \;\; \lambda_2=\dfrac{3}{2}$

$\boxed{\text{យើងបាន } y=Ae^{-x}+Be^{\frac{3}{2}x}\,;\, A;B \text{ ជាចំនួនថេរ}}$




២. រកចម្លើយមួយនៃ $(E)$

គេមាន $y=Ae^{-x}+Be^{\frac{3}{2}x} \Rightarrow y' = -Ae^{-x}+\dfrac{3}{2}Be^{\frac{3}{2}x}$

ដោយដឹងថាក្រាបនៃ អនុគមន៍ចម្លើយកាត់អ័ក្ស $(y'oy)$

ត្រង់ $y=2$ ហើយបន្ទាត់ប៉ះ

ក្រាបត្រង់ចំណុចនេះស្របទៅនឹង បន្ទាត់ $(L): \dfrac{1}{2}x+3$

គេបាន $\begin{cases} f(0)=2 \\ f'(0)=\dfrac{1}{2}\end{cases} \Leftrightarrow \begin{cases} A+B=2 \\ -A+\dfrac{3}{2}B=\dfrac{1}{2}\end{cases} \Rightarrow A=B=1$

ដូច្នេះ $\boxed{y=e^{-x}+e^{\frac{3}{2}x} \text{ ជាចម្លើយមួយនៃសមីការ (E)}}$

**V** រកកូរកូអរដោនេ នៃ កំពូល កំណុំ សមីការបន្ទាត់ប្រាប់ទិស និង អ័ក្សឆ្លុះ នៃ ប៉ារ៉ាបូល ៖

គេមាន$x^2-4x+4y+12=0 \Leftrightarrow x^2-4x+4=-4y-12+4$

$\Leftrightarrow (x-2)^2=-4(y+2)$ គេបានប៉ារ៉ាបូលមានអ័ក្សឆ្លុះឈរ

$$\Leftrightarrow \begin{cases}(x-2)^2=-4(y+2)\\(x-h)^2=4p(y-k)\end{cases} \Leftrightarrow h=2\,;\,k=-2\,;4p=-4 \Rightarrow p=-1$$

- កំពូល $V(h,k)=V(2,-2)$
- កំណុំ $F(h,k+p)=F(2,-2-1)$
  $=F(2,-3)$
- សមីការបន្ទាត់ប្រាប់ទិស $(\Delta): y=k-p$
  $=-2-(-1)$
  $=-1$
- អ័ក្សឆ្លុះឈរគឺ $x=h=2$
- ក្រាបនៃ អនុគមន៍ $x^2-4x+4y+12=0$
  យក $y=-3 \Leftrightarrow x=0\,;\,x=4 \Leftrightarrow y=-3$




**VI** រកប្រូបាបនៃ ព្រឹត្តការណ៍ ខាងក្រោម ៖

១. $A=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 2 ដើម
ដោយ $n(S)=C(20,4)=\dfrac{20!}{(20-4)!4!}=\dfrac{20\times19\times18\times17\times16!}{16!4!}=15\times19\times17 \quad =4845$

តាមរូបមន្ត : $P(A)=\dfrac{n(A)}{n(S)}$

$$=\frac{C(5,2)\times C(8,1)\times C(7,1)+C(5,1)\times C(8,2)\times C(7,1)+C(5,1)\times C(8,1)\times C(7,2)}{C(20,4)}$$

$=\dfrac{28}{57}$

ដូច្នេះ $\boxed{P(A)=\dfrac{112}{969}}$

២. $B=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 3 ដើម

$$\text{តាមរូបមន្ត } : P(B)=\frac{n(B)}{n(S)}=\frac{C(5,3)\times C(15,1)+C(8,3)\times C(12,1)+C(7,3)\times C(13,1)}{C(20,4)}$$
$$=\frac{1277}{4845}$$

ដូច្នេះ $\boxed{P(B)=\frac{1277}{4845}}$

៣. $C=$ចាប់បានប៊ិចមានពណ៌ ដូចគ្នា 4 ដើម

$$\text{តាមរូបមន្ត } : P(C)=\frac{n(C)}{n(S)}=\frac{C(5,4)+C(8,4)+C(7,4)}{C(20,4)}$$
$$=\frac{22}{969}$$

ដូច្នេះ $\boxed{P(C)=\frac{22}{969}}$

៤. $D$ : ចាប់បានប៊ិចមានពណ៌ដូចគ្នា 2គូ

ដោយព្រឹត្តការណ៍នៃការចាប់បានប៊ិចមានពណ៌ ដូចគ្នា 2គូ គឺមានន័យថា ចាប់បានប៊ិចមានពណ៌ដូចគ្នា 4ដើម

ដូច្នេះ $\boxed{P(D)=P(C)=\frac{22}{969}}$

**VII** ១. គណនា $\overrightarrow{AB}\times\overrightarrow{AC}$

គេមាន $A(0,4,-1)$ ; $B(-2,4,-5)$ ; $C(1,1,-5)$

+ តាមរូបមន្ត $\overrightarrow{AB}=(x_B-x_A,y_B-y_A,z_B-z_A)=(-2-0,4-4,-5-(-1))=(-2,0,-4)$
+ តាមរូបមន្ត $\overrightarrow{AC}=(x_C-x_A,y_C-y_A,z_C-z_A)=(1-0,1-4,-5-(-1))=(1,-3,-4)$

$$\text{គេបាន}\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -2 & 0 & -4\\ 1 & -3 & -4\end{vmatrix}=\begin{vmatrix}0 & -4\\ -3 & -4\end{vmatrix}\vec{i}-\begin{vmatrix}-2 & -4\\ 1 & -4\end{vmatrix}\vec{j}+\begin{vmatrix}-2 & 0\\ 1 & -3\end{vmatrix}\vec{k}$$
$$=[0(-4)-(-3)(-4)]\vec{i}-[(-2)(-4)-1(-4)]\vec{j}+[(-2)(-3)-1(0)]\vec{k}$$
$$=-12\vec{i}-12\vec{j}+6\vec{k}$$

ដូច្នេះ $\boxed{\overrightarrow{AB}\times\overrightarrow{AC}=-12\vec{i}-12\vec{j}+6\vec{k}}$

+ ដោយ$\overrightarrow{AB}\times\overrightarrow{AC}=\neq\vec{0}$ នោះគេបានចំណុចទាំងបីរត់មិនត្រង់ជួរកំណត់បានប្លង់$(ABC)$មួយ។
+ សរសេរសមីការប្លង់ $(ABC)$ តាមរូបមន្តសមីការប្លង់ $(ABC):a(x-x_0)+b(y-y_0)+c(z-z_0)=0$

- វ៉ិចទ័រណ័រម៉ាល់នៃប្លង់$(ABC)$ : $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(-12,-12,6)$
- យក$A(0,4,-1)$ ជាចំណុចកាត់របស់ប្លង់$(ABC)$គេបាន $x_0=0$ ; $y_0=4$ ; $z_0=-1$

គេបាន$(ABC):-12(x-0)-12(y-4)+6(z+1)=0 \quad \Leftrightarrow 2x+2y-z-9=0$

ដូច្នេះ $\boxed{(ABC):2x+2y-z-9=0}$

២. សរសេរសមីការប៉ារ៉ាម៉ែត្រនៃ បន្ទាត់ $(d)$

$$\text{តាមរូបមន្ត}: (d):\begin{cases}x=x_0+at\\ y=y_0+bt\\ z=z_0+ct\end{cases} ;t\in\mathbb{R}$$

+បម្រាប់:$(d)$កាត់តាម $C(1,1,-5)$ គេបាន $x_0=1$ ; $y_0=1$ ; $z_0=-5$

+$(d)$ស្របនឹង$(DE): x-1=\dfrac{y}{2}=\dfrac{z+4}{3}$គេបាន $\vec{u}_d=\vec{u}_{(DE)}=(1,2,3)$

ដូច្នេះ $(d):\begin{cases} x=1+t \\ y=1+2t \quad ;t\in\mathbb{R} \\ z=-5+3t \end{cases}$

៣. រកកូអរដោនេចំណុចប្រសព្វ $M(x_M,y_M,z_M)$នៃ បន្ទាត់ $(DE)$និង ប្លង់ $(ABC)$

យើងមានសមីការប្លង់$(ABC): 2x+2y-z-9=0$

សមីការឆ្លុះ$(DE): x-1=\dfrac{y}{2}=\dfrac{z+4}{3} \Rightarrow$ សមីការប៉ារ៉ាម៉ែត្រ$(DE):\begin{cases} x=1+t' \\ y=2t' \quad ;t'\in\mathbb{R} \\ z=-4+3t' \end{cases}$

$+M\in(DE)\Leftrightarrow \begin{cases} x_M=1+t' \\ y_M=2t' \quad ;t'\in\mathbb{R} \\ z_M=-4+3t' \end{cases}$

$+M\in(ABC)\Leftrightarrow 2x_M+2y_M-z_M=9=0$

$\Leftrightarrow 2(1+t')+2(2t')-(-4+3t)-9=0 \Rightarrow t'=1 \Rightarrow \begin{cases} x_M=1+1=2 \\ y_M=2(1)=2 \\ z_M=-4+3(1)=-1 \end{cases}$

ដូច្នេះ កូអរដោនេនៃMគឺ$M(2,2,-1)$

៤. បង្ហាញថាចំណុច $I(-1,2,-3)$ជាផ្ចិតរបស់ស្វ៊ែរ

ដោយស្វ៊ែរកាត់តាម $A$ ;$B$ ;$C$និង$D$នោះដើម្បីឲ្យ$I$ជាផ្ចិតរបស់ស្វ៊ែរលុះត្រាតែ$IA=IB=IC=ID$

+ $IA=\sqrt{(0+1)^2+(4-2)^2+(-1+3)^2}=3$ឯកតាប្រវែង

+ $IB=\sqrt{(-2+1)^2+(4-2)^2+(-5+3)^2}=3$ឯកតាប្រវែង

+ $\sqrt{(1+1)^2+(1-2)^2+(-5+3)^2}=3$ឯកតាប្រវែង

+ $\sqrt{(1+1)^2+(0-2)^2+(-4+3)^2}=3$ឯកតាប្រវែង

ដោយ $IA=IB=IC=ID$

ដូច្នេះ ចំណុច$I(-1,2,-3)$ជាផ្ចិតរបស់ស្វ៊ែរ

+សរសេរសមីការស្វ៊ែរ$(S)$

តាមរូបមន្ត$(S): (x-a)^2+(y-b)^2+(z-c)^2=r^2$

- បម្រាប់: $I(a,b,c)=I(-1,2,-3)$ $r=IA=3$

  ដូច្នេះ $(S): (x+1)^2+(y-2)^2+(z+3)^2=9$

VIII

១. + $f(x)$ មានន័យកាលណា $e^x-1\neq 0 \Leftrightarrow x\neq 0$

ដូច្នេះ $D=(-\infty,0)\cup(0,+\infty)$

+ គណនាលីមីតត្រង់ចុងដែនកំណត់

- $\lim\limits_{x\to-\infty} f(x)=\lim\limits_{x\to-\infty}\left(x-\dfrac{2e^x}{e^x-1}\right)=+\infty-\dfrac{2((0)}{0-1}=\boxed{-\infty}$ ព្រោះ $\lim\limits_{x\to+\infty} e^x=0$

- $\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\left(x - \frac{2e^x}{e^x-1}\right) = \lim_{x\to+\infty}\left(x - \frac{2e^x}{e^x\left(1-\frac{1}{e^x}\right)}\right)$
  $= \lim_{x\to+\infty}\left(x - \frac{2}{1-\frac{1}{e^x}}\right) = \boxed{+\infty}$ ព្រោះ $\lim_{x\to+\infty}\frac{1}{e^x} = 0$
- $\lim_{x\to0^+} f(x) = \lim_{x\to0^+}\left(x - \frac{2e^x}{e^x-1}\right) = 0 - \frac{2(e^0)}{e^{0^+}-1} = -\frac{2}{0^+} = \boxed{-\infty}$ ព្រោះ $\frac{2}{0^+} = +\infty$
- $\lim_{x\to0^-} f(x) = \lim_{x\to0^-}\left(x - \frac{2e^x}{e^x-1}\right) = 0 - \frac{2(e^0)}{e^{0^-}-1} = -\frac{2}{0^-} = \boxed{+\infty}$ ព្រោះ $\frac{2}{0^-} = -\infty$

\+ បញ្ជាក់អាស៊ីមតូត

- ដោយ $\lim_{x\to0} f(x) = \infty$ នោះគេបានបន្ទាត់ $\boxed{x=0}$ ជាអាស៊ីមតូតឈរនៃ ខ្សែកោង ។

២. បង្ហាញថា $I(0,-1)$ ជាផ្ចិតឆ្លុះនៃខ្សែកោង

តាមរូបមន្ត: $f(2a-x)+f(x) = 2b$ ; $I(0,-1) \Leftrightarrow a=0$ ; $b=-1$

\+ មាន $f(x) = x - \frac{2e^x}{e^x-1} \Rightarrow f(2\times0-x) = f(-x) = -x - \frac{2e^{-x}}{e^{-x}-1} = -x - \frac{2}{1-e^x}$

គេបាន$f(2\times0-x)+f(x) = 2\times(-1) \Leftrightarrow f(-x)+f(x) = -2$

$$\Leftrightarrow -x - \frac{2}{1-e^x} + x - \frac{2e^x}{e^x-1} = -\frac{2}{1-e^x} + \frac{2e^x}{1-e^x} = -2\left(\frac{1-e^x}{1-e^x}\right) = -2$$ ពិត

៣. + បង្ហាញថា $(d_1): y = x-2$ ជាអាស៊ីមតូតទ្រេតនៃ $(C)$

គេមាន $(C): f(x) = x - \frac{2e^x}{e^x-1}$ ; $(d_1): y = x-2$

យក $f(x)-y = x - \frac{2e^x}{e^x-1} - x + 2 = \frac{-2e^x+2e^x-2}{e^x-1} = \frac{2}{1-e^x}$ និង $\lim_{x\to+\infty}\frac{2}{1-e^x} = 0$

ដូច្នេះ $\boxed{\text{បន្ទាត់}(d_1): y = x-2\text{ជាអាស៊ីមតូតទ្រេតនៃ}(C)\text{ខាង}x\to+\infty}$

\+ បង្ហាញថា $(d_2): y = x$ ជាអាស៊ីមតូតទ្រេតនៃ $(C)$

យក $f(x)-y = x - \frac{2e^x}{e^x-1} - x = \frac{2e^x}{1-e^x}$ និង $\lim_{x\to-\infty}\frac{2e^x}{1-e^x} = \frac{2\times0}{1-0} = 0$

ដូច្នេះ $\boxed{\text{បន្ទាត់}(d_2): y = x\text{ជាអាស៊ីមតូតទ្រេតនៃ}(C)\text{ខាង}x\to-\infty}$

\+ សិក្សាទីតាំងរវាង $(C)$ និង $(d_1)$ ; $(d_2)$

- សិក្សាទីតាំងធៀបរវាង $(C)$និង$(d_1)$

  មាន $f(x)-y = \frac{2}{1-e^x}$ដោយ $2>0$នោះ $\frac{2}{1-e^x}$មានសញ្ញាតាម $1-e^x$

  $1-e^x>0 \Leftrightarrow x<0$ ; $1-e^x<0 \Leftrightarrow x>0$

| $x$ | $-\infty$ | $0$ | $+\infty$ |
|---|---|---|---|
| $f(x)-y$ | $+$ | ‖ | $-$ |

  +ចំពោះ $x\in(-\infty,0) \Rightarrow f(x)-y>0$ នោះខ្សែកោង$(C)$នៅលើ $(d_1)$

  +ចំពោះ $x\in(0,+\infty) \Rightarrow f(x)-y<0$ នោះខ្សែកោង$(C)$នៅក្រោម $(d_1)$

- សិក្សាទីតាំងធៀបរវាង $(C)$និង$(d_2)$

  មាន $f(x)-y = \frac{2e^x}{1-e^x}$ដោយ $2e^x>0$នោះ $\frac{2}{1-e^x}$មានសញ្ញាតាម $1-e^x$

  $1-e^x>0 \Leftrightarrow x<0$ ; $1-e^x<0 \Leftrightarrow x>0$

| $x$ | $-\infty$ $\qquad$ $0$ $\qquad$ $+\infty$ |
|---|---|
| $f(x)-y$ | $+$ ‖ $-$ |

+ចំពោះ $x\in(-\infty,0)\Rightarrow f(x)-y>0$ នោះខ្សែកោង$(C)$នៅលើ $(d_2)$

+ចំពោះ $x\in(0,+\infty)\Rightarrow f(x)-y<0$ នោះខ្សែកោង$(C)$នៅក្រោម $(d_2)$

៤. បង្ហាញថា $f$ ជាអនុគមន៍ម៉ូណូតូន ចំពោះ $x\neq 0$

មាន$f(x)=x-\dfrac{2e^x}{e^x-1}\Rightarrow f'(x)=1-2\left[\dfrac{e^x(e^x-1)-e^x\times e^x}{(e^x-1)^2}\right]=1+\dfrac{2e^x}{(e^x-1)^2}>0\,;\,\forall x\neq 0$

ដោយ$f'(x)>0$នោះ $f(x)$ជាអនុគមន៍កើន នាំឲ្យ$f(x)$ជាអនុគមន៍ម៉ូណូតូន

តារាងអថេរភាព

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | |
| $f(x)$ | $-\infty$ ↗ | $+\infty$ | ‖ | $-\infty$ ↗ | $+\infty$ |

៥. សង់ក្រាប និង គ្រប់អាសុីមតូតទាំងអស់

+ $(d_1): y=x-2$ ;

| $x$ | $0$ | $1$ |
|---|---|---|
| $y$ | $-2$ | $-1$ |

;$(d_2): y=x$

| $x$ | $0$ | $1$ |
|---|---|---|
| $y$ | $0$ | $1$ |



៦. គណនា ផ្ទៃក្រឡាផ្នែក ប្លង់ ខណ្ឌដោយខ្សែកោង $(C)$ និងបន្ទាត់ $(d_1)$ និង បន្ទាត់ $x=2\,;x=4$ ។

យើងដឹងហើយថា $x\in(0,+\infty)$បន្ទាត់$(d_1): y=x-2$នៅលើខ្សែកោង $(C)$នោះ

គេបាន $x\in[2,4]$បន្ទាត់$(d_1)$ ក៏នៅលើខ្សែកោង$(C)$ដែរ

គេបាន $S=\int_2^4\left[x-2-x+\frac{2e^x}{e^x-1}\right]dx=\int_2^4\left(\frac{2e^x}{e^x-1}-2\right)dx=\left[2\ln(e^x-1)-2x\right]_2^4$

$$=2\ln(e^4-1)-8-2\ln(e^2-1)+4$$

$$=2\ln\left(\frac{e^4-1}{e^2-1}\right)-4$$

ដូច្នេះ $\boxed{S=2\ln\left(\frac{e^4-1}{e^2-1}\right)-4 \text{ ឯកតាផ្ទៃ}}$

**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________ អក្សរសម្ងាត់

ហត្ថលេខា៖________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

$\frac{\quad}{125}$ **៩**

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី អក្សរសម្ងាត់

រៀបរៀងដោយ៖ Kim Hun

**I** (**១៥ពិន្ទុ**) គេឲ្យពីរចំនួនកុំផ្លិច $z_1 = 2i(\cos\frac{\pi}{6} + i\sin\frac{\pi}{6})$ និង $z_2 = 2i(\cos\frac{\pi}{6} - i\sin\frac{\pi}{6})$ ។

ក. សរសេរ $z_1$ និង $z_2$ ជាទម្រង់ពីជគណិត ។ ខ. ចូរបង្កើតសមីការដឺក្រេទី 2 នៃ $z$ ដែលមាន $z_1$ និង $z_2$ ជាឬស ។

គ. កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យ $z_1^3 + z_2^3 = 2(x+1) + i(y-3)$ ។

**II** (**១៥ពិន្ទុ**) គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to -1}\frac{1+x}{\sqrt{x^2+3}-2}$ ខ. $\lim\limits_{x\to 0^+}(\frac{1}{x} + \ln x)$ គ. $\lim\limits_{x\to +\infty}(x - e^x + \ln x)$

**III** ១. (**៥ពិន្ទុ**) ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $E:\ g''(x) - 7g'(x) + 10g(x) = 0$ ។

២. (**៥ពិន្ទុ**) កំណត់ចម្លើយ $g(x)$ មួយនៃ $E$ ដែល $g(0) = 5\ ;\ g'(0) = 16$ ។

**IV** (**១៥ពិន្ទុ**) ថង់មួយមានបាល់ក្រហម 8 បាល់ស 5 ។បាល់ 3 ត្រូវបានយកចេញដោយចៃដន្យ។ គណនាប្រូបាបនៃព្រឹត្តិការណ៍ដូចខាងក្រោម៖

ក. $A$ : បាល់ទាំង 3 ពណ៌ស ។ ខ. $B$ : បាល់ទាំង3ពណ៌ក្រហម ។ គ. $C$ : បាល់ស2និងបាល់ក្រហម1 ។

**V** (**១០ពិន្ទុ**) គេឲ្យអនុគមន៍ $f(x) = \frac{x+1}{x^2-3x+2}\quad ;\quad x\neq 1\ ,\ x\neq 2$ ។

១. សរសេរ $f$ ជារាង $f(x) = \frac{a}{x-1} + \frac{b}{x-2}$ ដែល $a\,,b$ ជាចំនួនពិតត្រូវកំណត់ ។

២. គណនា $\int_0^3 f(x)dx$

**VI** (**៣៥ពិន្ទុ**) គេឲ្យអនុគមន៍ $f$ កំណត់លើ$\mathbb{R}$ ដោយ $f(x) = x + 2 + (x+1)e^{-x}$ មានក្រាបតំណាង $C$ ។

១. គណនាលីមីតនៃ $f$ ខាង $+\infty$ និង $-\infty$ ។

២. គណនា $f'(x)$ ។

៣. ដោយដឹងថា $1 - xe^{-x} > 0$ ចូរសិក្សាសញ្ញានៃ $f'(x)$ រួចគូសតារាងអថេរភាពនៃ $f$ ។

៤. បង្ហាញថាបន្ទាត់ $\Delta : y = x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$ ។

សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងអាស៊ីមតូតទ្រេតនេះ ។

៥. សង់បន្ទាត់ $\Delta$ និង ក្រាប $C$ ក្នុងតម្រុយតែមួយ ។

**VII** (**២៥ពិន្ទុ**)នៅក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(O;\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(2,1,4)\,;B(2,-2,7)$ និង ប្លង់ $P : 2x + 2y - z = 2$ ។

១. កំណត់សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $L$ ដែលកាត់តាម $B$ ហើយកែងនឹងប្លង់ $P$ ។

២. បន្ទាត់ $D$ មួយមានសមីការ $x = 1 + 2t\ ;\ y = -2t\ ;\ z = 1 - t\ ;\ \ (t\in\mathbb{R})$ ។

ចូរកំណត់កូអរដោនេចំណុចប្រសព្វ $M$ រវាង $D$ និង $P$ ។

៣. ចូរគណនាផ្ទៃក្រឡានៃត្រីកោណ $MAB$ ។

# ដំណោះស្រាយ

**I** ក. (**៥ពិន្ទុ**) សរសេរ $z_1$ និង $z_2$ ជាទម្រង់ពីជគណិត

ដោយ $z_1 = 2i(\cos\frac{\pi}{6} + i\sin\frac{\pi}{6}) = 2i(\frac{\sqrt{3}}{2} + \frac{1}{2}i) \quad = -1 + \sqrt{3}i$

ដោយ $z_2 = 2i(\cos\frac{\pi}{6} - i\sin\frac{\pi}{6}) = 2i(\frac{\sqrt{3}}{2} - \frac{1}{2}i) \quad = 1 + \sqrt{3}i$

ខ. (**៥ពិន្ទុ**)ចូរបង្កើតសមីការដឺក្រេទី 2 នៃ $z$ ដែលមាន $z_1$ និង $z_2$ ជាឫស

សមីការដឺក្រេទី២មានរាង $Z^2 - SZ + P = 0$

ដោយ $S = z_1 + z_2 = -1 + \sqrt{3}i + 1 + \sqrt{3}i = 2\sqrt{3}i$

ដោយ $P = z_1 \times z_2 = (-1 + \sqrt{3}i) \times (1 + \sqrt{3}i) = -1 - \sqrt{3}i + \sqrt{3}i - 3 = -4$

ដូចនេះ សមីការដឺក្រេទី២គឺ $Z^2 - 2i\sqrt{3}Z - 4 = 0$

គ. (**៥ពិន្ទុ**)កំណត់ចំនួនពិត $x$ និង $y$ ដើម្បីឲ្យ $z_1^3 + z_2^3 = 2(x+1) + i(y-3)$

ដោយ $\quad z_1 = 2(\cos\frac{2\pi}{3} + i\sin\frac{2\pi}{3})$

$$\Rightarrow z_1^3 = 2^3(\cos 2\pi + i\sin 2\pi) = 8(1 + 0i) = 8$$

ដោយ $\quad z_2 = 2(\cos\frac{\pi}{3} + i\sin\frac{\pi}{3})$

$$\Rightarrow z_2^3 = 2^3(\cos\pi + i\sin\pi) = 8(-1 + 0i) = -8$$

គេបាន $z_1^3 + z_2^3 = 2(x+1) + i(y-3)$

$$8 - 8 = 2(x+1) + i(y-3)$$

$$0 + 0i = 2(x+1) + i(y-3)$$

$$\Longleftrightarrow \begin{cases} 2(x+1) & = 0 \\ y - 3 & = 0 \end{cases} \Longleftrightarrow \begin{cases} x & = -1 \\ y & = 3 \end{cases}$$

ដូចនេះ: $x = -1$ និង $y = 3$

**II** (**១៥ពិន្ទុ**) គណនាលីមីតខាងក្រោមៈ

ក. $\lim\limits_{x\to -1} \frac{1+x}{\sqrt{x^2+3}-2}$ រាង $\frac{0}{0}$

គេបាន $\lim\limits_{x\to -1} \frac{1+x}{\sqrt{x^2+3}-2} = \lim\limits_{x\to -1} \frac{(1+x)(\sqrt{x^2+3}+2)}{(\sqrt{x^2+3}-2)(\sqrt{x^2+3}+2)} = \lim\limits_{x\to -1} \frac{(1+x)(\sqrt{x^2+3}+2)}{x^2+3-4}$

$$= \lim_{x\to -1} \frac{(1+x)(\sqrt{x^2+3}+2)}{x^2-1} = \lim_{x\to -1} \frac{(1+x)(\sqrt{x^2+3}+2)}{(x+1)(x-1)}$$

$$= \frac{2+2}{-1-1} = \frac{4}{-2} = -2$$

ដូចនេះ: $\lim\limits_{x\to -1} \frac{1+x}{\sqrt{x^2+3}-2} = -2$

ខ. $\lim\limits_{x\to 0^+} (\frac{1}{x} + \ln x)$ រាង $\infty - \infty$

ដោយ $\lim\limits_{x\to 0^+} (\frac{1}{x} + \ln x) = \lim\limits_{x\to 0^+} (\frac{1 + x\ln x}{x}) = \frac{1+0}{0^+} = \frac{1}{0^+} = +\infty$

ដូចនេះ: $\lim\limits_{x\to 0^+} (\frac{1}{x} + \ln x) = +\infty$

គ. $\lim\limits_{x\to +\infty} (x - e^x + \ln x)$ រាង $\infty - \infty$

ដោយ $\lim\limits_{x\to +\infty} (x - e^x + \ln x) = \lim\limits_{x\to +\infty} e^x(\frac{x}{e^x} - 1 + \frac{\ln x}{e^x}) = +\infty(0 - 1 - 0) = -\infty$

ដូចនេះ $\lim\limits_{x\to+\infty}(x-e^x+\ln x)=-\infty$

**III** ១. (**៥ពិន្ទុ**) ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $E:\ g''(x)-7g'(x)+10g(x)=0$

មានសមីការសម្គាល់ $r^2-7r+10=0$

$\Delta=49-4.1.10=49-40=9=3^2$

$r=\dfrac{7\pm\sqrt{3^2}}{2}=\begin{cases}r_1=5\\ r_2=2\end{cases}$

$\Longrightarrow g(x)=Ae^{5x}+Be^{2x}\ ,\ A,B\in\Re$

២. (**៥ពិន្ទុ**)កំណត់ចម្លើយ $g(x)$ មួយនៃ $E$ ដែល $g(0)=5\ ;\ g'(0)=16$

$g(x)=Ae^{5x}+Be^{2x}$

$g'(x)=5Ae^{5x}+2Be^{2x}$

$\begin{cases}g(0)=5\\ g'(0)=16\end{cases}\Longleftrightarrow\begin{cases}A+B=5\\ 5A+2B=16\end{cases}\Longleftrightarrow\begin{cases}A+B=5\times(-5)\\ 5A+2B=16\end{cases}\Longleftrightarrow-\begin{cases}5A+5B=25\\ 5A+2B=16\end{cases}$

$\Rightarrow 3B=9\Rightarrow B=3\qquad\Rightarrow A=2$

ដូចនេះ $g(x)=2e^{5x}+3e^{2x}$

**IV** (**១៥ពិន្ទុ**) គណនាប្រូបាបនៃព្រឹត្តិការណ៍

រូបមន្ត ប្រូបាបនៃព្រឹត្តិការណ៍មួយ$P(A)=\dfrac{n(A)}{n(S)}$

ចំនួនករណីអាច

$n(S)=C(13,3)=\dfrac{13!}{10!3!}=\dfrac{13\cdot12\cdot11\cdot10!}{10!\cdot3\cdot2\cdot1}=286$ ករណី

ក. $A:$ បាល់ទាំង 3 ពណ៌ស

ចំនួនករណីស្រប

$n(A)=C(5,3)=\dfrac{5!}{2!\cdot3!}=\dfrac{5\cdot4\cdot3!}{3!\cdot2\cot1}=10$ ករណី

$\Longrightarrow P(A)=\dfrac{n(A)}{n(S)}=\dfrac{10}{286}=\dfrac{5}{143}$

ខ. $B:$ បាល់ទាំង3ពណ៌ក្រហម

ចំនួនករណីស្រប

$n(B)=C(8,3)=\dfrac{8!}{5!\cdot3!}=\dfrac{8\cdot7\cdot6\cdot5!}{5!\cdot3\cdot2\cdot1}=56$ ករណី

$\Longrightarrow P(B)=\dfrac{n(B)}{n(S)}=\dfrac{56}{286}=\dfrac{28}{143}$

គ. $C:$ បាល់ស2និងបាល់ក្រហម1

$n(C)=C(5,2)\times C(8,1)=\dfrac{5!}{2!\cdot3!}\times\dfrac{8!}{7!\cdot1!}=\dfrac{5\cdot4\cdot3!}{3!\cdot2\cdot1}\times\dfrac{8\cdot7!}{7!\cdot1}=10\times8=80$ ករណី

$\Longrightarrow P(C)=\dfrac{n(C)}{n(S)}=\dfrac{80}{286}=\dfrac{40}{143}$

**V** $f(x)=\dfrac{x+1}{x^2-3x+2}\quad;\quad x\neq1\ ,\ x\neq2$

១. (**៥ពិន្ទុ**)សរសេរ $f$ ជារៀង $f(x)=\dfrac{a}{x-1}+\dfrac{b}{x-2}$ ដែល $a\,,b$ ជាចំនួនពិតត្រូវកំណត់

ដោយ $f(x)=\dfrac{x+1}{x^2-3x+2}=\dfrac{a}{x-1}+\dfrac{b}{x-2}$

$$\frac{x+1}{x^2-3x+2}=\frac{a(x-2)+b(x-1)}{(x-1)(x-2)}$$

$$x+1=a(x-2)+b(x-1)$$

បើ $x=1 \Longrightarrow 2=-a \Longrightarrow a=-2$

បើ $x=2 \Longrightarrow 3=b \Longrightarrow b=3$

ដូចនេះ $f(x)=-\dfrac{2}{x-1}+\dfrac{3}{x-2}$

២. (**៥ពិន្ទុ**) គណនា $\displaystyle\int_0^3 f(x)dx$

$$\int_0^3 f(x)dx=\int_0^3 \left(-\frac{2}{x-1}+\frac{3}{x-2}\right)dx=-2\int_0^3 \frac{(x-1)'}{x-1}dx+3\int_0^3 \frac{(x-2)'}{x-2}dx$$

$$=-2\ln|x-1|+3\ln|x-2|\big|_0^3=-2\ln 2+3\ln 1-(-2\ln 1+3\ln 2)$$

$$=-2\ln 2-3\ln 2=-5\ln 2$$

**VI** (**៣៥ពិន្ទុ**) $f(x)=x+2+(x+1)e^{-x}$

១. (**៤ពិន្ទុ**)គណនាលីមីតនៃ $f$ ខាង $+\infty$ និង $-\infty$

ដោយ $\displaystyle\lim_{x\to+\infty} f(x)=\lim_{x\to+\infty}[x+2+(x+1)e^{-x}]=+\infty+2+0=+\infty$

ដោយ $\displaystyle\lim_{x\to-\infty} f(x)=\lim_{x\to-\infty}[x+2+(x+1)e^{-x}]=-\infty+2+(-\infty)(+\infty)=-\infty+2-\infty=-\infty$

២. (**៥ពិន្ទុ**) គណនា $f'(x)$

$f(x)=x+2+(x+1)e^{-x}$

$\Longrightarrow f'(x)=1+0+(x+1)'e^{-x}+[e^{-x}]'(x+1)=1+e^{-x}-e^{-x}(x+1)=1+e^{-x}(1-x-1)=$
$1-xe^{-x}$

៣. (**៥ពិន្ទុ**) សិក្សាសញ្ញានៃ $f'(x)$

ដោយ $1-xe^{-x}>0 \Longrightarrow f'(x)>0$

| $x$ | $-\infty$ | $+\infty$ |
|---|---|---|
| $f'(x)$ | + | |

$\Longrightarrow f(x)$ ជាអនុគមន៍កើន

(**៥ពិន្ទុ**) គូសតារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $+\infty$ |
|---|---|---|---|
| $f'(x)$ | | + | |
| $f(x)$ | $-\infty$ | ↗ | $+\infty$ |

៤. (**៣ពិន្ទុ**) បង្ហាញថាបន្ទាត់ $\Delta : y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$

ដោយ $\lim\limits_{x\to+\infty}[f(x)-(x+2)] = \lim\limits_{x\to+\infty}(x+1)e^{-x}=0$

$\Longrightarrow \Delta: y=x+2$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$

(**៥ពិន្ទុ**)សិក្សាទីតាំងនៃក្រាប $C$ ធៀបនឹងអាស៊ីមតូតទ្រេត

តាង $h(x)=f(x)-\Delta=(x+1)e^{-x}$

បើ $h(x)=0 \Longleftrightarrow x+1=0 \quad ; \quad e^{-x}>0$

$\Longleftrightarrow x=-1$

| $x$ | $-\infty$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|
| $h(x)$ | | $-$ | $0$ | $+$ | |

$x\in(-\infty,-1) \Longrightarrow$ ក្រាប $C$ នៅក្រោម $\Delta$

$x\in(-1,+\infty) \Longrightarrow$ ក្រាប $C$ នៅលើ $\Delta$

$x=-1 \qquad \Longrightarrow$ ក្រាប $C$ កាត់ $\Delta$ ត្រង់ $(-1,1)$

៥. (**៨ពិន្ទុ**) សង់បន្ទាត់ $\Delta$ និង ក្រាប $C$ ក្នុងតម្រុយតែមួយ




**VII** (**២៥ពិន្ទុ**) គេមានចំណុច $A(2,1,4)$ ; $B(2,-2,7)$ និង ប្លង់ $P: 2x+2y-x=2$

១. (**១០ពិន្ទុ**) កំណត់សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $L$ ដែលកាត់តាម $B$ ហើយកែងនឹងប្លង់ $P$

សមីការមានរាង $\quad L: x=x_o+at \; ; \; y=y_o+bt \; ; \; z=z_o+ct \; ; \; t\in\Re$

ដោយ $\begin{cases} L\perp P \\ \vec{n}_p\perp P \end{cases} \Rightarrow L \parallel \vec{n}_p$

ដោយ $L$ កាត់តាម $B(2,-2,7)$ ហើយមានវ៉ិចទ័រប្រាប់ទិស $\vec{n}_p=(2,-2,-1)$

ដូចនេះ៖ $\quad L: x=2+2t \; ; \; y=-2++2t \; ; \; z=7-t \; ; \; t\in\Re$

២. (**៥ពិន្ទុ**) ចូរកំណត់កូអរដោនេចំណុចប្រសព្វ $M$ រវាង $D$ និង $P$

យក $D$ ជួសក្នុង $P$ គេបាន : $2(1+2t)+2(-2t)-(1-t)=2$

$$2+4t-4t-1+t=2$$

$$t=1$$

យក $t=1$ ជួសក្នុង $D$ គេបាន $x=3\ ;\ y=-2\ ;\ z=0$

ដូចនេះ កូអរដោនេនៃ $M$ គឺ $M(3\,,-2\,,0)$

៣. (**១០ពិន្ទុ**) ចូរគណនាផ្ទៃក្រឡានៃត្រីកោណ $MAB$

តាមរូបមន្ត $S_{\triangle MAB}=\dfrac{1}{2}|\overrightarrow{AB}\times\overrightarrow{AM}\,|$

ដោយ $\overrightarrow{AB}=(x_B-x_A\ ;\ y_B-y_A\ ;\ z_B-z_A)=(0\ ,\ -3\ ,\ 3)$

$\Longrightarrow\overrightarrow{AM}=(x_M-x_A\ ;\ y_M-y_A\ ;\ z_M-z_A)=(1\ ,\ -3\ ,\ -4)$

$$\overrightarrow{AB}\times\overrightarrow{AM}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 0 & -3 & 3\\ 1 & -3 & -4\end{vmatrix}=(12+9)\vec{i}-(0-3)\vec{j}+(0+3)\vec{k}=21\vec{i}+3\vec{j}+3\vec{k}$$

$S_{\triangle MAB}=\dfrac{1}{2}\sqrt{12^2+3^2+3^2}=\dfrac{1}{2}\sqrt{459}=\dfrac{3}{2}\sqrt{51}$ឯកតាផ្ទៃ

**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖________________ មណ្ឌលប្រឡង៖________________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________________

ថ្ងៃខែឆ្នាំកំណើត៖________________ | អក្សរសម្ងាត់ |

ហត្ថលេខា៖________________

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។

• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

✂ - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

____ / 125

# ១០

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី

រៀបរៀងដោយ៖ **សុខលាភ**

| អក្សរសម្ងាត់ |

**I** គេឲ្យចំនួនកុំផ្លិចពីរកំណត់ដោយ $x=\dfrac{1+2i}{3-4i}$ និង $y=\dfrac{2-i}{5i}$ ។

ក. ចូរសរសេរ $x$ និង $y$ ជាទម្រង់ពិជគណិត។ ខ. បង្ហាញថា $x+y$ ជាចំនួនពិត។

**II** ១. អ្នកគ្រូម្នាក់បានលើកទឹកចិត្តសិស្សពូកែក្នុងថ្នាក់ម្នាក់ដោយការផ្តល់ជូននូវសៀវភៅ 2 ក្បាលពីក្នុងចំណោមសៀវភៅគណិតវិទ្យា 6 ក្បាល វិទ្យាសាស្ត្រ 7 ក្បាល និងសេដ្ឋកិច្ច 4 ក្បាល។ ចូរគណនាចំនួនរបៀបនៃការជ្រើសរើសសៀវភៅ 2 ក្បាលនេះ បើសិស្សនោះ៖

ក. រើសយកសៀវភៅ 2 ក្បាលដែលជាមុខវិជ្ជាដូចគ្នា? ខ. រើសយកសៀវភៅ 2 ក្បាលដែលជាមុខវិជ្ជាខុសគ្នា?

២. អំណោយចំនួន 7 នឹងត្រូវបានចែកជូនសិស្សក្រីក្រចំនួន 10 នាក់។ តើមានប៉ុន្មានរបៀបក្នុងការចែកនេះ បើគ្មាននរណាម្នាក់បានលើសពី 1 ឡើយ?

**III** ចូរគណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 0}\dfrac{1-\cos x\cos 4x\cos 7x}{x^2}$ ខ. $\lim\limits_{x\to 1}\dfrac{\sqrt[2021]{x}-1}{x-1}$ គ. $\lim\limits_{x\to 0}(1+4\tan^2 x)^{\cot^2 x}$

**IV** គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{(2x-1)^2}{x}$ ចំពោះគ្រប់តម្លៃ $x\neq 0$ ។

ក. ចូរកំណត់តម្លៃ $A,B$ និង $C$ ដើម្បីអោយ $f(x)=Ax+B+\dfrac{C}{x}$ ។

ខ. គណនាអាំងតេក្រាលកំណត់នៃ $\displaystyle\int_1^2 f(x)dx$ ។

**V** គេមានម៉ាទ្រីសចំនួនបីគឺ $A=\begin{pmatrix}3&4\\-1&3\end{pmatrix}$ ; $B=\begin{pmatrix}0&-1\\3&1\end{pmatrix}$ និង $C=\begin{pmatrix}a&b\\c&d\end{pmatrix}$ ។

ក. ចូរគណនា $A+B$ និង $A-B$ ។

ខ. ចូរគណនាតម្លៃនៃម៉ាទ្រីស $C$ បើ $C=A\times B$

**VI** គេមានសមីការប៉ារ៉ាបូលទូទៅមួយកំណត់ដោយ $P: y^2-6y-12x-27=0$ ។

ក. ចូរសរសេរសមីការប៉ារ៉ាបូល $P$ ជាសមីការស្តង់ដារ។

ខ. ចូរកំណត់ កំពូល កំណុំ និង សមីការបន្ទាត់ប្រាប់ទិសនៃសមីការ $P$ នេះ។

គ. ចូរសង់ប៉ារ៉ាបូលនេះ ។

**VII** គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\dfrac{x^2+4x+3}{x^2-4x+3}$ ។

ក. រកដែនកំណត់ និង ដេរីវេទី១ នៃអនុគមន៍ $f$ ។

ខ. គណនាលីមីត $\lim\limits_{x\to\pm\infty} f(x)$ , $\lim\limits_{x\to 1} f(x)$ និង $\lim\limits_{x\to 3} f(x)$ ។ រួចទាញរកអាស៊ីមតូតដេក និងអាស៊ីមតូតឈរនៃអនុគមន៍នេះ។

គ. សង់តារាងអថេរភាពនៃអនុគមន៍នេះ។

ឃ. គូសក្រាបតាងអនុគមន៍នេះ ។ ( យក $\sqrt{3}=1.73$ )

# ដំណោះស្រាយ

**I**

ក. សរសេរ $x$ និង $y$ ជាទម្រង់ពិជគណិត

គេមាន $x=\dfrac{1+2i}{3-4i}$

$=\dfrac{(1+2i)(3+4i)}{3^2-(4i)^2}$

$=\dfrac{3-8+10i}{9+16}$

$=-\dfrac{1}{5}+\dfrac{2}{5}i$

និង $y=\dfrac{2-i}{5i}$

$=\dfrac{(2-i)(5i)}{(5i)^2}$

$=\dfrac{5+10i}{-25}$

$=-\dfrac{1}{5}-\dfrac{2}{5}i$

$(a-b)(a+b)=a^2-b^2$

$i^2=-1$

ដូចនេះៈ ទម្រង់ពិជគណិតនៃ $x$ និង $y$ គឺ $x=-\dfrac{1}{5}+\dfrac{2}{5}i$, $y=-\dfrac{1}{5}-\dfrac{2}{5}i$

ខ. បង្ហាញថា $x+y$ ជាចំនួនពិត

តាមសំណួរ (ក) ខាងលើ

គេបាន $x+y=(-\dfrac{1}{5}+\dfrac{2}{5}i)+(-\dfrac{1}{5}-\dfrac{2}{5}i)$

$=(-\dfrac{1}{5}-\dfrac{1}{5})+(\dfrac{2}{5}-\dfrac{2}{5})i$

$=-\dfrac{2}{5}$

ដូចនេះៈ $x+y$ ជាចំនួនពិត ។

**II**

១. គណនាចំនួនរបៀបនៃការជ្រើសរើសសៀវភៅ 2 ក្បាលនេះ បើសិស្សនោះៈ

ក. រើសយកសៀវភៅ 2 ក្បាលជាមុខវិជ្ជាដូចគ្នា

- ករណីសៀវភៅគណិតវិទ្យាដូចគ្នាៈ វាជាបន្សំនៃការរើស 2 ធាតុ ចេញពីធាតុសរុប 6

  $C_6^2=\dfrac{6!}{2!\times 4!}=\dfrac{6\times 5}{2\times 1}=15$ ករណី
- ករណីសៀវភៅវិទ្យាសាស្ត្រដូចគ្នាៈ វាជាបន្សំនៃការរើសធាតុ 2 ចេញពីធាតុសរុប 7

  $C_7^2=\dfrac{7!}{2!\times 5!}=\dfrac{7\times 6}{2\times 1}=21$ ករណី
- ករណីសៀវភៅសេដ្ឋកិច្ចដូចគ្នាៈ ដូចគ្នាដែរ វាជាបន្សំ នៃការរើសធាតុ 2 ចេញពីធាតុសរុប 4

  $C_4^2=\dfrac{4!}{2!\times 2!}=\dfrac{4\times 3}{2\times 1}=6$ ករណី

  គេបាន ចំនួនរបៀបនៃការរើសបានសៀវភៅជាមុខវិជ្ជាដូចគ្នា គឺ

  $15+21+6=42$ របៀប

  ដូចនេះៈ ចំនួនរបៀបនៃការរើសយកសៀវភៅដែលជាមុខវិជ្ជាដូចគ្នាសរុបគឺ 42 ករណី ។

ខ. រើសយកសៀវភៅ 2 ក្បាលជាមុខវិជ្ជាខុសគ្នា

$$\frac{z_1}{z_2} = \frac{2}{\sqrt{2}}\left[\cos\left(\frac{2\pi}{3} - \frac{\pi}{4}\right) + i\sin\left(\frac{2\pi}{3} - \frac{\pi}{4}\right)\right]$$
$$\frac{-1 + i\sqrt{3}}{1 + i} = \frac{2}{\sqrt{2}}\left(\cos\frac{5\pi}{12} + i\sin\frac{5\pi}{12}\right)$$
$$\cos\frac{5\pi}{12} + i\sin\frac{5\pi}{12} = \frac{\sqrt{2}(-1 + i\sqrt{3})(1 - i)}{2(1 + i)(1 - i)}$$
$$= \frac{\sqrt{2}(-1 + i + i\sqrt{3} - i^2\sqrt{3})}{2(1 - i^2)}, i^2 = -1$$
$$\cos\frac{5\pi}{12} + i\sin\frac{5\pi}{12} = \frac{-\sqrt{2} + \sqrt{6}}{4} + i\frac{\sqrt{2} + \sqrt{6}}{4}$$

ដូច្នេះ នាំឱ្យ $\boxed{\cos\frac{5\pi}{12} = \frac{\sqrt{6} - \sqrt{2}}{4} \text{ និង } \sin\frac{5\pi}{12} = \frac{\sqrt{2} + \sqrt{6}}{4}}$

**II** គណនាលីមីត

១. $\lim\limits_{x\to 2} \frac{x^3 + 4x - 16}{x^2 + 3x - 10} = \frac{2^3 + 4(2) - 16}{2^2 + 3(2) - 10} = \frac{8 + 8 - 16}{4 + 6 - 10} = \frac{0}{0}$ រាងមិនកំណត់

គេបាន
$$\lim_{x\to 2} \frac{x^3 + 4x - 16}{x^2 + 3x - 10} = \lim_{x\to 2} \frac{x^3 - 2x^2 + 2x^2 - 4x + 8x - 16}{x^2 - 2x + 5x - 10}$$
$$= \lim_{x\to 2} \frac{x^2(x - 2) + 2x(x - 2) + 8(x - 2)}{x(x - 2) + 5(x - 2)}$$
$$= \lim_{x\to 2} \frac{(x - 2)(x^2 + 2x + 8)}{(x - 2)(x + 5)}$$
$$= \frac{2^2 + 2(2) + 8}{2 + 5} = \frac{16}{7}$$

ដូច្នេះ $\boxed{\lim\limits_{x\to 2} \frac{x^3 + 4x - 16}{x^2 + 3x - 10} = \frac{16}{7}}$

២. $\lim\limits_{x\to\frac{\pi}{6}} \frac{2\sin^2 x - 3\sin x + 1}{4\sin^2 x - 1} = \frac{2\sin^2\frac{\pi}{6} - 3\sin\frac{\pi}{6} + 1}{4\sin^2\frac{\pi}{6} - 1} = \frac{2(\frac{1}{2})^2 - 3(\frac{1}{2}) + 1}{4(\frac{1}{2})^2 - 1} = \frac{0}{0}$ រាងមិនកំណត់

គេបាន
$$\lim_{x\to\frac{\pi}{6}} \frac{2\sin^2 x - 3\sin x + 1}{4\sin^2 x - 1} = \lim_{x\to\frac{\pi}{6}} \frac{2\sin^2 x - \sin x - 2\sin x + 1}{(2\sin x)^2 - 1}$$
$$= \lim_{x\to\frac{\pi}{6}} \frac{\sin x(2\sin x - 1) - (2\sin x - 1)}{(2\sin x - 1)(2\sin x + 1)}$$
$$= \lim_{x\to\frac{\pi}{6}} \frac{(2\sin x - 1)(\sin x - 1)}{(2\sin x + 1)(2\sin x - 1)}$$
$$= \frac{\frac{1}{2} - 1}{2(\frac{1}{2}) + 1} = -\frac{1}{4}$$

ដូច្នេះ $\boxed{\lim\limits_{x\to\frac{\pi}{6}} \frac{2\sin^2 x - 3\sin x + 1}{4\sin^2 x - 1} = -\frac{1}{4}}$

៣. $\lim\limits_{x\to 0} \frac{1 - \cos x.\cos 2x.\cos 3x}{x^2} = \frac{1 - 1}{0} = \frac{0}{0}$ រាងមិនកំណត់

ដោយប្រើរូបមន្ត $\cos a\cos b=\frac{1}{2}[\cos(a+b)+\cos(a-b)]$

គេបាន $\lim_{x\to0}\frac{1-\cos x.\cos 2x.\cos 3x}{x^2}=\lim_{x\to0}\frac{1-\frac{1}{2}[\cos 3x+\cos(-x)]\cos 3x}{x^2}$ , $\cos(-x)=\cos x$

$$=\lim_{x\to0}\frac{1-\frac{1}{2}(\cos 3x.\cos 3x+\cos x.\cos 3x)}{x^2}$$

$$=\lim_{x\to0}\frac{1-\frac{1}{2}[\frac{1}{2}(\cos 6x+\cos 0)+\frac{1}{2}(\cos 4x+\cos 2x)]}{x^2}$$

$$=\lim_{x\to0}\frac{\frac{4-\cos 6x-1-\cos 4x-\cos 2x}{4}}{x^2}$$

$$=\lim_{x\to0}\frac{1-\cos 6x+1-\cos 4x+1-\cos 2x}{4x^2}, 1-\cos ax=2\sin^2\frac{ax}{2}$$

$$=\frac{1}{4}\lim_{x\to0}\frac{2\sin^2 3x+2\sin^2 2x+2\sin^2 x}{x^2}$$

$$=\frac{1}{2}\lim_{x\to0}\left[\frac{\sin^2 3x}{(3x)^2}\times 9+\frac{\sin^2 2x}{(2x)^2}\times 4+\frac{\sin^2 x}{x^2}\right]$$

$$=\frac{1}{2}(9+4+1)=\frac{14}{2}$$

ដូច្នេះ $\boxed{\lim_{x\to0}\frac{1-\cos x.\cos 2x.\cos 3x}{x^2}=7}$

## III គណនាអាំងតេក្រាល

១. $I=\int\frac{3x^2+5x-4}{(x-1)(x+1)^2}dx$

គេអាចសរសេរជារាងកាណូនិច

$$\frac{3x^2+5x-4}{(x-1)(x+1)^2}=\frac{A}{x-1}+\frac{B}{(x+1)^2}+\frac{C}{x+1}$$

$$3x^2+5x-4=A(x^2+2x+1)+B(x-1)+C(x^2-1)$$

$$3x^2+5x-4=Ax^2+2Ax+A+Bx-B+Cx^2-C$$

$$3x^2+5x-4=(A+C)x^2+(2A+B)x+(A-B-C)$$

ផ្ទឹមមេគុណនៃអង្គទាំងពីរ គេបាន $\begin{cases}A+C=3\\2A+B=5\\A-B-C=-4\end{cases}$ នាំឱ្យ $\begin{cases}A=1\\B=3\\C=2\end{cases}$

នោះគេបាន $I=\int\frac{3x^2+5x-4}{(x-1)(x+1)^2}dx=\int\left[\frac{1}{x-1}+\frac{3}{(x+1)^2}+\frac{2}{x+1}\right]dx$

$$=\int\frac{dx}{x-1}+3\int\frac{dx}{(x+1)^2}+2\int\frac{dx}{x+1}$$

$$=\ln|x-1|-\frac{3}{x+1}+2\ln|x+1|+C$$

ដូច្នេះ $\boxed{I=\int\frac{3x^2+5x-4}{(x-1)(x+1)^2}dx=\ln|x-1|-\frac{3}{x+1}+2\ln|x+1|+C}$

២. $J=\int\frac{3(x^2-2x+3)}{(x-1)(x+2)^2}dx$

គេអាចសរសេរជារាងកាណូនិច

$$\frac{3(x^2-2x+3)}{(x-1)(x+2)^2}=\frac{A}{x-1}+\frac{B}{(x+2)^2}+\frac{C}{x+2}$$

$$3(x^2-2x+3)=A(x^2+4x+4)+B(x-1)+C(x-1)(x+2)$$

$$3x^2-6x+9=Ax^2+4Ax+4A+Bx-B+Cx^2+Cx-2C$$

$$3x^2-6x+9=(A+C)x^2+(4A+B+C)x+(4A-B-2C)$$

ផ្ទឹមមេគុណនៃអង្គទាំងពីរ គេបាន $\begin{cases}A+C=3\\4A+B+C=-6\\4A-B-2C=9\end{cases}$ នាំឱ្យ $\begin{cases}A=\frac{2}{3}\\B=-11\\C=\frac{7}{2}\end{cases}$

នោះគេបាន $J=\int\frac{3(x^2-2x+3)}{(x-1)(x+2)^2}dx=\int\left[\frac{2}{3(x-1)}-\frac{11}{(x+2)^2}+\frac{7}{3(x+2)}\right]dx$

$$=\frac{2}{3}\int\frac{dx}{x-1}-11\int\frac{dx}{(x+2)^2}+\frac{7}{3}\int\frac{dx}{x+2}$$

$$=\frac{2}{3}\ln|x-1|+\frac{11}{x+2}+\frac{7}{3}\ln|x+2|+C$$

ដូច្នេះ $\boxed{J=\int\frac{3(x^2-2x+3)}{(x-1)(x+2)^2}dx=\frac{2}{3}\ln|x-1|+\frac{11}{x+2}+\frac{7}{3}\ln|x+2|+C}$

៣. $K=\int\cos^3xdx=\int\cos x(\cos^2x)$ ដោយ $\sin^2x+\cos^2x=1$ នោះ $\cos^2x=1-\sin^2x$

គេបាន $K=\int\cos x(1-\sin^2x)dx=\int\cos xdx-\int\sin^2x\cos xdx$

តាង $t=\sin x\Rightarrow dt=\cos xdx$

គេបាន $K=\int\cos xdx-\int t^2dt=\sin x-\frac{t^3}{3}+C=\sin x+\frac{\sin^3x}{3}+C$

ដូច្នេះ $\boxed{K=\sin x+\frac{\sin^3x}{3}+C}$

**IV** គេឱ្យសមីការឌីផេរ៉ង់ស្យែល $(E):\quad y''-3y'+2y=4x^3-2x$

១. ដោះស្រាយសមីការឌីផេរ៉ង់ស្យែលអូម៉ូស្សែន $y''-3y'+2y=0$

សមីការសំគាល់ $\lambda^2-3\lambda+5=0\Leftrightarrow(\lambda-1)(\lambda-2)=0\Rightarrow\lambda_1=1,\lambda_2=2$

ដូនេះ ចម្លើយទូទៅនៃសមីការគឺ $\boxed{y_c=Ae^x+Be^{2x}}$

២. កំណត់ចំនួនពិត $a,b,c$ និង $d$

បើ $g(x)=ax^3+bx^2+cx+d$ ជាចម្លើយពិសេសនៃសមីការ $(E)$

នោះ $g'(x)=3ax^2+2bx+c\Rightarrow g''(x)=6ax+2b$ ជំនួសចូលសមីការ $(E)$

គេបាន
$$g''(x)-3g'(x)+2g(x)=4x^3-2x$$

$$6ax+2b-3(3ax^2+2bx+c)+2(ax^3+bx^2+cx+d)=4x^3-2x$$

$$2ax^3+(-9a+2b)x^2+(6a-6b+2c)x+(2b-3c+2d)=4x^3-2x$$

$$\Leftrightarrow\begin{cases}2a&=4\\-9a+2b&=0\\6a-6b+2c&=2\\2b-3c+2d&=0\end{cases}\Leftrightarrow\begin{cases}a&=2\\b&=9\\c&=22\\d&=24\end{cases}$$

ដូច្នេះ $\boxed{\text{ចម្លើយទូទៅនៃសមីការ } (E) \text{ គឺ } y=y_c+g(x)=Ae^x+Be^x+2x^3+9x^2+22x+24\ ,A,B\in\mathbb{R}}$

**V** គេឱ្យអនុគមន៍ $f(x)=\sqrt{3x+1}$ កំណត់លើ $\left[-\frac{1}{3},+\infty\right)$

១. កំណត់តម្លៃអមនៃ $f'(x)$ ចំពោះ $\forall x\in[1,5]$

ដោយ $f'(x)=\frac{(3x+1)'}{2\sqrt{3x+1}}=\frac{3}{2\sqrt{3x+1}}\Rightarrow f'(1)=\frac{3}{2\sqrt{4}}=\frac{3}{4}, f'(5)=\frac{3}{2\sqrt{16}}=\frac{3}{8}$

ចំពោះ $\forall x\in[1,5]$ និង $f'(1)>f'(5)$ នោះគេបាន $f'(5)\le f'(x)\le f'(1)$

ដូច្នេះ $\boxed{\text{តម្លៃអមនៃ } f'(x) \text{ គឺ } \frac{3}{8}\le f'(x)\le\frac{3}{4}}$

២. បង្ហាញថា $\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4}$ ចំពោះ $\forall x\in[1,5]$

ដោយ $\frac{3}{8}\le f'(x)\le\frac{3}{4}$ តាមវិសមភាពកំណើនមានកំណត់

គេបាន $\frac{3}{8}(x-1)\le f(x)-f(1)\le\frac{3}{4}(x-1)$

$$\frac{3}{8}x-\frac{3}{8}\le\sqrt{3x+1}-\sqrt{3(1)+1}\le\frac{3}{4}x-\frac{3}{4}$$

$$\frac{3}{8}x-\frac{3}{8}+2\le\sqrt{3x+1}\le\frac{3}{4}x-\frac{3}{4}+2$$

ដូច្នេះ $\boxed{\frac{3}{8}x+\frac{13}{8}\le\sqrt{3x+1}\le\frac{3}{4}x+\frac{5}{4},\forall x\in[1,5]}$

**VI** $f$ ជាអនុគមន៍កំណត់ដោយ $y=f(x)=x+e^{1-x}$ ហើយមានក្រាប $C$ ។

ក. គណនា $\lim\limits_{x\to+\infty}f(x)=\lim\limits_{x\to+\infty}(x+e^{1-x})=+\infty+e^{-\infty}=+\infty+0=+\infty$

$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}(x+e^{1-x})=-\infty+e^{+\infty}=+\infty-\infty$$

$$=\lim_{x\to-\infty}(x+\frac{e}{e^x})=\lim_{x\to-\infty}e^{-x}\left(\frac{x}{e^{-x}}+e\right)=+\infty(0+e)=+\infty$$

ដោយ $\lim\limits_{x\to+\infty}e^{1-x}=0$ នោះគេបាន $L:y=x$ ជាអាស៊ីមតូតទ្រេតនៃក្រាប $C$

ខ. បង្ហាញថា $f$ មានតម្លៃអប្បបរមាត្រង់ $x=1$

គេបាន $f'(x)=(x+e^{1-x})'=1+(1-x)'e^{1-x}=1-e^{1-x}$

បើ $f'(x)=0$ នោះ $1-e^{1-x}=0\Leftrightarrow e^{1-x}=e^0\Leftrightarrow 1-x=0\Rightarrow x=1$

បើ $f'(x)>0$ នោះ $1-e^{1-x}>0\Leftrightarrow e^{1-x}<e^0\Leftrightarrow 1-x<0\Rightarrow x>1$

បើ $f'(x)<0$ នោះ $1-e^{1-x}<0\Leftrightarrow e^{1-x}>e^0\Leftrightarrow 1-x>0\Rightarrow x<1$

តារាងសញ្ញានៃ $f'(x)$

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |

ដោយ $f'(x)$ ប្ដូរសញ្ញាពី $-$ ទៅ $+$ ត្រង់ $x=1$ នោះ $f$ មានអតិប្បបរមាត្រង់ $x=1$ គឺ $f(1)=1+e^0=2$

សង់តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $0$ | $+$ | |
| $f(x)$ | $+\infty$ | $\searrow$ | $2$ | $\nearrow$ | $-\infty$ |

គ. សង់ក្រាប $C$ នៅក្នុងតម្រុយកូអរដោនេមួយ គេយក $e=2.7$

បើ $x=0$ នោះ $y(0)=e$




ឃ. គណនាផ្ទៃក្រឡាផ្នែកប្លង់កំណត់ដោយក្រាប $C$ អាស៊ីមតូតទ្រេត $L$ បន្ទាត់ឈរ $x=1$ និង $x=2$

គេបាន $S=\int_1^2[f(x)-x]dx=\int_1^2(x+e^{1-x}-x)dx=\int_1^2 e^{1-x}dx=e\int_1^2 e^{-x}dx$

$$=-e\left[e^{-x}\right]_1^2=-e(e^{-2}-e^{-1})=-e^{-1}+e^0=1-\frac{1}{e}=\frac{e-1}{e}$$

ដូច្នេះ $\boxed{\text{ផ្ទៃក្រឡា } S=\frac{e-1}{e} \text{ ឯកត្តាផ្ទៃក្រឡា}}$

**VII** ក្នុងតម្រុយអរតូនរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេឱ្យបីចំណុច $A(-2,1,-3),B(1,2,3)$ និង $C(2,-2,1)$

១. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ ដែលកាត់តាម $A$ ហើយស្របនឹង $\overrightarrow{BC}$

នោះ $\overrightarrow{BC}=(2-1,-2-2,1-3)=(1,-4,-2)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $L$

គេបានសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L:\begin{cases}x=-2+t\\ y=1-4t\\ z=-3-2t\end{cases},t\in\mathbb{R}$

២. គណនា $\overrightarrow{AB}\times\overrightarrow{AC}$

ដោយ $\overrightarrow{AB}=(1+2,2-1,3+3)=(3,1,6)$

$\overrightarrow{AC}=(2+2,-2-1,1+3)=(4,-3,4)$

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\3&1&6\\4&-3&4\end{vmatrix}=(4+18)\vec{i}-(12-24)\vec{j}+(-9-4)\vec{k}=22\vec{i}+12\vec{j}-13\vec{k}$

រកសមីការប្លង់ $ABC$

គេបាន សមីការប្លង់ $ABC$ :
$$\begin{aligned}22(x+2)+12(y-1)-13(z+3)&=0\\22x+44+12y-12-13z-39&=0\\22x+12y-13z-7&=0\end{aligned}$$

គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$

គេបាន ក្រឡាផ្ទៃនៃត្រីកោណ $ABC$ គឺ $S=|\overrightarrow{AB}\times\overrightarrow{AC}|=\dfrac{1}{2}\sqrt{22^2+12^2+13^2}=\sqrt{797}$ ឯកត្តាផ្ទៃក្រឡា

៣. រកមាឌនៃតេត្រាអែត $OABC$

ដោយ $\overrightarrow{AO}=(0+2,0-1,0+3)=(2,-1,3)$ និង $\overrightarrow{AB}\times\overrightarrow{AC}=(22,12,-13)$

នាំឱ្យ $\overrightarrow{AO}.(\overrightarrow{AB}\times\overrightarrow{AC})=(2)(22)+(-1)(12)+(3)(-13)=-7$

គេបាន មាឌតេត្រាអ៊ែត $OABC$ គឺ $V=\dfrac{1}{6}\left|\overrightarrow{AO}.(\overrightarrow{AB}\times\overrightarrow{AC})\right|=\dfrac{|-7|}{6}=\dfrac{7}{6}$ ឯកត្តាមាឌ

ក្រសួងអប់រំ យុវជន និងកីឡា
ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**
សម័យប្រឡង៖______________________ មណ្ឌលប្រឡង៖______________________
**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖______________________
ថ្ងៃខែឆ្នាំកំណើត៖______________________
ហត្ថលេខា៖______________________

លេខបន្ទប់៖________
លេខតុ៖________

អក្សរសម្ងាត់

• បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
• បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

______ / 125

**១៤**

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី
រៀបរៀងដោយ៖ **ហ៊ីង វុទ្ធី**

អក្សរសម្ងាត់

**I**

១. ដោះស្រាយសមីការ $z^2-2\sqrt{2}z+4=0$ $(E)$ ក្នុងសំណុំចំនួនកុំផ្លិច ។
រកម៉ូឌុល និង អាគុយម៉ង់នៃឫសនីមួយៗរបស់សមីការ $(E)$ ។

២. សរសេរ $w=\left(\dfrac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}\right)^2$ ជាទម្រង់ត្រីកោណមាត្រ ។

**II** គណនាលីមីត៖

$$A=\lim_{x\to0}\frac{1-\cos4x}{1-\cos x}\qquad B=\lim_{x\to0}\frac{\sin x}{\sqrt{x+1}-\sqrt{1-x}}\qquad C=\lim_{x\to1}\frac{x^2+x-2}{x^2-1}$$

**III** ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $2y''+3y'+y=0$ តាមលក្ខខណ្ឌដើម $y(0)=1, y'(0)=2$ ។

**IV** គណនាអាំងតេក្រាល

$$A=\int\frac{2x+7}{x^2-1}dx\qquad B=\int_e^{e^2}\frac{dx}{x\ln x}\qquad C=\int xe^x dx$$

**V** ក្នុងថង់មួយមានប៊ូល ១៥ ដែលចែកជា ប៊ូលពណ៌បៃតងចំនួន ៧ និងសរសេរលើប៊ូលទាំង ៧ ប៊ូលខៀវចំនួន ៥ និងប៊ូលពណ៌ក្រហម ចំនួន ៣ ។ គេចាប់ប៊ូលបីចេញពីក្នុងថង់ដោយចៃដន្យ ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

$A$: ប៊ូលដែលចាប់បានមានពណ៌បៃតង

$B$: ប៊ូលដែលចាប់បានមានពណ៌ក្រហមចំនួនពីរ និងបៃតងមួយ

$C$: ប៊ូលដែលចាប់បានមានពណ៌ខុសគ្នា ។

**VI** អនុគមន៍ $f$ កំណត់ដោយ $y=f(x)=\ln\left(\dfrac{x+1}{x-1}\right)$ ហើយមានក្រាប $C$ ។

១. រកដែនកំណត់នៃអនុគមន៍ $f$ រួចបង្ហាញថាជាអនុគមន៍សេស ។

២. គណនាលីមីតចុងដែនកំណត់ រួចទាញរកអាស៊ីមតូតនៃអនុគមន៍ ។

៣. គណនាដេរីវេនៃអនុគមន៍

៤. សង់តារាងអថេរភាពនៃ អនុគមន៍ $f$ និងសង់ខ្សែកោង $C$ ។ គេឱ្យ $(e=2.7)$

៥. ដោយប្រើក្រាប $(C)$ ចូរពិភាក្សាតាមតម្លៃប៉ារ៉ាម៉ែត្រ $m$ នូវចំនួននឹងសញ្ញានៃឫសសមីការ $\ln\left(\dfrac{x+1}{x-1}\right)=m$ ។

**VII** ក្នុងតម្រុយអរតូនរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមានមួយ គេឱ្យបីចំណុច $A(3,1,4), B(-1,2,5), C(5,-2,3)$

១. សរសេរសមីការប៉ារ៉ាម៉ែត និង សមីការឆ្លុះនៃបន្ទាត់ $(D)$ ដែលកាត់តាមចំណុច $C$ និងមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB}$ ។

២. រកសមីការប្លង់ $(P)$ ដែលមានវ៉ិចទ័រណរម៉ាល់ $\overrightarrow{AC}$ ហើយកាត់តាមចំណុច $B$ ។ រកសមីការស្វ៊ែ $(S)$ ដែលមានអង្កត់ផ្ចិត $[AB]$ ។

៣. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ រួចសរសេរសមីការប្លង់ $ABC$ ។ គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ ។
$M$ ជាចំណុចប្រសព្វរវាងបន្ទាត់ $(D)$ និងប្លង់ $(P)$ គណនាកូអរដោនេនៃចំណុច $M$ ។

# ដំណោះស្រាយ

**I**

១. ដោះស្រាយសមីការ $z^2-2\sqrt{2}z+4=0\quad(E)$ ក្នុងសំណុំចំនួនកុំផ្លិច ។

តាម $\Delta'=(b')^2-ac=(-\sqrt{2})^2-(1)(4)=2-4=-2<0$

គេបាន $z_1=\dfrac{-(-\sqrt{2})+\sqrt{2}i}{1}=\sqrt{2}+i\sqrt{2}$ នាំឱ្យ $z_2=\bar{z}_=\sqrt{2}-i\sqrt{2}$

ដូច្នេះ $\boxed{z_1=\sqrt{2}+i\sqrt{2},z_2=\sqrt{2}-i\sqrt{2}}$

រក $|z_1|,|z_2|$ និង $\arg(z_1),\arg(z_2)$

ដោយ $|z_1|=|z_2|=\sqrt{(\sqrt{2})^2+(\sqrt{2})^2}=\sqrt{2+2}=\sqrt{4}=2$

គេបាន $z_1=2\left(\dfrac{\sqrt{2}}{2}+i\dfrac{\sqrt{2}}{2}\right)=2\left(\cos\dfrac{\pi}{4}+i\sin\dfrac{\pi}{4}\right)$

$$z_2=2\left(\frac{\sqrt{2}}{2}-i\frac{\sqrt{2}}{2}\right)=2\left[\cos(-\frac{\pi}{4})+i\sin(-\frac{\pi}{4})\right]$$

ដូច្នេះ $\boxed{|z_1|=|z_2|=2,\arg(z_1)=\dfrac{\pi}{4}+2k\pi,\arg(z_2)=-\dfrac{\pi}{4}+2k\pi \text{ ដែល } k\in\mathbb{Z}}$

២. សរសេរ $w=\left(\dfrac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}\right)^2$ ជាទម្រង់ត្រីកោណមាត្រ

ដោយ $\dfrac{\sqrt{2}+i\sqrt{2}}{\sqrt{2}-i\sqrt{2}}=\cos\left(\dfrac{\pi}{4}+\dfrac{\pi}{4}\right)+i\sin\left(\dfrac{\pi}{4}+\dfrac{\pi}{4}\right)=\cos\left(\dfrac{2\pi}{4}\right)+i\sin\left(\dfrac{2\pi}{4}\right)$

នាំឱ្យ $w=\left[\cos\left(\dfrac{2\pi}{4}\right)+i\sin\left(\dfrac{2\pi}{4}\right)\right]^2=\cos\left(\dfrac{4\pi}{4}\right)+i\sin\left(\dfrac{4\pi}{4}\right)$

ដូច្នេះ $\boxed{w=\cos\pi+i\sin\pi}$

**II** គណនាលីមីត៖

$A=\lim\limits_{x\to0}\dfrac{1-\cos4x}{1-\cos x}$ រាងមិនកំណត់ $\dfrac{0}{0}$

គេបាន $A=\lim\limits_{x\to0}\dfrac{2\sin^2 2x}{2\sin^2\frac{x}{2}}=16\lim\limits_{x\to0}\left[\dfrac{\sin^2 2x}{(2x)^2}\times\dfrac{\frac{x^2}{2}}{\sin^2\frac{x}{2}}\right]=16$

ដូច្នេះ $\boxed{A=16}$

$B=\lim\limits_{x\to0}\dfrac{\sin x}{\sqrt{x+1}-\sqrt{1-x}}$ រាងមិនកំណត់ $\dfrac{0}{0}$

តាង $A(x)=\sqrt{x+1}+\sqrt{1-x}\Rightarrow A(0)=2$

គេបាន $B=\lim\limits_{x\to0}\dfrac{\sin x.A(x)}{(\sqrt{x+1}-\sqrt{1-x})(\sqrt{x+1}+\sqrt{1-x})}=\lim\limits_{x\to0}\dfrac{\sin x.A(x)}{(\sqrt{x+1})^2-(\sqrt{1-x})^2}$

$$=\lim_{x\to0}\frac{A(x)\sin x}{x+1-1+x}=\lim_{x\to0}\left[\frac{A(x)}{2}\times\frac{\sin x}{x}\right]=\frac{A(0)}{2}\times1=\frac{2}{2}=1$$

ដូច្នេះ $\boxed{B=1}$

$C=\lim\limits_{x\to1}\dfrac{x^2+x-2}{x^2-1}$ រាងមិនកំណត់ $\dfrac{0}{0}$

គេបាន $C=\lim\limits_{x\to1}\dfrac{x^2-x+2x-2}{x^2-x+x-1}=\lim\limits_{x\to1}\dfrac{x(x-1)+2(x-1)}{x(x-1)+(x-1)}$

$$=\lim_{x\to1}\frac{(x-1)(x+2)}{(x-1)(x+1)}=\lim_{x\to1}\frac{x+2}{x+1}=\frac{3}{2}$$

ដូច្នេះ $\boxed{C=\dfrac{3}{2}}$

**III** ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $2y''+3y'+y=0$ តាមលក្ខខណ្ឌដើម $y(0)=1,y'(0)=2$

មានសមីការសម្គាល់ $2\lambda^2+3\lambda+1=0 \Leftrightarrow (\lambda+1)(2\lambda+1)=0$

$$\Leftrightarrow x+1=0, 2x+1=0$$

$$\Rightarrow x=-1, x=-\frac{1}{2}$$

គេបាន ចម្លើយទូទៅនៃសមីការ $y=Ae^{-x}+Be^{-\frac{1}{2}x}, A,B\in\mathbb{R} \Rightarrow y(0)=A+B=1 \quad (1)$

$$y'=-Ae^{-x}+-\frac{1}{2}B^{-\frac{1}{2}x} \Rightarrow y'(0)=-A-\frac{1}{2}B=2 \quad (2)$$

យកសមីការ $(1)+(2)$ គេបាន $A-A+B-\frac{1}{2}B=1+2 \Leftrightarrow \frac{1}{2}B=3 \Rightarrow B=6$

ជំនួសចូលសមីការ $(1)$ នាំឱ្យ $A=1-B=1-6=-5$

ដូច្នេះ សមីការមានចម្លើយ $\boxed{y=-5e^{-x}+6e^{-\frac{1}{2}x}}$

**IV** គណនាអាំងតេក្រាល

$A=\int \frac{2x+7}{x^2-1}dx$

ដោយ $\frac{2x+7}{x^2-1}=\frac{2x+7}{(x-1)(x+1)}=\frac{A}{x-1}+\frac{B}{x+1}=\frac{A(x+1)+B(x-1)}{(x-1)(x+1)}$

សមូល $2x+7=Ax+A+Bx-B=(A+B)x+A-B$

$$\Leftrightarrow \begin{cases} A+B &=2 \quad (1) \\ A-B &=7 \quad (2) \end{cases}$$

យក $(1)+(2)$ គេបាន $2A=9 \Rightarrow A=\frac{9}{2}$ ជំនួសចូល $(1)$ នោះ $B=2-A=2-\frac{9}{2}=-\frac{5}{2}$

គេបាន $A=\int\left(\frac{9}{2(x-1)}-\frac{5}{2(x+1)}\right)dx=\frac{9}{2}\int\frac{dx}{x-1}-\frac{5}{2}\int\frac{dx}{x+1}=\frac{9}{2}\ln|x-1|-\frac{5}{2}\ln|x+1|+C$

ដូច្នេះ $\boxed{A=\frac{9}{2}\ln|x-1|-\frac{5}{2}\ln|x+1|+C, C\in\mathbb{R}}$

$B=\int_e^{e^2}\frac{dx}{x\ln x}$

តាង $t=\ln x \Rightarrow dt=\frac{dx}{x}$

គេបាន $B=\int_e^{e^2}\frac{dx}{x\ln x}=\int_e^{e^2}\frac{dt}{t}=[\ln|t|]_e^{e^2}=[\ln|\ln x|]_e^{e^2}=|\ln|\ln e^2||-|\ln|e||=\ln 2-1$

ដូច្នេះ $\boxed{B=\ln 2-1}$

$C=\int xe^x dx$

តាង $u=x \Rightarrow du=dx$ និង $dv=e^x dx \Rightarrow v=\int e^x dx=e^x$

គេបាន $C=uv-\int vdu=xe^x-\int e^x dx=xe^x-e^x+C$

ដូច្នេះ $\boxed{C=xe^x-e^x+c, c\in\mathbb{R}}$

**V** គេចាប់បូល 3 ចេញពីក្នុងថង់ដែលមានបូលសរុបចំនួន 15 ដោយចៃដន្យ

នោះករណីអាចគឺ $n(S)=C(15,3)=\frac{15!}{(15-3)!3!}=\frac{12!.13.14.15}{12!3!}=450$

រក $P(A)$

$A$: បូលដែលចាប់បានមានពណ៌បៃតង នាំឱ្យ $n(A)=C(7,3)=\frac{7!}{(7-3)3!}=\frac{4!.5.6.7}{4!3!}=5\times 7=35$

ដូច្នេះ $\boxed{P(A)=\frac{n(A)}{n(S)}=\frac{35}{450}=\frac{7}{90}}$

រក $P(B)$

$B$: ប៊ូលដែលចាប់បានពណ៌ក្រហមចំនួន 2 និង បៃតង 1 នំាឱ្យ $n(B) = C(3,2).C(7,1) = 3\times 7 = 21$

ដូច្នេះ $\boxed{P(B) = \dfrac{n(B)}{n(S)} = \dfrac{21}{450} = \dfrac{7}{150}}$

រក $P(C)$

$C$: ប៊ូលដែលចាប់បានមានពណ៌ខុសគ្នា នាំឱ្យ $n(C) = C(7,1).C(5,1).C(3,1) = 7\times 5\times 3 = 150$

ដូច្នេះ $\boxed{P(C) = \dfrac{n(C)}{n(S)} = \dfrac{150}{450} = \dfrac{1}{3}}$

**VI** អនុគមន៍ $f$ កំណត់ដោយ $y = f(x) = \ln\left(\dfrac{x+1}{x-1}\right)$ ហើយមានក្រាប $C$

១. រកដែនកំណត់នៃអនុគមន៍ $f$

អនុគមន៍ $f$ មានន័យកាលណា $\dfrac{x+1}{x-1} > 0$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $x+1$ | | $-$ | $0$ | $+$ | | $+$ | |
| $x-1$ | | $-$ | | $-$ | $0$ | $+$ | |
| $\dfrac{x+1}{x-1}$ | | $+$ | | $-$ | | $+$ | |

តាមតារាងសញ្ញា ដោយ $\dfrac{x+1}{x-1} > 0 \Rightarrow x\in(-\infty,-1)\cup(1,+\infty)$

ដូច្នេះ ដែនកំណត់ $\boxed{\mathscr{D} = (-\infty,-1)\cup(1,+\infty)}$

បង្ហាញថា $f$ ជាអនុគមន៍សេស

$\forall x\in\mathscr{D}, \exists -x\in\mathscr{D}$ គេបាន
$$\begin{aligned} f(-x) &= \ln\left(\frac{-x+1}{-x-1}\right) = \ln\left(\frac{x-1}{x+1}\right)\\ &= \ln(x-1) - \ln(x+1)\\ &= -[\ln(x+1) - \ln(x-1)]\\ &= -\ln\left(\frac{x+1}{x-1}\right)\\ &= -f(x)\end{aligned}$$

ដូច្នេះ $f$ ជាអនុគមន៍សេស

២. គណនាលីមីតចុងដែនកំណត់

គេបាន $\lim\limits_{x\to\pm\infty} f(x) = \lim\limits_{x\to\pm\infty}\ln\left(\dfrac{x+1}{x-1}\right) = \lim\limits_{x\to\pm\infty}\ln\left(\dfrac{1+\frac{1}{x}}{1-\frac{1}{x}}\right) = \ln 1 = 0$

$$\lim_{x\to -1} f(x) = \lim_{x\to -1}\ln\left(\frac{x+1}{x-1}\right) = \ln\left(\frac{-1+1}{-1-1}\right) = \ln 0^+ = -\infty$$

$$\lim_{x\to 1} f(x) = \lim_{x\to 1}\ln\left(\frac{x+1}{x-1}\right) = \ln\left(\frac{1+1}{1-1}\right) = \ln +\infty = +\infty$$

គេបាន $y = 0$ ជាអាស៊ីមតូតដេក និង $x = -1, x = 1$ ជាអាស៊ីមតូតឈរនៃអនុគមន៍ $f$

៣. គណនាដេរីវេនៃអនុគមន៍

គេបាន $f'(x) = \left[\ln\left(\dfrac{x+1}{x-1}\right)\right]' = [\ln(x+1)]' - [\ln(x-1)]' = \dfrac{(x+1)'}{x+1} - \dfrac{(x-1)'}{x-1}$

$$= \frac{1}{x+1} - \frac{1}{x-1} = \frac{x-1-x-1}{(x-1)(x+1)} = \frac{-2}{(x-1)(x+1)}$$

ដូច្នេះ $f'(x) = \dfrac{-2}{(x-1)(x+1)}$

ដោយ $(x-1)(x+1) > 0, \forall x\in\mathscr{D} \Rightarrow f'(x) < 0$ នោះអនុគមន៍ $f$ ចុះដាច់ខាតលើ $\mathscr{D}$

៤. តារាងអថេរភាពនៃ អនុគមន៍ $f$

| $x$ | $-\infty$ | | $-1$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f(x)$ | | $-$ | | | | $-$ | |
| $f(x)$ | $0$ | ↘ | $-\infty$ | | $+\infty$ | ↘ | $0$ |

សង់ខ្សែកោង $C$




បើ $y=1$ នោះ:

$$1=\ln\left(\frac{x+1}{x-1}\right)$$

$$\Leftrightarrow e=\frac{x+1}{x-1}$$

$$\Leftrightarrow ex-e=x+1$$

$$\Leftrightarrow x(e-1)=1+e$$

$$\Rightarrow x=\frac{3.7}{1.7}=2.17$$

៥. ពិភាក្សាតម្លៃ $m$ នៃសមីការ $\ln\left(\frac{x+1}{x-1}\right)=m \quad (I)$

$(I)$ ជាសមីការអាប់ស៊ីសនៃចំណុចប្រសព្វរវាង ខ្សែកោង $(C)$ និង បន្ទាត់ $y=m$ តាមក្រាប

គេបាន $m\in(-\infty,0)$ សមីការ (I) មានឫសតែមួយគត់ជាចំនួនពិតអវិជ្ជមាន

$$\ln\left(\frac{x+1}{x-1}\right)=m\Leftrightarrow\frac{x+1}{x-1}=e^m\Rightarrow x=\frac{e^m+1}{e^m-1}$$

$m\in(0,+\infty)$ សមីកា (I) មានឫសតែមួយគត់ជាចំនួនវិជ្ជមានគឺ $x=\dfrac{e^m+1}{e^m-1}$

$m=0$ សមីការ (I) គ្មានឫស

**VII** ក្នុងតម្រុយអរតូនរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមានមួយ គេឱ្យបីចំណុច $A(3,1,4),B(-1,2,5),C(5,-2,3)$

១. សរសេរសមីការប៉ារ៉ាម៉ែត និង សមីការឆ្លុះនៃបន្ទាត់ $(D)$ ដែលកាត់តាមចំណុច $C$ និងមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB}$

ដោយ $\overrightarrow{AB}=(-1-3,2-1,5-4)=(-4,1,1)$

គេបាន សមីកាប៉ារ៉ាម៉ែតនៃបន្ទាត់ $(D)$ : $\begin{cases}x=5-4t\\ y=-2+t\\ z=3+t\end{cases}\quad ,t\in\mathbb{R}$

សមីការឆ្លុះនៃ $(D)$ : $\dfrac{x-5}{-4}=\dfrac{y+2}{1}=\dfrac{z-3}{1}$

២. រកសមីការប្លង់ $(P)$ ដែលមានវ៉ិចទ័រណរម៉ាល់ $\overrightarrow{AC}$ ហើយកាត់តាមចំណុច $B$

ដោយ $\overrightarrow{AC}=(5-3,-2-1,3-4)=(2,-3,-1)$

គេបាន $(P):2(x+1)-3(y-2)-(z-5)=0$

$$2x+2-3y+6-z+5=0$$

ដូច្នេះ សមីការប្លង់ $(P):2x-3y-z+13=0$

រកសមីការស្វ៊ែ $(S)$ ដែលមានអង្កត់ផ្ចិត $[AB]$

ដោយ $[AB]=|\overrightarrow{AB}|=\sqrt{4^2+1^2+1^2}=\sqrt{18}=3\sqrt{2}$ នាំឱ្យ $r=\frac{[AB]}{2}=\frac{3\sqrt{2}}{2}$

និងផ្ចិត $\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2},\frac{z_A+z_B}{2}\right)=\left(\frac{3-1}{2},\frac{1+2}{2},\frac{4+5}{2}\right)=\left(1,\frac{3}{2},\frac{9}{2}\right)$

គេបានសមីការស្វ៊ែ $S:(x-1)^2+\left(y-\frac{3}{2}\right)^2+\left(z-\frac{9}{2}\right)^2=\left(\frac{3\sqrt{2}}{2}\right)^2$

$$x^2-2x+1+y^2-3y+\frac{9}{4}+z^2-9z+\frac{81}{4}=\frac{9}{2}$$

$$x^2+y^2+z^2-2x-3y-9z+\frac{45}{2}-\frac{9}{2}=0$$

ដូច្នេះ សមីការស្វ៊ែ $S:x^2+y^2+z^2-2x-3y-9z+18=0$

៣. គណនា $\overrightarrow{n}=\overrightarrow{AB}\times\overrightarrow{AC}$ រួចសរសេរសមីការប្លង់ $ABC$

គេបាន $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\-4&1&1\\2&-3&-1\end{vmatrix}=\begin{vmatrix}1&1\\-3&-1\end{vmatrix}\vec{i}-\begin{vmatrix}-4&1\\2&-1\end{vmatrix}\vec{j}+\begin{vmatrix}-4&1\\2&-3\end{vmatrix}\vec{k}$

$$=(-1+3)\vec{i}-(4-2)\vec{j}+(12-2)\vec{k}$$

$$\vec{n}=2\vec{i}-2\vec{j}+10\vec{k}$$

គេបានសមីការប្លង់ $ABC:2(x-3)-2(y-1)+10(z-4)=0$

$$2x-6-2y+2+10z-40=0$$

$$2x-2y+10z-44=0$$

$$x-y+5z-22=0$$

គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$

គេបាន $S_{\triangle ABC}=\frac{|n|}{2}=\frac{\sqrt{2^2+2^2+10^2}}{2}$

$$=\frac{\sqrt{4+4+100}}{2}=\frac{\sqrt{108}}{2}=\sqrt{27}=3\sqrt{3}$$ ឯកតាផ្ទៃក្រឡា

គណនាកូអរដោនេនៃចំណុច $M(x,y,z)$

$M$ ជាចំណុចប្រសព្វរវាងបន្ទាត់ $(D):x=5-4t,y=-2+t,z=3+t$ និងប្លង់ $(P);2x-3y-z+13=0$

គេបាន $2(5-4t)-3(-2+t)-(3+t)+13=0$

$$10-8t+6-3t-3-t+13=0$$

$$-12t=-26\Rightarrow t=\frac{13}{6}$$

នាំឱ្យ $x=5-\frac{4(13)}{6}=\frac{30-52}{6}=-\frac{11}{3},y=-2+\frac{13}{6}=\frac{-12+13}{6}=\frac{1}{6},z=3+\frac{13}{6}=\frac{31}{6}$

ដូនេះ ចំណុចប្រសព្វ $M\left(-\frac{11}{3},\frac{1}{6},\frac{31}{6}\right)$

**ក្រសួងអប់រំ យុវជន និងកីឡា** លេខបន្ទប់៖________

ប្រឡង៖ **សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** លេខតុ៖________

សម័យប្រឡង៖________ មណ្ឌលប្រឡង៖________

**ហត្ថលេខាអនុរក្ស៖** នាមត្រកូល និងនាមខ្លួន៖________

ថ្ងៃខែឆ្នាំកំណើត៖________ | អក្សរសម្ងាត់ |

ហត្ថលេខា៖________

- បេក្ខជនមិនត្រូវធ្វើសញ្ញាសម្គាល់អ្វីមួយនៅលើក្រដាស់ប្រឡងឡើយ។ ក្រដាស់ប្រឡងណាដែលមានសម្គាល់នឹងត្រូវបានពិន្ទុសូន្យ។
- បេក្ខជនមិនត្រូវចម្លងប្រធានវិញ្ញាសាដាក់លើក្រដាស់ប្រឡងជាដាច់ខាត។

---

$\dfrac{\quad}{125}$

# ១៥

វិញ្ញាសា៖ **គណិតវិទ្យាត្រៀម** រយៈពេល៖ 120 នាទី | អក្សរសម្ងាត់ |

រៀបរៀងដោយ៖ **ហ៊ីង វុទ្ធី**

**I** គេឱ្យចំនួនកុំផ្លិច $A=(\sqrt{3}-1)+i(\sqrt{3}+1)$ និង $B=\dfrac{x+iy}{1+i}$ ដែល $x,y$ ជាចំនួនពិត ។

១. សរសេរ $A^2$ ជាទម្រង់ពីជគណិត ហើយជាទម្រង់ត្រីកោណមាត្រ ។

២. សរសេរ $B$ ជាទម្រង់ពីជគណិត ។ រកតម្លៃ $x,y$ ដោយដឹងថា $2\overline{B}-A^2=0$ ($\overline{B}$ ជាកុំផ្លិចឆ្លាស់នៃ $B$) ។

**II** គណនាលីមីតខាងក្រោម៖

១. $\displaystyle\lim_{x\to-1}\frac{2x^2-x-3}{x^3+2x^2+6x+5}$

២. $\displaystyle\lim_{x\to0}\frac{\sin x+e^x-1}{x^2+x}$

៣. $\displaystyle\lim_{x\to\frac{\pi}{2}}\frac{\pi-2x}{\cos x}$

៤. $\displaystyle\lim_{x\to2}\frac{\sqrt{x^2-1}-\sqrt{2x-1}}{\sqrt{x+2}-\sqrt{x^2+2x-4}}$

**III** ១. ដោះស្រាយសមីការ $(E): y''+5y'+6y=0$ ។

២. រកចម្លើយនៃសមីការ $(E)$ បើគេដឹងថាបន្ទាត់ $(D): y=x-1$ ប៉ះក្រាបនៃចម្លើយត្រង់ $x=0$ ។

**IV** រកសមីការស្តង់ដានៃប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះស្របអ័ក្សអរដោនេ ហើយក្រាបវាកាត់តាមចំណុច $(-2,-3),(2,5)$ និង $(1,6)$ ។ កំណត់កូអរដោនេ កំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិស រួចសង់ប៉ារ៉ាបូល ។

**V** គេឱ្យអនុគមន៍ $g$ កំណត់លើ $\mathbb{R}$ ដោយ $g(x)=e^{2x}-2e^x+\frac{1}{2}x+1$ មានក្រាប $(C)$ ។

១. គណនា $\lim\limits_{x\to-\infty}g(x)$ និង $\lim\limits_{x\to+\infty}g(x)$ ។ រកសមីការបន្ទាត់ $(D)$ ជាអាស៊ីមតូតនៃ $(C)$ ។

២. បង្ហាញថា $g$ ជាអនុគមន៍កើន ។ សង់តារាងអថេរភាពនៃ $g$ ។

៣. សរសេរសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹងខ្សែកោង $(C)$ ត្រង់ $x=0$ ។

៤. សង់ក្រាប $(T),(D)$ និង $(C)$ ក្នុងតម្រុយតែមួយ ។

**VI** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(0,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(2,0,1),B(3,1,5)$ និង $C(1,4,4)$

១. គណនា $\overrightarrow{AB}$ និង $\overrightarrow{AC}$ ។

២. គណនា $\vec{N}=\overrightarrow{AB}\times\overrightarrow{AC}$ រួចគណនាក្រឡាផ្ទៃ $\triangle ABC$ ។

៣. រកសមីការប្លង់ $(ABC)$ ។ បង្ហាញថាចំណុច $D(2,0,2)$ មិននៅក្នុងប្លង់ $(ABC)$ ។

៤. រកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$ រួចគណនាមាឌតេត្រាអ៊ែត $ABCD$ ។

៥. សរសេរសមីការស្វ៊ែ $(S)$ ដែលមានអង្កត់ផ្ចិត $[AB]$ ។

# ដំណោះស្រាយ

**I** ១. សរសេរ $A^2$ ជាទម្រង់ពីជគណិត

គេមាន $A=(\sqrt{3}-1)+i(\sqrt{3}+1)$

គេបាន $A^2=\left[(\sqrt{3}-1)+i(\sqrt{3}+1)\right]^2$

$=(\sqrt{3}-1)^2+2(\sqrt{3}-1)(\sqrt{3}+1)i+i^2(\sqrt{3}+1)^2, i^2=-1$

$=3-2\sqrt{3}+1+4i-(3+2\sqrt{3}+1)$

ដូច្នេះ $A^2=-4\sqrt{3}+4i$

សរសេរ $A^2$ ទម្រង់ត្រីកោណមាត្រ

គេបាន $A^2=-4\sqrt{3}+4i$

$=8\left(-\frac{\sqrt{3}}{2}+\frac{1}{2}\right)$

ដូច្នេះ $A^2=8\left(\cos\frac{5\pi}{6}+i\sin\frac{5\pi}{6}\right)$

២. សរសេរ $B$ ជាទម្រង់ពីជគណិត

គេមាន $B=\frac{x+iy}{1+i}$ ដែល $x,y\in\mathbb{R}$

$=\frac{(x+iy)(1-i)}{(1+i)(1-i)}$

$=\frac{x-xi+iy-i^2y}{1-i^2}, i^2=-1$

$=\frac{(x+y)+(y-x)i}{2}$

ដូច្នេះ $B=\frac{x+y}{2}+\frac{y-x}{2}i$

រកតម្លៃ $x,y$ ដោយដឹងថា $2\overline{B}-A^2=0$ ($\overline{B}$ ជាកុំផ្លិចឆ្លាស់នៃ $B$) នោះ $\overline{B}=\frac{x+y}{2}-\frac{y-x}{2}i$

គេបាន
$$2\overline{B}-A^2=0$$
$$2\overline{B}=A^2$$
$$x+y-(y-x)i=-4\sqrt{3}+4i$$
$$\Leftrightarrow\begin{cases}x+y&=-4\sqrt{3} \quad (1)\\ y-x&=4 \quad (2)\end{cases}$$

យក $(1)+(2)$ នោះ $2y=4-4\sqrt{3}\Rightarrow y=2-2\sqrt{3}$

ជំនួសចូល $(1)$ នោះ $x=-4\sqrt{3}-y=-4\sqrt{3}-2+2\sqrt{3}=-2-2\sqrt{3}$

ដូច្នេះ $x=-2-2\sqrt{3}, y=2-2\sqrt{2}$

**II** គណនាលីមីត

១. $\lim_{x\to-1}\frac{2x^2-x-3}{x^3+2x^2+6x+5}$ រាងមិនកំណត់ $\frac{0}{0}$

គេបាន $\lim_{x\to-1}\frac{2x^2-x-3}{x^3+2x^2+6x+5}=\lim_{x\to-1}\frac{2x^2+2x-3x-3}{x^3+x^2+x^2+x+5x+5}$

$$= \lim_{x\to -1} \frac{2x(x+1)-3(x+1)}{x^2(x+1)+x(x+1)+5(x+1)}$$
$$= \lim_{x\to -1} \frac{(x+1)(2x-3)}{(x+1)(x^2+x+5)}$$
$$= \frac{2(-1)-3}{(-1)^2+(-1)+5}$$

ដូច្នេះ $\lim_{x\to -1} \frac{2x^2-x-3}{x^3+2x^2+6x+5} = -1$

២. $\lim_{x\to 0} \frac{\sin x + e^x - 1}{x^2+x}$ រាងមិនកំណត់ $\frac{0}{0}$

គេបាន $\lim_{x\to 0} \frac{\sin x + e^x - 1}{x^2+x} = \lim_{x\to 0} \frac{\sin x}{x(x+1)} + \lim_{x\to 0} \frac{e^x-1}{x(x+1)}$

$$= \lim_{x\to 0} \frac{\sin x}{x} \times \frac{1}{x+1} + \lim_{x\to 0} \frac{e^x-1}{x} \times \frac{1}{x+1}$$
$$= 1\times 1 + 1\times 1$$

ដូច្នេះ $\lim_{x\to 0} \frac{\sin x + e^x - 1}{x^2+x} = 2$

៣. $\lim_{x\to \frac{\pi}{2}} \frac{\pi - 2x}{\cos x}$ រាងមិនកំណត់ $\frac{0}{0}$

តាង $t = x - \frac{\pi}{2} \Rightarrow x = t + \frac{\pi}{2}$ បើ $x \to \frac{\pi}{2}$ នោះ $t \to 0$

គេបាន $\lim_{t\to 0} \frac{\pi - 2(t+\frac{\pi}{2})}{\cos(t+\frac{\pi}{2})} = \lim_{t\to 0} \frac{-2t}{-\sin t}$

$$= 2\lim_{t\to 0} \frac{t}{\sin t}$$
$$= 2\times 1$$

ដូច្នេះ $\lim_{x\to \frac{\pi}{2}} \frac{\pi - 2x}{\cos x} = 1$

៤. $\lim_{x\to 2} \frac{\sqrt{x^2-1}-\sqrt{2x-1}}{\sqrt{x+2}-\sqrt{x^2+2x-4}}$ រាងមិនកំណត់ $\frac{0}{0}$

តាង $A(x) = \sqrt{x^2-1}+\sqrt{2x-1} \Rightarrow A(2) = \sqrt{3}+\sqrt{3} = 2\sqrt{3}$

និង $B(x) = \sqrt{x+2}-\sqrt{x^2+2x-4} \Rightarrow B(2) = 2+2 = 4$

គេបាន $\lim_{x\to 2} \frac{\sqrt{x^2-1}-\sqrt{2x-1}}{\sqrt{x+2}-\sqrt{x^2+2x-4}} = \lim_{x\to 2} \frac{(\sqrt{x^2-1}-\sqrt{2x-1})A(x).B(x)}{(\sqrt{x+2}-\sqrt{x^2+2x-4})B(x).A(x)}$

$$= \lim_{x\to 2} \frac{[x^2-1-(2x-1)]B(x)}{[x+2-(x^2+2x-4)]A(x)}$$
$$= \lim_{x\to 2} \frac{(x^2-2x)B(x)}{-(x^2+x-6)A(x)}$$
$$= \lim_{x\to 2} \frac{x(x-2)B(x)}{-(x-2)(x+3)A(x)}$$
$$= \lim_{x\to 2} \frac{xB(x)}{-(x+3)A(x)}$$
$$= \frac{2.B(2)}{-5.A(2)} = \frac{2\times 4}{-5\times 2\sqrt{3}} = -\frac{4\sqrt{3}}{15}$$

ដូច្នេះ $\lim_{x\to 2} \frac{\sqrt{x^2-1}-\sqrt{2x-1}}{\sqrt{x+2}-\sqrt{x^2+2x-4}} = -\frac{4\sqrt{3}}{15}$

**III** ១. ដោះស្រាយសមីការ $(E): y''+5y'+6y=0$

មានសមីការសំគាល់ $\lambda^2+5\lambda+6=0 \Leftrightarrow \lambda^2+2\lambda+3\lambda+6=0$

$$\Leftrightarrow \lambda(\lambda+2)+3(\lambda+2)=0$$

$$\Leftrightarrow (\lambda+3)(\lambda+2)=0$$

$$\Leftrightarrow x=-2, x=-3$$

គេបាន $y=Ae^{\lambda_1}+Be^{\lambda_2}=Ae^{-2x}+Be^{-3x}$

ដូនេះ ចម្លើយទូទៅនៃសមីការ $(E)$ គឺ $y=Ae^{-2x}+Be^{-3x}$ ដែល $A,B\in\mathbb{R}$

២. រកចម្លើយនៃសមីការ $(E)$ បើគេដឹងថាបន្ទាត់ $(D): y=x-1$ ប៉ះក្រាបនៃចម្លើយត្រង់ $x=0$

នោះ $y(0)=0-1=-1$ និង $y'=(x-1)'=1 \Rightarrow y'(0)=1$

ដោយ $y=Ae^{-2x}+Be^{-3x} \Rightarrow y(0)=Ae^0+Be^0$

$$\Leftrightarrow -1=A+B \qquad (1)$$

និង $y=Ae^{-2x}+Be^{-3x} \Rightarrow y'=(-2x)'Ae^{-2x}+(-3x)'Be^{-3x}$

$$=-2Ae^{-2x}-3Be^{-3x}$$

$$\Rightarrow y'(0)=-2Ae^0-3Be^0$$

$$\Leftrightarrow 1=-2A-3B \qquad (2)$$

យក $2(1)+(2)$ គេបាន $2(-1)+1=2(A+B)-2A-3B$

$$-1=2A+2B-2A-3B$$

$$-1=-B$$

$$B=1$$

ជំនួលចូល $(1)$ នោះ $-1=A+1 \Rightarrow A=-2$

ដូច្នេះ ចម្លើយនៃសមីការ $(E)$ គឺ $y=-2e^{-2x}+e^{-3x}$

**IV** រកសមីការស្តង់ដានៃប៉ារ៉ាបូល

ដោយប៉ារ៉ាបូលមានអ័ក្សឆ្លុះជាអ័ក្សឈរ ហើយក្រាបវាកាត់តាមចំណុច $(-2,-3),(2,5)$ និង $(1,6)$

សមីការស្តង់ដានៃប៉ារ៉ាបូលមានអ័ក្សឆ្លុះជាអ័ក្សឈរគឺ $(x-h)^2=4p(y-k)$

កាត់តាមចំណុច $(-2,-3)$ នោះ $(-2-h)^2=4p(-3-k)$

$$4+4h+h^2=-12p-4pk$$

$$h^2+4pk=-12p-4h-4 \qquad (1)$$

កាត់តាមចំណុច $(2,5)$ នោះ $(2-h)^2=4p(5-k)$

$$4-4h+h^2=20p-4pk$$

$$h^2+4pk=20p+4h-4$$

$$-12p-4h-4=20p+4h-4$$

$$32p+8h=0$$

$$4p+h=0 \qquad (2)$$

កាត់តាមចំណុច $(1,6)$ នោះ $$(1-h)^2=4p(6-k)$$
$$1-2h+h^2=24p-4pk$$
$$h^2+4pk=24p+2h-1$$
$$-12p-4h-4=24p+2h-1$$
$$36p+6h=-3$$
$$12p+2h=-1 \qquad (3)$$
យក $2(1)-(2)$ គេបាន $2(4p+h)-(12p+2h)=0-(-1)$
$$8p+2h-12p-2h=1$$
$$-4p=1$$
$$p=-\frac{1}{4}$$
ជំនួសចូល $(2)$ នោះ $h=-4p=-4\left(-\frac{1}{4}\right)=1$

ជំនួសចូល $(1)$ គេបាន $4+4h+h^2+12p=-4pk$
$$4+4(1)+1^2-3=k$$
$$6=k$$
ដូនេះ រកសមីការស្តង់ដានៃប៉ារ៉ាបូលគឺ $P:(x-1)^2=-(y-6)$

កំណត់កូអរដោនេ កំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិស

គេបាន កពូល $V(h,k)=V(1,6)$

កំណុំ $F(h,k+p)=F\left(1,6-\frac{1}{4}\right)=F\left(1,\frac{23}{4}\right)$

សមីការបន្ទាត់ប្រាប់ទិស $\Delta: y=k-p=6+\frac{1}{4}=\frac{25}{4}$

សង់ប៉ារ៉ាបូល



V គេឱ្យអនុគមន៍ $g$ កំណត់លើ $\mathbb{R}$ ដោយ $g(x) = e^{2x} - 2e^x + \frac{1}{2}x + 1$ មានក្រាប $(C)$

១. គណនា $\lim\limits_{x\to-\infty} g(x)$ និង $\lim\limits_{x\to+\infty} g(x)$

គេបាន $\lim\limits_{x\to-\infty} g(x) = \lim\limits_{x\to-\infty}\left(e^{2x} - 2e^x + \frac{1}{2}x + 1\right)$

$= -\infty$

$\lim\limits_{x\to+\infty} g(x) = \lim\limits_{x\to+\infty}\left(e^{2x} - 2e^x + \frac{1}{2}x + 1\right)$

$= \lim\limits_{x\to+\infty} e^{2x}\left(1 - \frac{2}{e^x} + \frac{x}{2e^{2x}} + \frac{1}{e^{2x}}\right)$

$= +\infty$

រកសមីការបន្ទាត់ $(D)$ ជាអាស៊ីមតូតនៃ $(C)$

ដោយ $\lim\limits_{x\to-\infty}(e^{2x} - 2e^x) = 0$ នាំឱ្យ $D: y = \frac{1}{2}x + 1$ ជាអាស៊ីមតូតទ្រេតខាង $-\infty$

២. បង្ហាញថា $g$ ជាអនុគមន៍កើន

យើងមាន $g(x) = e^{2x} - 2e^x + \frac{1}{2}x + 1 \Rightarrow g'(x) = 2e^{2x} - 2e^x + \frac{1}{2}$

$= 4e^{2x} - 4e^x + 1$

$= (2e^x - 1)^2 > 0$

ដោយ $g'(x) > 0$ នោះ $g$ ជាអនុគមន៍កើន

តារាងអថេរភាពនៃ $g$

| $x$ | $-\infty$      $+\infty$ |
|---|---|
| $g'(x)$ | $+$ |
| $g(x)$ | $-\infty$ ↗ $+\infty$ |

៣. សរសេរសមីការបន្ទាត់ប៉ះ $(T)$ ទៅនឹងខ្សែកោង $(C)$ ត្រង់ $x = 0$

គេបាន $T: y - g(0) = g'(0)(x - x_0)$

$y - (e^0 - 2e^0 + 0 + 1) = (2e^0 - 1)^2(x - 0)$

$y = x$

ដូច្នេះ បន្ទាត់ប៉ះ $T: y = x$

៤. សង់ក្រាប $(T), (D)$ និង $(C)$ ក្នុងតម្រុយតែមួយ

| $x$ | $T: y = x$ | $D: y = \frac{1}{2}x + 1$ | $C: y = e^{2x} - 2e^x + \frac{1}{2}x + 1$ |
|---|---|---|---|
| 0 | 0 | 1 | 0 |
| 1 | 1 | 1.5 | 3.4 |




**VI** ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន $(0, \overrightarrow{i}, \overrightarrow{j}, \overrightarrow{k})$ គេមានចំណុច $A(2,0,1), B(3,1,5)$ និង $C(1,4,4)$

១. គណនា $\overrightarrow{AB}$ និង $\overrightarrow{AC}$

គេបាន $\overrightarrow{AB} = (3-2, 1-0, 5-1) = (1,1,4)$

$\overrightarrow{AC} = (1-2, 4-0, 4-1) = (-1,4,3)$

២. គណនា $\overrightarrow{N} = \overrightarrow{AB} \times \overrightarrow{AC}$

គេបាន $\overrightarrow{N} = \overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 1 & 1 & 4 \\ -1 & 4 & 3 \end{vmatrix} = \vec{i}(3-16) - \vec{j}(3+4) + \vec{k}(4+1) = -13\vec{i} - 7\vec{j} + 5\vec{k}$

គណនាក្រឡាផ្ទៃ $\triangle ABC$

គេបាន $S_{\triangle ABC} = \frac{1}{2}|\overrightarrow{N}| = \frac{1}{2}\sqrt{13^2+7^2+5^2} = \frac{1}{2}\sqrt{169+49+25} = \frac{1}{2}\sqrt{243} = \frac{9\sqrt{3}}{2}$ ឯកត្តាផ្ទៃ

៣. រកសមីការប្លង់ $(ABC)$

គេបាន $(ABC) : a(x-x_A) + b(y-y_A) + c(z-z_A) = 0$

$$-13(x-2) - 7(y-0) + 5(z-1) = 0$$

$$-13x + 26 - 7y + 5z - 5 = 0$$

$$-13x - 7y + 5z + 21 = 0$$

$$13x + 7y - 5z - 21 = 0$$

បង្ហាញថាចំណុច $D(2,0,2)$ មិននៅក្នុងប្លង់ $(ABC)$

គេបាន $13x_D + 7y_D - 5z_D - 21 = 13(2) + 7(0) - 5(2) - 21$

$$= 26 - 10 - 21$$

$$= -5 \neq 0$$

៤. រកចម្ងាយពីចំណុច $D$ ទៅប្លង់ $(ABC)$

គេបាន $d\left[D,(ABC)\right]=\dfrac{|13x_D+7y_D-5z_D-21|}{\sqrt{13^2+7^2+5^2}}=\dfrac{|-5|}{9\sqrt{3}}$

$=\dfrac{5\sqrt{3}}{27}$ ឯកត្តាប្រវែង

គណនាមាឌតេត្រាអ៊ែត $ABCD$

គេបាន មាឌតេត្រាអ៊ែត $=\dfrac{1}{3}$ក្រឡាផ្ទៃបាទ $\times$ កំពស់

$$V_{ABCD}=\frac{1}{3}\times\frac{1}{2}|\overrightarrow{N}|\times d\left[D,(ABC)\right]$$

$$=\frac{1}{3}\times\frac{9\sqrt{3}}{2}\times\frac{5\sqrt{3}}{27}$$

$$=\frac{3\times 5}{18}=\frac{5}{6}\text{ ឯកត្តាមាឌ}$$

៥. សរសេរសមីការស្វ៊ែ $(S)$ ដែលមានអង្កត់ផ្ចិត $[AB]$

ដោយ $[AB]$ ជាអង្កត់ផ្ចិតនោះ $I\left(\dfrac{x_A+x_B}{2},\dfrac{y_A+y_B}{2},\dfrac{z_A+z_B}{2}\right)=\left(\dfrac{2+3}{2},\dfrac{0+1}{2},\dfrac{1+5}{2}\right)=I\left(\dfrac{5}{2},\dfrac{1}{2},3\right)$

និងមានកាំ $r=\dfrac{|\overrightarrow{AB}|}{2}=\dfrac{\sqrt{1^2+1^2+4^2}}{2}=\dfrac{\sqrt{20}}{2}=\dfrac{2\sqrt{5}}{2}=\sqrt{5}$

គេបាន $S:\left(x-\dfrac{5}{2}\right)^2+\left(y-\dfrac{1}{2}\right)^2+(z-3)^2=(\sqrt{5})^2$

$$x^2-5x+\frac{25}{4}+y^2-y+\frac{1}{4}+z^2-6z+9-5=0$$

$$x^2+y^2+z^2-5x-y-6z+\frac{21}{2}=0$$